ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>**

**<u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៥២**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាតាចា វិចស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក អាឡាញ ប្រៃអត *(Mr. Aline BRIOT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អានីស អះមេដ *(Mr. Anees AHMED)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាធិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោក គឹមម៉េងឃី

លោក គង់ ពិសី

លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ*(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-Naprous)*

**មេធាវីជំនួយការរបស់សាក្សី៖**

លោក គង់ សំអុន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក  កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក សេក ជន

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ២
សួរដោយ ចៅក្រម ធូ មណី ផ្ដើមពី ........ ទំព័រ ៧
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ........ ទំព័រ ១៤
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ ទំព័រ ១៤
សួរដោយ លោក តាន់ សេណារ៉ុង ផ្ដើមពី ........ ទំព័រ ១៩
សួរដោយ កញ្ញា ម៉ុច សុវណ្ណារី ផ្ដើមពី ........ ទំព័រ ២៨
សួរដោយ លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សូណាព្រូស ផ្ដើមពី ........ ទំព័រ ៣១
សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី ........ ទំព័រ ៣២
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី ........ ទំព័រ ៣៣
សួរបន្តដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៤២

### លោក ឡាច មាន

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៤៥
សួរដោយ ចៅក្រម យ៉ា សុខន ផ្ដើមពី ........ ទំព័រ ៥១
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ ទំព័រ ៧៥
សួរបន្តដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ៧៩

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
| --- | --- |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក សេក ដន | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន | បារាំង |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក ឡាច មាន | ខ្មែរ |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| ចៅក្រម ធូ មណី | ខ្មែរ |
| ចៅក្រម យ៉ា សុខន | ខ្មែរ |
| លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សូណាព្រូស | បារាំង |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៣:២៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ថ្ងៃនេះ យើងបន្តកិច្ចដំណើរការនីតិវិធីស្តាប់សក្ខីកម្មសាក្សីជាបន្តទៀត ហើយដោយសារសាក្សីមួយរូបមានបញ្ហាសុខភាពដែលត្រូវពន្យារពេលក្នុងការកោះហៅ គឺយើងធ្វើសាក្សីបន្តទៀត គឺ KW-20 ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានរបស់ភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សេ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន!ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯមេធាវីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះលោកស្រី ហ្សាប៊ីយ៉ែន ទ្រូស្ស ណាព្រូស ទើបតែមានវត្តមានក្នុងថ្ងៃនេះ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃ KW-20 នឹង KW-21 មានវត្តមាន ។ សាក្សីទាំងពីររូបមិនមានជាប់ចំណងញាតិលោហិត និងញាតិពន្ធ ជាមួយនឹងជនជាប់ចោទ ឬភាគីរដ្ឋប្បវេណីនោះទេ ។ សាក្សីបានធ្វើសម្បថរួចហើយ ។

**ប្រធានអង្គជំនុំ៖**

ដោយអនុវត្តតាមវិធាន ២៣.៧(ង).១ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងសូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ឡើងធ្វើការស្នើសុំទទួលស្គាល់មេធាវីបរទេសដែលជាដៃគូរបស់ខ្លួន ដែលមិនទាន់បានស្នើសុំទទួលស្គាល់ពីអង្គជំនុំជម្រះសាលាដំបូងកន្លងមក ។ សូមអញ្ជើញ ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

ជាដំបូង នាងខ្ញុំសូមគោរពដល់លោកប្រធានអង្គជំនុំជម្រះ ហើយនិងអង្គជំនុំជម្រះសាលាដំបូងទាំងមូល ។ ថ្ងៃនេះនាងខ្ញុំសូមធ្វើការបង្ហាញ និងសូមធ្វើការស្នើសុំទទួលស្គាល់ដល់លោកស្រីមេធាវីប្រធានគណៈមេធាវី ហ្សាប៊ីយ៉ែន ទ្រូស្ស ណាព្រូស ។ លោកស្រីគឺជាប្រធានគណៈមេធាវីទីក្រុងតាត ហើយលោកស្រីបានស្បថចូលនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយលោកស្រីបានអនុវត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ លោកស្រីបានទទួលនូវការអនុញ្ញាតឲ្យប្រកបវិជ្ជាជីវមេធាវី

របស់លោកស្រី នៅក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

[០៩:០៦:០១]

ដូច្នេះ ថ្ងៃនេះនាងខ្ញុំស្នើសុំដល់លោកប្រធាន និងអង្គជំនុំជម្រះសាលាដំបូងទាំងមូល ដើម្បីទទួលស្គាល់គាត់ ឱ្យគាត់មានសិទ្ធិនៅក្នុងការចូលរួមនៅក្នុងដំណើរការនីតិវិធីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមបីរបស់នាងខ្ញុំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស ។

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់លោកស្រីធ្វើជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីតំណាងក្រុមបី សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ ដោយយោងទៅតាមការទទួលស្គាល់នេះ លោកស្រីមានសិទ្ធិនិងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិដែរ ចាប់ពីពេលនេះតទៅ ។ សូមអញ្ជើញអង្គុយចុះ ។

មន្ត្រីតុលាការ អញ្ជើញសាក្សី KW-20 ចូលមកកាន់បន្ទប់សវនាការ ។

*[សាក្សីចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៨:៣៦]

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សាក្សី តើលោកមានឈ្មោះអ្វីដែរ?

**លោក សេក ដន៖**

**ឆ៖** សាក្សីខ្ញុំបាទឈ្មោះសេក ដន ។

**ស៖** លោកមានឈ្មោះផ្សេងទៀត ក្រៅពីឈ្មោះដន ដែរឬទេ? លោកមានឈ្មោះអ្វីផ្សេងទៀតក្រៅពីឈ្មោះ ដន ដែរឬទេ?

**ឆ៖** អត់មានឈ្មោះអ្វីផ្សេងទេ ។

**ស៖** លោកសេក ដន លោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ...ប្រាំបីឆ្នាំហើយ ។

**ស៖** លោកឆ្លើយម្តងទៀត ហើយអង្គជំនុំជម្រះសូមណែនាំលោកថា លោកនឹងឆ្លើយនូវសំណួរនេះគឺចាំឲ្យមានភ្លើងពណ៌ ក្បាលមីក្រូហ្នឹងមានភ្លើងក្រហមសិន ភ្លើងពណ៌ក្រហមសិន អាហ្នឹងចាប់ផ្តើមនិយាយ ទើបមានការបកប្រែ ហើយនិងអ្នកធ្វើកំណត់ហេតុ ប្រតិចារឹកហ្នឹងគេអាចកត់ត្រាសម្តីរបស់លោកបាន ។ លោកយល់ទេ? ឥឡូវម្តងទៀតណា! ដល់ពេលនេះតើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

[០៩:១០:០៨]

**ឆ៖** ដល់ពេលនេះខ្ញុំអាយុ៤៨ឆ្នាំ ។

**ស៖** លោកប្រកបមុខរបររកស៊ីអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** ស្រែ ។

**ស៖** ម្តងទៀត លោកឆ្លើយនឹងសំណួររបស់យើងម្តងទៀត ដោយរង់ចាំភ្លើងក្រហមនៅក្បាលមីក្រូ មុននឹងលោកនិយាយ ។

**ឆ៖** របររកស៊ីសព្វថ្ងៃធ្វើស្រែ ។

**ស៖** របាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា លោកពុំមានចំណងញាតិលោហិត ញាតិពន្ធ ឬក៏ជាសហព័ទ្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ ហើយនិងថាលោកបានស្បថរួចហើយ តើជាការពិតដែរឬទេ?

**ឆ៖** ស្បថរួចហើយ ជាការពិត ។

**ស៖** តើលោកជាប់ជាចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីរឿងក្តីនេះដែរឬទេ?

**ឆ៖** អត់មានជាប់សាច់ញាតិ សាច់សារលោហិតអីទេ ។

**ប្រធានអង្គជំនុំ៖**

លោកសេក ដន ក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើងប្រាប់អំពីសិទ្ធិនិងករណីកិច្ចដល់លោកដូចខាងក្រោមនេះ ។

លោក សេក ដន ក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬអំណះអំណាងណាមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនលោក ។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងនោះ នាំឲ្យលោកត្រូវទទួលរងការចោទប្រកាន់ ។ ទន្ទឹមនឹងនេះ លោក សេក ដន ក្នុងនាមលោកជាសាក្សី លោកមានករណីកិច្ចនិយាយជូនដល់អង្គសវនាការតែការណាដែលពិត ដែលលោកបានឃើញ បានដឹងបានឮដោយផ្ទាល់។ ហើយលោកមិន

គប្បីឆ្លើយនឹងសំណួរដោយធ្វើសេចក្តីសន្និដ្ឋាននោះឡើយ ។ លោកយល់អំពីសិទ្ធិនិងករណីកិច្ចក្នុងនាមលោកជាសាក្សីដែលយើងបានប្រាប់នេះដែរឬទេ? លោកយល់ទេ? យល់ទេ អំពីអ្វីដែលយើងបានប្រាប់អំពីសិទ្ធិរបស់លោក ហើយនិងករណីកិច្ចរបស់លោក ដែលលោកត្រូវនិយាយតែការណ៍ណាដែលពិត? លោក ក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនលោក គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬក៏អះអាងរបស់លោក នាំឲ្យលោកត្រូវទទួលរងការចោទប្រកាន់ ។ នេះជាសិទ្ធិទីពីរ គឺករណីកិច្ចក្នុងនាមលោកជាសាក្សី លោកមានករណីកិច្ច និយាយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញដោយផ្ទាល់ ហើយនៅក្នុងចម្លើយតបនេះគឺលោកមិនគប្បីឆ្លើយដោយធ្វើសេចក្តីទេ ។ លោកយល់ដែរឬទេ? លោកអាចឆ្លើយបានទេ លោកសេក ដន? មេធាវីប្រឹក្សាយោបល់ជាមួយនឹងសាក្សី លោកអាចធ្វើការសម្របសម្រួលជាមួយនឹងសាក្សីរូបនេះ ដើម្បីពន្យល់អំពីសិទ្ធិ និងករណីកិច្ចដល់គាត់ដោយផ្ទាល់ ។ លោកអាចអញ្ជើញទៅផ្ទាល់ ដើម្បីពន្យល់គាត់ ។

[០៩:១៧:៣៤]

តើលោកយល់ហើយឬនៅ អំពីសិទ្ធិ និងករណីកិច្ចក្នុងនាមជាសក្សី ក្រោយពីមេធាវីបានប្រឹក្សាយោបល់ជាមួយនឹងលោក លោកសេក ដន?

**លោក សេក ដន៖**

បាទ, ខ្ញុំបានឃើញជារបបកាលនៅសម័យនោះ កាលនៅ ស-២១នោះ ។

**ប្រធានអង្គជំនុំ៖**

លោកចាំនិយាយ ឆ្លើយនូវសំណួរឲ្យជាក់លាក់ណា ។

[០៩:១៨:០០]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក សេក ដន តើលោករស់នៅទីណាខ្លះ និងធ្វើការងារអ្វីខ្លះនៅក្នុងអំឡុងពេលចន្លោះពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥?

**ឆ៖** កាលពីមុនឆ្នាំ តាំងពីឆ្នាំ៧៥ កាលពីខ្ញុំនៅកុមារគ្រូបង្រៀននៅកាច់ទន្ទ្រានខែត្ររួចបានពេលនោះបានគេយកខ្ញុំមកទីក្រុងភ្នំពេញ មានឈ្លបគេពីរនាក់ គេជូនខ្ញុំមកនៅសាលាលេខ៥ មកនៅសាលាលេខ៥ សម្រាកមួយយប់ ថ្ងៃឡើងបាន អ៎យប់-- ពេលព្រឹកឡើងបានគេជូនឡានយកមកទីក្រុងភ្នំពេញ

រួចទៅហាត់នៅសាលាព្រែកត្នោត សាលាបច្ចេកទេស ។

**ស៖** លោកត្រូវអង្គការបញ្ជូនលោកមកពីសាលាលេខ៥ នៅក្នុងខេត្តកំពង់ឆ្នាំងហ្នឹងមកភ្នំពេញទៅហាត់រៀននៅសាលាបច្ចេកទេសព្រែកត្នោតហ្នឹង នៅក្នុងឆ្នាំណា? លោកចងចាំដែរឬទេ?

**ឆ៖** ខ្ញុំអត់បានចងចាំទេ កាលនោះខ្ញុំនៅកុមារតូច ខ្ញុំគ្រាន់តែទៅតាមគេ ។

**ស៖** កាលនោះលោកចងចាំទេ អាយុប្រហែលជា លោកមានអាយុប្រហែលប៉ុន្មានឆ្នាំ កាលពីលោកមកដល់ មករៀននៅសាលាបច្ចេកទេសព្រែកត្នោត?

រំឭកលោកម្តងទៀត ចាំមានភ្លើងក្រហមនៅក្នុងក្បាល នៅលើក្បាលមីក្រូ សូមឆ្លើយណ៎ា បានសំឡេងលោកឮ អ្នកផ្សេងទៀតស្តាប់បាន ខំលោកនិយាយ តែស្តាប់តែខ្លួនឯងប៉ុណ្ណោះ ។ លោកឆ្លើយកាលពីលោកដែលគេបញ្ជូនមកហាត់រៀននៅសាលាបច្ចេកទេសព្រែកត្នោតហ្នឹង លោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** កាលដែលគេយកខ្ញុំមកហាត់នៅបច្ចេកទេសនៅសាលាព្រែកត្នោតខ្ញុំអាយុ១១ឆ្នាំ ។

**ស៖** លោកមកហាត់រៀននៅសាលាបច្ចេកទេសព្រែកត្នោតអស់រយៈពេលប្រហែលប៉ុន្មានខែប៉ុន្មានឆ្នាំដែរនៅទីនោះ?

**ឆ៖** ប្រហែលបីខែ ។

**ស៖** បន្ទាប់ពីហាត់រៀននៅសាលាបច្ចេកទេសព្រែកត្នោតអស់រយៈពេលបីខែ តើលោកត្រូវបានគេបញ្ជូនទៅធ្វើការនៅទីណាទៀត?

**ឆ៖** ចាប់ពីព្រែកត្នោតមក គេបញ្ជូនខ្ញុំឲ្យទៅនៅកុមារ មិនដឹងនៅឯណាទេ ជិតៗភ្នំពេញនេះប៉ុនខ្ញុំអត់មានស្គាល់ រែកដី រែកទំនប់គេដែរ ។

**ស៖** លោកត្រូវបានគេបញ្ជូនទៅកន្លែងធ្វើស្រែ រានដីលើកទំនប់ លើកភ្លឺស្រែ ជីកប្រឡាយ នៅក្បែរភ្នំពេញ ដែលលោកមិនដឹង តើលោកទៅធ្វើការនៅទីនោះអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** នៅជិតៗហ្នឹងខ្ញុំយូរដែរ ប៉ុន្តែអត់ស្គាល់ ដឹងខែប៉ុន្មាន ដឹងថ្ងៃប៉ុន្មានទេបានគេយកខ្ញុំមកដូរមកនៅស-២១ នេះនោះ ។

[០៩:២២:៣៤]

**ស៖** លោកដឹងថា លោកបានទៅដល់មន្ទីរស-២១ ហ្នឹងនៅក្នុង នៅថ្ងៃខែឆ្នាំណាដែរ លោកចងចាំដែរឬទេ?

**ធ៖** ខែខ្ញុំអត់ដឹង ដឹងតែឆ្នាំ ប្រហែលដើម៧៨ ខ្ញុំនៅបានមួយឆ្នាំ ធ្វើកុមារពេទ្យនៅនោះ សម្រាប់ដើរចែកថ្នាំអ្នកទោស តាមមនុស្សធំៗ ។

**ស៖** កាលពីលោកទៅដល់មន្ទីរស-២១ ដែលលោកបាននិយាយអម្បាញ់មិញនេះ សំណួរសួរថា កាលពីលោកទៅដល់ភ្លាមនុ៎ង ឈ្មោះនៃមន្ទីរស-២១ ហ្នឹងពិតប្រាកដ គេហៅថាម៉េច ដែលលោកស្គាល់ ហើយលោកឮគេប្រាប់ថាលោកបានមកធ្វើការនៅទីនោះ? មន្ទីរស-២១ អ៊ីចឹង ឬក៏ឈ្មោះផ្សេងពីនេះ?

**ធ៖** កាលនោះអត់ប្រាប់ផង ស្រាប់តែមកដល់ឃើញឈ្មោះហ្នឹងដែរ ស-២១ នេះខ្ញុំអត់ដែលស្គាល់ផង ទើបថានៅយូរបានខ្ញុំស្គាល់ ខ្ញុំអត់មានយកចិត្តទុកដាក់ថា អង្គភាពណា ឯណាផង ខ្ញុំអត់ស្គាល់កាលនោះ ខ្ញុំនៅតូចកុមារ ទើបមកស្គាល់ស-២១ ដែលធំ ដែលពេលនេះរត់ ដែលនៅបានយូរបាន ទើបស្គាល់ ពីមុនខ្ញុំអស់ស្គាល់ផង ។

**ស៖** លោកបានចាកចេញពីមន្ទីរស-២១ នៅក្នុងថ្ងៃខែឆ្នាំណាដែរ?

**ធ៖** បានចាកចេញនៅពេលផ្ទុះអារុធ រត់ចេញ គេឲ្យនាំគ្នាថយចេញ តូចៗថយមុនបន្តៗទៅ នៅតែមនុស្សធំៗក្រោយ ។

**ស៖** ឥឡូវហ្នឹងត្រឡប់ក្រោយវិញ គឺពេលដែលលោកត្រូវបានអង្គការចាត់លោកឲ្យទៅធ្វើការនៅមន្ទីរស-២១ ចូលលោករៀបរាប់អំពីភារកិច្ចដែលលោក ដែលអង្គការចាត់ឲ្យលោកធ្វើការងារនៅទីនោះ តើលោកធ្វើបានធ្វើអ្វីខ្លះ?

**ធ៖** អង្គការចាត់ខ្ញុំឲ្យទៅធ្វើនៅទីនោះ ខ្ញុំធ្វើជាកូនពេទ្យសម្រាប់ដើរចែកថ្នាំអ្នកទោសតាមមនុស្សធំៗដែលបងៗ ។ អ្នកឈឺសុំថ្នាំឲ្យថ្នាំ ។

**ស៖** លោកចេះអក្សរទេ កាលពីគេបញ្ជូនទៅហ្នឹង លោកបានរៀនសូត្រចេះអក្សរទេ?

**ធ៖** កាលពីមុន ខ្ញុំអត់ចេះអក្សរទេ ។

**ស៖** ឥឡូវនេះ លោកចេះអក្សរដែរឬទេ?

**ធ៖** ឥឡូវខ្ញុំបានរៀនថ្នាក់អក្ខរកម្មគ្រាន់ចេះ គ្រាន់បានមើល គ្រាន់បើដែរ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរដល់សាក្សីរូបនេះដែរឬទេ?

អញ្ជើញលោកចៅក្រម ធូ មណី ។

[០៩:២៦:២៩]

**សួរដោយចៅក្រម ធូ មណី៖**

**ស៖** លោក សេក ដន លោកបានអះអាងថា ពេលដែលលោកចូលមកមន្ទីរស-២១ ហ្នឹងគេឲ្យលោកដើរចែកថ្នាំតាមមនុស្សធំៗ ។ អ៊ីចឹង តើលោកកន្លងមកលោកមុននឹងពេលលោកដើរចែកថ្នាំហ្នឹង លោកធ្លាប់បានរៀនវិជ្ជាពេទ្យអីដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលបានរៀនវិជ្ជាពេទ្យទេ គេឲ្យខ្ញុំមកដើរចែកថ្នាំតាមធំៗ មនុស្សធំៗគេអ្នកចេះ ខ្ញុំគេគ្រាន់តែបង្ហាញថ្នាំយកឲ្យអានេះ យកឲ្យនោះ ។ ថ្នាំជំនាន់នោះ ថ្នាំអាចម៍ទន្សាយនុ៎ង ។

**ស៖** តើក្នុងការដែលលោកដើរចែកថ្នាំហ្នឹង ចែកគ្រប់អគារទាំងអស់នៅក្នុងមន្ទីរស-២១ ហ្នឹង ឬក៏ចែកតាមផ្នែក?

**ឆ៖** កាលនោះ ចែកតាមផ្នែក ខ្ញុំចែកនៅផ្ទះលេខ៣ នៅអគារលេខ៣ ។

**ឆ៖** ចុះអគារផ្សេងក្រៅពីអគារលេខ៣ហ្នឹង លោកធ្លាប់ដើរចែកដែរឬទេ?

**ស៖** អគារផ្សេងមានក្រុមគេផ្សេង ចែកគ្នាមួយអគារពីរនាក់ មួយអគារពីរនាក់ ។

**ស៖** តើពេទ្យទាំងអស់ដែលបម្រើការងារនោះមន្ទីរស-២១ ហ្នឹង មានគ្នាចំនួនប៉ុន្មាននាក់?

**ឆ៖** ពេទ្យនៅស-២១ កាលពីមុន ខ្ញុំមកទាន់ហ្នឹងមានមនុស្សធំៗផ្លាស់ច្រើនដែរ ប៉ុន្តែពេលនោះគេចាប់អស់ទៅ ។ ដូចយ៉ាងមេក្រុមខ្ញុំឈ្មោះ ប៉ោ ឈ្មោះអី ចាប់អស់ហើយ ។

**ស៖** លោកថាច្រើននុ៎ង ទាំងអស់ប្រហែលប៉ុន្មាននាក់ដែលលោកមកទាន់នោះ?

**ឆ៖** ខ្ញុំមកទាន់ឃើញមនុស្សមេៗក្រុមខ្ញុំនោះពីរនាក់ធំៗ ។

**ស៖** លោកស្គាល់ឈ្មោះអ្នកទាំងពីរនុ៎ងដែរឬទេ?

**ឆ៖** ឈ្មោះទាំងពីរខ្ញុំស្គាល់ ឈ្មោះ ប៉ោ ឈ្មោះ យឺន ។

**ស៖** ចុះកុមារពេទ្យដែលមកជាមួយលោកហ្នឹង មានគ្នាប៉ុន្មាននាក់ទៅ?

**ឆ៖** កុមារពេទ្យដែលមកនៅជាមួយ មកជាមួយខ្ញុំមានគ្នាបួននាក់ មានឈ្មោះ ធីម ឈ្មោះ ម៉ុន ឈ្មោះ ហូរ។

**ស៖** ចុះក្នុងចំណោមកុមារពេទ្យ ឬក៏ពេទ្យនៅមន្ទីរស-២១ មានពេទ្យជានារី ឬក៏ស្ត្រីដែរឬទេ?

[០៩:២៩:៥៦]

**ឆ៖** នៅស-២១ មានពេទ្យប្រុសៗពីរនាក់ បងប៉ោ, បងយឺន ។

**ស៖** មានពេទ្យស្រីដែរឬទេ?

**ផ៖** អត់មានពេទ្យស្រីទេ ។

**ស៖** ចុះលោកមកធ្វើការនៅមន្ទីរស-២១ ហ្នឹង លោកដឹងទេថាអ្នកណាជាអ្នកគ្រប់គ្រងនៅមន្ទីរ ស-២១ នេះ?

**ផ៖** អ្នកគ្រប់គ្រងនៅស-២១ មានតែឈ្មោះ ឌុច នុ៎ងហើយជាមេ ។

**ស៖** លោកស្គាល់ លោក ឌុច ហ្នឹងច្បាស់ដែរឬទេ?

**ផ៖** ខ្ញុំអស់សូវស្គាល់ច្បាស់ទេ ខ្ញុំឃើញដើរម្តងៗ ប៉ុន្តែខ្ញុំមើលឆ្ងាយអត់សូវច្បាស់មនុស្ស ខ្ញុំអស់ស្គាល់ព្រោះខ្ញុំតូច អស់សូវប៉ានមើលគេទេ ព្រោះគេមេអ្នកណាប៉ានមើលមុខសម័យនោះ ។

**ស៖** ចុះក្រៅពី ឌុច ហ្នឹង លោកមានដែលស្គាល់ ធ្លាប់ស្គាល់អ្នកដឹកនាំអ្នកគ្រប់គ្រងមន្ទីរស-២១ ផ្សេងទៀតដែរឬទេ?

**ផ៖** អ្នកដឹកនាំក្រោមៗខ្ញុំអត់មានស្គាល់ទេ ស្គាល់តែមេនុ៎ងមួយហើយ ។

**ស៖** លោកអាចថា លោកដើរចែកថ្នាំអ្នកជំងឺ អ្នកទោសដែលមានជំងឺ តើលោកអាចរៀបរាប់ប្រាប់យើងបានទេ អំពីស្ថានភាពនូវការឃុំខ្លួនអ្នកទោសនៅក្នុងអគារដែលលោកដើរចែកថ្នាំហ្នឹង តើលោកពិនិត្យឃើញស្ថានភាពនៃការឃុំខ្លួននោះយ៉ាងដូចម្តេចខ្លះ?

**ផ៖** ឃើញ កាលឃុំខ្លួនហ្នឹង ឃើញមានដំបៅ ក្រចកដៃ ពិសេសខ្នងដែលវ៉ៃសួរចម្លើយ រួចជាអ្នកទោសដែរតដៃ មានតែអ្នកយាមមានមានតែមេៗគេ គេមេអ្នកយាមគេហៅមកចាប់មកធ្វើទារុណ-កម្មដាក់ខ្នោះ ជាខ្នោះដៃ ខ្នោះជើងពីរ បើអ្នកអត់សូវធ្វើសកម្មភាពគេដាក់ខ្នោះជើងមួយ ។

**ស៖** ពេលលោកថា ដាក់ខ្នោះដៃខ្នោះជើងហ្នឹង តើនៅក្នុងបន្ទប់នីមួយៗហ្នឹងមានគេឃុំខ្លួនអ្នកទោសនុ៎ងប្រហែលប៉ុន្មាននាក់ទៅក្នុងបន្ទប់មួយៗ?

**ផ៖** បន្ទប់មួយៗ បើបន្ទប់ខាងលើដែលអ្នកទោសតូចៗដឹងឃើញគេដាក់ច្រើនៗណាស់ ដោតដូចត្រណោតអ៊ីចឹង ។

[០៩:៣៣:០៥]

**ស៖** លោកដើរចែកហ្នឹង ភាគច្រើននៃអ្នកជំងឺហ្នឹង អ្នកទោសហ្នឹងឈឺអីទៅ?

**ផ៖** អ្នកទោសភាគច្រើនជំងឺមិនសូវឈឺប៉ុន្មានទេ ដូចរាគ ដូចគ្រុញ ឈឺក្បាលអី ច្រើនតែរបួសខ្នង របក បាត់ក្រចកដៃក្រចកជើង ។

**សៈ** អ៊ីចឹង បានន័យថា អ្នកទោសដែលលោកព្យាបាលហ្នឹង ភាគច្រើនមិនមែនឈឺដោយជំងឺផ្សេងៗទេ ភាគច្រើន គឺដោយសារថារងរបួស ដោយសារថារងអំពើទារុណកម្ម ។ អ៊ីចឹងមែនទេ?

**ផៈ** ភាគច្រើនមែន ច្រើនប្រើទារុណកម្មហ្នឹងហើយ អត់សូវមានជំងឺប៉ុន្មានដែលទេ ច្រើនធ្វើទារុណកម្មហ្នឹង ។

**សៈ** ចុះគេឲ្យថ្នាំអីខ្លះទៅ ដល់អ្នកទោសហ្នឹង?

**ផៈ** អ្នកទោស ដល់តែពេលឈឺរាគ ឲ្យថ្នាំរាក ។ ច្រើនរបួសឲ្យថ្នាំរបួស ប៉ុន្តែថ្នាំនុ៎ង ថ្នាំអាចម៍ទន្សាយធ្វើនៅស្រុកខ្មែរហ្នឹង ។

**សៈ** អ្នកដែលរងរបួស តើមានការព្យាបាលដោយលាងរបួសអីដែរឬទេ?

**ផៈ** មានលាងរបួស លាងនឹងទឹកអំបិលដើម្បីឲ្យសះរបួស ឲ្យជំងឺនោះជា ជួនកាលជាអត់ទាំងទាន់ផង ដល់ម៉ោង ដល់ពេល គេត្រូវយកបាត់ ដល់ខែគេ ។

**សៈ** ត្រឡប់ទៅក្រោយបន្តិច។ លោកពេលដែលលោកមកនៅមន្ទីរស-២១ ហ្នឹង លោករស់នៅខាងក្នុងបរិវេណមន្ទីរតែម្តង ឬក៏នៅខាងក្រៅ?

**ផៈ** ខ្ញុំនៅផ្ទះសសរចាក់បេតុង ផ្ទះឈើដែលមានប្រហុកនៅពីក្រោមនុ៎ង កូនពេទ្យនៅហ្នឹង ។

**សៈ** ផ្ទះនុ៎ងនៅចាំត្រង់ណាដែរ? ទីតាំង?

**ផៈ** ខាងកើតជ្រុងខាងជើង ផ្លូវប៉ុន្មាននេះ ខ្ញុំមិនសូវស្គាល់ដែរ ចិតសិបអីណានុ៎ង ប៉ុន្តែជ្រុងផ្លូវខាងជើងផ្ទះមាត់ច្រកគុកចូលនុ៎ង ។

**សៈ** ផ្ទះនុ៎ងសង់ពីអីទៅ?

**ផៈ** ពីក្រោមចាក់បេតុង ខាងលើឈើ ។

**សៈ** អ៊ីចឹងបានន័យថា ផ្ទះខាងក្រោមថ្ម ខាងលើឈើ ។ អ៊ីចឹងមែនទេ?

**ផៈ** អ៊ីចឹងមែនហើយ ផ្ទះពីក្រោមចាក់បេតុង ពីលើឈើ អ៊ីចឹងមែន ។

**សៈ** លោកបានអះអាងថា អ្នករងរបួស-- លោកព្យាបាលអ្នកទោស ដែលភាគច្រើនជាអ្នករងរបួស ហើយរបួសនោះដោយសារថាការធ្វើទារុណកម្ម មានដំបៅខ្នង មានដកបាត់ក្រចកដៃ ក្រចកជើង ។ អ៊ីចឹង តើលោកធ្លាប់ដែលឃើញគេធ្វើទារុណកម្មទៅលើអ្នកទោសដែរឬទេ?

**ផៈ** ខ្ញុំអត់ដែលបានឃើញ ដែលផ្ទាល់ ដែលគេយកទៅសួរចម្លើយទេ ក្រុមគេផ្សេងទេ ពួកអ្នកសួរចម្លើយផ្សេង ពួកអ្នកយាមផ្សេង កូនពេទ្យផ្សេង ផ្សេងៗពីគ្នា ។ ខ្ញុំបានតែមើលនៅក្នុងអគារ ។

**ស៖** អ៊ីចឹងកន្លែងអ្នកសួរចម្លើយ ដែលគេយកទៅសួរ នៅឯណាទៅ?

**ឆ៖** គេយកទៅតាមកន្លែងអង្គភាពគេផ្សេងៗ តាម "គ" តាមក្រុមគេផ្សេង ។ បងៗ គេយកផ្សេងសម្រាប់ខ្ញុំកុមារពេទ្យនៅមើលតែអគារទេ ។

**ស៖** ចុះយ៉ាងម៉េចទៅបានជាលោកដឹងថា ការរងរបួសហ្នឹង ដោយសារថាគេធ្វើទារុណកម្ម?

**ឆ៖** ខ្ញុំដឹងឮថា យប់ឡើងមានស្រែក មានដំបៅ រួចខ្ញុំអ្នកព្យាបាល ខ្ញុំដឹង ខ្ញុំលបសួរតិចៗថា អាម៉េចបានដំបៅម្ល៉ឹងៗ? គេថា សួរចម្លើយ អ្នកទោសថា សួរចម្លើយ ។

**ស៖** អ៊ីចឹងលោកដឹងហ្នឹង ដោយសារតែការដែលលោកសួរទៅអ្នកទោស ។ អ៊ីចឹងមែនទេ?

**ឆ៖** សួរ ដោយខ្ញុំសួរអ្នកទោសថា មូលហេតុដែលដឹងៗដោយសារសួរអ្នកទោស ព្រោះខ្ញុំអ្នកព្យាបាលហ្នឹង ដំបៅវាច្រើនពេក ខ្ញុំលាងរបួស លាងអីទុំង នៅកន្លែងអស់ហ្នឹង ។

**ស៖** ចុះលោកថា ធ្លាប់ព្យាបាល ដើរចែកថ្នាំតែអ្នកទោស ចុះលោកមានដែលព្យាបាលបុគ្គលិកមន្ទីរស-២១ ដែលមានជំងឺដែរឬទេ?

**ឆ៖** បើគេឈឺសុំថ្នាំ ខ្ញុំទៅ-- ខ្ញុំឲ្យថ្នាំគេដែរ ។

**ស៖** ចុះថ្នាំរបស់អ្នកជំងឺដែលជាអ្នកទោស ហើយនិងថ្នាំរបស់បុគ្គលិកមន្ទីរស-២១ គេប្រើប្រាស់ថ្នាំដូចគ្នា ឬក៏យ៉ាងម៉េច?

**ឆ៖** ជួនកាលជំងឺនេះទៅដូចគ្នា ជួនកាលជំងឺណាដែលធ្ងន់ទៅខុសគ្នាទៅថ្នាំ ។

**ស៖** ត្រឡប់មកកុមារពេទ្យ ដែលលោករៀបរាប់អម្បាញ់មិញវិញ ។ តើលោកអាចរាប់រៀបឈ្មោះកុមារពេទ្យទាំងបួននាក់ឡើងវិញបានឬទេ? ឈ្មោះអីខ្លះទៅ?

**ឆ៖** ខ្ញុំអាចរាប់បានកុមារពេទ្យទាំងបួននាក់ មានឈ្មោះ ម៉ុន, ឈ្មោះ ហួរ, ឈ្មោះ ធីម និងឈ្មោះខ្ញុំ ជន ។

[០៩:៣៩:៥៧]

**ស៖** លោកបានរៀបរាប់ថា មានពេទ្យហ្នឹងឈ្មោះ ម៉ុន ។ តើ ម៉ុន នោះជាស្រី ឬប្រុស?

**ឆ៖** ម៉ុន នោះប្រុស កុមារដែលនៅជាមួយគ្នា ដែលគេយកមកទាំងបួននាក់ ។

**ស៖** អ៊ីចឹង ម៉ុន ហ្នឹងមកពីស្រុកភូមិជាមួយលោកដែរ? មកពីខាងកំពង់ឆ្នាំងហ្នឹង? អ៊ីចឹងមែនទេ?

**ឆ៖** មកពីខាងកំពង់ឆ្នាំហ្នឹង ស្រុកភូមិជាមួយគ្នា ។

**ស៖** ហើយជាប្រុសណា?

**ឆ៖** បាទ ។

**ស៖** នៅពេលដែលលោកធ្វើនៅមន្ទីរស-២១ហ្នឹង តើលោកធ្លាប់បានឃើញគេនាំអ្នកទោសចេញទៅសួរចម្លើយ ឬក៏យកទៅណាទៀតទេ?

**ឆ៖** យកទៅ-- គេយកអ្នកទោសទៅសួរចម្លើយ សួរនៅពេលថ្ងៃ ។ ដល់ថា ខ្ញុំចេះតែប្លែកថា ចុះបាត់អាចាស់ទៅណាអស់ ចេញអាថ្មីមកទៀត មនុស្សមុនដំបូងមកអត់មានរបួសទេ ។ ដល់ចុងក្រោយចេះតែរបួសច្រើន ហើយខ្ញុំចេះតែលាង ខ្ញុំចេះតែឆ្ងល់អ៊ីចឹង ចុះបាត់អាចាស់ទៅណាអស់ទៅ? រួចយប់ឡើងបាត់ហើយ ព្រឹកឡើងខ្ញុំទៅព្យាបាលបាត់ហើយ ។

**ស៖** អ៊ីចឹង មានការបាត់អ្នកទោសអ៊ីចឹង អ្នកទោសលោកដឹងទេថា ចាប់ពីពេលដែលអ្នកទោសចូលមកថ្មីរហូតទៅដល់គេ លោកព្យាបាលរហូតដល់ពេលដែលបាត់អ្នកទោសនោះ រយៈពេលឃុំខ្លួនគាត់នៅក្នុងមន្ទីរឃុំខ្លួនហ្នឹង រយៈពេលប្រហែលប៉ុន្មានទៅ បានបាត់គាត់?

**ឆ៖** ខ្លះក៏យូរ ខ្លះក៏ឆាប់ ចង់មួយខែ ខ្លះក៏ពីរខែ ខ្លះក៏បីខែ អ៊ីចឹង តាមចម្លើយ តាមខ្សែរយៈអីណាគេ ខ្ញុំអត់ច្បាស់អារឿងអ្នកសួរ ខ្ញុំអត់ចេះនិយាយអាហ្នឹង ។

**ស៖** តើលោកដឹងទេថា នៅក្នុងបរិវេណមន្ទីរស-២១ និយាយឲ្យចំ និយាយនៅក្នុងអាបរិវេណសាលាហ្នឹងតែម្តង តើមានកន្លែងសួរចម្លើយនៅក្នុងហ្នឹងដែរឬទេ?

**ឆ៖** ក្នុងមន្ទីរស-២១ អត់ដែលឃើញមានអាកន្លែងសួរចម្លើយនៅក្នុងហ្នឹងទេ មានចេញ គេដកយកចេញទៅក្រៅទេ អត់មានសួរនៅក្នុងហ្នឹងទេ ។

**ស៖** ចុះនៅកន្លែងឃុំខ្លួន ដែលលោកធ្វើការចែកថ្នាំឲ្យដល់អ្នកទោសហ្នឹង មានអ្នកទោសជាស្ត្រីដែរឬទេ?

[០៩:៤២:៥២]

**ឆ៖** អ្នកទោសភាគច្រើនឃើញតែប្រុស អត់សូវមានឃើញស្ត្រី ខ្ញុំអត់ដែលឃើញទេស្ត្រី ។

**ស៖** ចុះលោកមានធ្លាប់ដែលឃើញអ្នកទោសដែលជាជនជាតិបរទេសដែរឬទេ? ជនជាតិបស្ចិមប្រទេស ឬក៏វៀតណាម?

**ឆ៖** ជនជាតិបរទេសខ្ញុំអត់ឃើញទេ ព្រោះផ្ទះគេដាក់ផ្សេងពីគ្នា មានផ្ទះលេខមួយ លេខពីរ លេខបី ផ្ទះលេខបីអត់មានជនបរទេសទេ ។

**ស៖** ចុះការឃុំខ្លួនអ្នកទោសហ្នឹង តើរបបអាហារ គេឲ្យអ្នកទោសហូបចុកយ៉ាងម៉េចដែរ?ហូបអីទៅ?

**ឆ៖** ការហូបចុកមានតែបបរទេ មួយចានៗម្នាក់ ។ អ្នកដែល ដូចថាធ្វើការក្នុងកន្លែងហ្នឹងមានការគ្រោះថ្នាក់អី វាឲ្យរែកបាយយកទៅចែកអ្នកទោសហ្នឹង ។

**ស៖** នៅក្នុងអំឡុងពេលដែលលោកធ្វើការនោះ  តើលោកមានធ្លាប់ដឹងគេយកអ្នកទោសទៅបូមឈាមដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលមានឃើញយកទោសទៅបូមឈាម ខ្ញុំអត់ដែលឃើញ ។

**ស៖** ចុះការធ្វើពិសោធន៍វេជ្ជសាស្ត្រផ្សេងៗទៅលើអ្នកទោស  ធ្លាប់មានទេនៅក្នុងមន្ទីរស-២១? លោកដឹងទេ?

**ឆ៖** ខ្ញុំពេទ្យកុមារអត់ដឹងផង ធំៗប្រហែលគេដឹងមើលទៅ ។

**ស៖** លោកធ្លាប់ថា នៅក្នុងនុំងមានពេទ្យធំៗមួយចំនួន ហើយក្រោយមកលោកបានថា គេចាប់ពួកពេទ្យធំៗទាំងនោះទៅបាត់ ។  ថាតើលោកដឹងទេ  ថាគេចាប់ពេទ្យធំៗចាស់នោះទៅដោយមូលហេតុអី? ឬក៏គេមានកំហុសអី?

**ឆ៖** ពេទ្យ-- ចាប់ពេទ្យធំៗកាលនោះ  មានកំហុសដូចថា  ចាក់ថ្នាំប្រតិកម្ម  ឬក៏ឲ្យថ្នាំគេលេបប្រតិកម្មអី គេថាខ្មាំង ។

**ស៖** ចុះដឹងទេថា តើអ្នកណាជាអ្នកបញ្ជាក្នុងការចាប់ខ្លួនពេទ្យចាស់ៗនោះ?

**ឆ៖** ខ្ញុំថាមានតែឈ្មោះ ឌុច ហ្នឹង ឲ្យចាប់តែពេទ្យចាស់ៗ ពេទ្យធំៗ មុនពេលចាប់ពីយប់ ព្រឹកឡើងស្រាប់តែបាត់អស់ បងៗធំៗ ។

[០៩:៤៦:០៦]

**ស៖** ថាតើលោកនៅក្នុងមន្ទីរស-២១ ហ្នឹង ដល់ពេលណាទៅ?

**ឆ៖** ខ្ញុំនៅ ស-២១ ដល់ពេលរត់ ដល់ពេលផ្ទុះអារុធរត់ ។

**ស៖** បានន័យថា លោកនៅក្នុងមន្ទីរស-២១ នេះរហូតដល់ថ្ងៃទី៦ ទី៧ មករា ឆ្នាំ៧៩ ។ អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែន ដល់ថ្ងៃ៦ ថ្ងៃ៧ បានរត់ ផ្ទុះអាវុធ ខ្ញុំរត់ចេញអស់ទៅ បែកគ្នី បែកគ្នាអស់ទៅ ។ ព្រោះខ្ញុំតូចទៅមុន ទៅថ្ងៃជាមួយគ្នាដែរ ប៉ុន្តែថយមុន គេធំៗនៅក្រោយ ។

**ស៖** អ៊ីចឹងបានន័យថា លោករស់នៅក្នុងមន្ទីរស-២១ នេះប្រហែលជាមួយឆ្នាំ ។ អ៊ីចឹង តើក្នុងរយៈពេលដែលលោកនៅក្នុងមន្ទីរស-២១ មួយឆ្នាំហ្នឹង លោកដែលចូលរួមវគ្គបង្រៀនរៀនសូត្រនយោបាយអីផ្សេងៗដែរឬទេ?

**ឆ៖** ការរៀននយោបាយធំៗ ខ្ញុំអត់ដែលចូលវគ្គធំទេ ។

**ស៖** ចុះវគ្គប្រជុំជាក្រុមតូចនោះ លោកដែលធ្លាប់ទេ?

**ឆ៖** បើប្រជុំក្រុមតូចៗ និងប្រជុំពួកបី ខ្ញុំចូលរួមទិតៀនគ្នា កសាង ។

**ស៖** ខ្លឹមសារនៃការប្រជុំនោះ យ៉ាងម៉េចទៅ? គេនិយាយអំពីអីខ្លះទៅ?

**ឆ៖** ប្រជុំគេនិយាយអំពីការអនាម័យ គេនិយាយអំពីការថែទាំ ពេលវេលាធ្វើការខុសម៉ោង អត់ទាន់ពេលទាន់វេលា ។

[០៩:៤៨:០០]

**ស៖** នៅក្នុងរយៈពេលដែលលោកព្យាបាលអ្នកទោសនៅទីនោះ តើលោកធ្លាប់បានឃើញអ្នកទោសឈឺស្លាប់នៅក្នុងកន្លែងឃុំខ្លួនដែរឬទេ?

**ឆ៖** មានអ្នកទោសឈឺស្លាប់ក្នុងនុំងមាន ធ្លាប់ឃើញ ។

**ស៖** ក្នុងរយៈពេលលោកធ្វើការនុំងមានអ្នកឈឺស្លាប់នុំងចំនួនប្រហែលប៉ុន្មានអ្នកទៅ?

**ឆ៖** កាលខ្ញុំធ្វើការនុំងមានអ្នកដែលឈឺស្លាប់នៅក្នុងនុំង មានច្រើនណាស់រាប់ទៅប្រហែលជារាប់រយហើយ ។

**ស៖** ហើយគេធ្វើយ៉ាងម៉េចទៅចំពោះសាកសពដែលស្លាប់នោះ?

**ឆ៖** សាកសពនុំងគេឲ្យកូនពេទ្យ ឲ្យពេទ្យសែងជញ្ជូនចេញយកមកកប់នៅក្រៅ ឬក៏កប់ជិតៗកន្លែងនុំងឲ្យតែផុតទៅ ។

**ស៖** លោកស្គាល់ទីតាំងដែរ? តើកប់នៅត្រង់ណាទៅ?

**ឆ៖** កប់នៅខាងលិចអគារ កប់នៅជុំតែវិញ មួយៗ ដែលអ្នកឈឺស្លាប់មួយៗ ។

**ចៅក្រម ធូ មណី៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម មានសំណួរអ្វីសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។

**ស៖** សេក ដន តើលោកមានដឹងទេថាអ្វីទៅជាថ្នាំដែលលោកបានប្រគល់ទៅឲ្យអ្នកទោស ឬក៏បុគ្គលិករបស់ ស-២១ នោះ?

[០៩:៥០:២២]

**ឆ៖** ថ្នាំនោះ គឺថ្នាំធ្វើនៅស្រុកខ្មែរយើងហ្នឹង គេហៅថា អាថ្នាំអាចម៍ទន្សាយ ពណ៌វាខ្មៅៗ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងថ្នាំអាចម៍ទន្សាយហ្នឹង តើត្រូវបានគេប្រើប្រាស់ជាធម្មតាឬ នៅក្នុងប្រទេសកម្ពុជា មុនរបបខ្មែរក្រហមនោះ?

**ឆ៖** ថ្នាំហ្នឹង គេទើបតែនឹងស្លថ្នាំ-- ក្រោយពីឆ្នាំ៧៥ ហ្នឹងឯង ។

**ស៖** តើលោកដឹងទេថា ថ្នាំអាចម៍ទន្សាយនោះធ្វើអំពីអ្វីដែរ?

**ឆ៖** ថ្នាំអាចម៍ទន្សាយៗហ្នឹង ខ្ញុំអត់ដែលបានធ្វើទេ ប៉ុន្តែគេឲ្យ-- គេបញ្ជូនមកសម្រាប់ចែកតាមជំងឺ ដឹងគេស្លនៅឯណាទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំអត់មានសំណួរអ្វីសម្រាប់សាក្សីនេះទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អស់លោកចៅក្រម--

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើលោកអាចប្រាប់យើងបានទេ ថាតើមានថ្នាំពេទ្យអ្វីខ្លះសម្រាប់លោកចែកចាយនោះ? តើប្រភេទថ្នាំនោះមានអ្វីខ្លះដែលលោកចែកឲ្យអ្នកជំងឺនោះ?

**ឆ៖** ដែលចែកឲ្យអ្នកជំងឺប្រភេទថ្នាំ មានថ្នាំរបួស ថ្នាំរាគ ថ្នាំគ្រុន ថ្នាំឈឺក្បាល ។

**ស៖** ថ្នាំទាំងអស់នុ៎ង តើថ្នាំទាំងអស់សុទ្ធជាថ្នាំអាចម៍ទន្សាយទាំងអស់ ឬក៏ជាប្រភេទថ្នាំផ្សេងៗទៀតក្រៅពីប្រភេទថ្នាំអាចម៍ទន្សាយនោះ?

**ឆ៖** មានថ្នាំផ្សេងលាយខ្លះដែរ សម្រាប់ធំៗដែលខ្ញុំមើលទៅថ្នាំដូចខុសប្លែកដូចខុសគ្នា ។

**ស៖** តើថ្នាំហ្នឹងត្រូវបានគេធ្វើនៅស្រុកខ្មែរយើង ឬក៏យកនាំចូលមកពីបរទេស?

**ឆ៖** ថ្នាំហ្នឹងបើតាមខ្ញុំសន្មត ខ្ញុំខាំមើល ខ្ញុំហូបទៀត គឺកាលដែលខ្ញុំឃ្លានបាយពេក ខ្ញុំហូបទៅជូរអែមៗដូចថ្នាំកម្លាំងអី ត្រូវថ្នាំរាកហ្នឹងចត់ៗខ្ញុំថា សំបកឈើសំបកព្រៃហ្នឹងហើយមើលទៅ ថ្នាំធ្វើក្នុងស្រុកហ្នឹងហើយមើលទៅ ។

[០៩:៥៣:៥១]

**ស៖** តើថ្នាំនោះមានឥទ្ធិពលទេ? ហើយពិតជាព្យាបាលបានមែន ឬក៏វាអត់មានឥទ្ធិពលអ្វីទេ? វាអត់ស័ក្តិសិទ្ធិទេ?

**ឆ៖** ថ្នាំនោះ វាអាចព្យាបាលបានខ្លះ មិនពូកែខ្លះ ពូកែខ្លះ ខ្លះអត់ពូកែ ដូចអស់ស្ងួវមានស័ក្តិសិទ្ធិរហូតដល់ខ្ញុំហូបមួយដៃអី អត់អីដែរ ដែលឃ្លានបាយពេក ។

**ស៖** លោកបាននិយាយថា លោកបានសម្គាល់ឃើញថាអ្នកទោសអស់ទាំងហ្នឹង គាត់មានរបួសជាច្រើន តើលោកអាចរៀបរាប់ឲ្យបានពិស្តារទៀតទេថា របួសនោះជារបួសប្រភេទណាដែរ ដែលអ្នកទោសគាត់មាន? តើរបួសហ្នឹងរបួសនៅលើកន្លែងណាខ្លះដែរនៅលើរាងកាយរបស់អ្នកទោសនោះ?

**ឆ៖** ប្រភេទរបួសច្រើនដូច ខ្ញុំរៀបរាប់កាលមុន ភាគច្រើននៅខ្នង នៅដៃ នៅជើង ។

[០៩:៥៥:៣៣]

**ស៖** តើលោកមានឃើញស្នាមរលាក ឬក៏ស្នាមដែលត្រូវបានគេអុជអីនៅលើរាងកាយរបស់អ្នកទោសទេ? ឬក៏ស្នាមជាំដែលបណ្តាលមកពីការឆក់ខ្សែភ្លើងជាដើម តើលោកមានធ្លាប់ឃើញស្នាមបែបនេះទេ?

**ឆ៖** ស្នាមជាំខ្ញុំធ្លាប់ឃើញ ខ្ញុំមាន ខ្ញុំសួរទៀត ។ ខ្ញុំដែលខ្ញុំព្យាបាល មានស្នាមជាំ មានស្នាមបែក មានស្នាមឈាមគ្រប់សព្វនិយាយអត់ចង់កើតទេ ច្រើនមុខ គ្រប់ប្រភេទ ។

**ស៖** តើលោកមានបានឃើញស្នាមជាំ ដែលមាននៅលើត្រចៀករបស់អ្នកទោសទេ?

**ឆ៖** ត្រចៀកខ្ញុំធ្លាប់ឃើញ ត្រចៀកជួនកាលដាច់ផែក ជួនកាលដំបៅ ដែលខ្ញុំធ្លាប់ព្យាបាល ។

**ស៖** តើមានអ្នកទោសណាដែលមានស្នាមជាំនៅក្បែរប្រដាប់ភេទរបស់គេទេ?

**ឆ៖** ប្រដាប់ភេទខ្ញុំអត់ដែលឃើញទេ ព្រោះសុទ្ធតែស្លៀកខោស្លៀកអីដែរ ។ ស្លៀកតែខោខ្លីអត់មានស្លៀកពាក់អាវពាក់អីទេ ។

**ស៖** តើលោកមានបានសួរអ្នកទោសអស់ទាំងនុ៎ងទេ ថាតើពួកគេហ្នឹងហេតុអ្វីបានជាគេត្រូវបានគេធ្វើបាបហ្នឹងមកពីគេសួរចម្លើយទៅ ហើយគាត់ហ្នឹងមិនឆ្លើយតប? ហើយថាតើមានអ្នកទោសណាដែលថាគេទុកចិត្តទៅលើលោក ហើយប្រាប់ថា ពួកគេត្រូវបានគេធ្វើទារុណកម្មដោយឧបករណ៍អ្វីនោះទេ?

[០៩:៥៨:២៣]

**ឆ៖** ខ្ញុំអត់ដែលបានសួរឲ្យជ្រៅ ឲ្យឆ្ងាយទេ ខ្លាចគេឃើញ អ្នកយាមគេឃើញខ្ញុំអាចស្លាប់ ។

**ស៖** អ៊ីចឹង គឺថាលោកមិនអាចសួរសំណួរបានទេ ។ តើលោកមានបានសួរគាត់ថា គាត់ឈឺកន្លែងណាទេ? ហើយដែលសួរថា ហេតុអ្វីបានជាគាត់ឈឺនៅកន្លែងផ្នែកណាមួយនៃរាងកាយរបស់គាត់នោះ?

**ឆ៖** ខ្ញុំធ្លាប់តែសួរថា ឈឺអី? ហុចតែថ្នាំ សួរឈឺហុចៗ អត់មាននិយាយគ្នាអីឲ្យបានយូរទេ ខ្លាចទាក់ទងអ្នកទោសថា នាំបះបោរ ហើយជាប់គុក ។

**ស៖** លោកមានការភ័យខ្លាច ។ តើលោកមានការភ័យខ្លាចហ្នឹងជាប្រចាំរហូតឬ? លោកបាននិយាយថា មានមនុស្សធំៗហ្នឹងត្រូវបានគេចាប់ខ្លួន តើលោកអាចប្រាប់បានទេថា លោកមានបានដឹងថាបុគ្គលិកដែលធ្វើការនៅផ្នែកពេទ្យហ្នឹង ដែលថាពួកគេហ្នឹងដែលមានបំណងធ្វើអត្តឃាតខ្លួនឯង ឬក៏យ៉ាងម៉េចទេ?

**ឆ៖** ដែលធ្វើអត្តឃាតខ្លួនឯងរហូតដល់ភ័យរហូតដល់ចងកស្លាប់ដូច បងយឺន អី ។ គាត់ជាមេខ្ញុំជាអនុក្រុមខ្ញុំនុ៎ងឯង ។ មេក្រុមចូលថ្មី ។

[១០:០០:២៦]

*(អ្នកបកប្រែ៖ សូមអភ័យទោសដោយសារចៅក្រម-- សូមមេត្តាចៅក្រមបញ្ជាក់ឡើងវិញ)*

**ស៖** តើលោកនៅចងចាំទេ ដែលថាលោកបានដឹងពីរឿងនោះៗ? ពីរឿងដែលថាអ្នកទោសចងកនោះ?

**ធ៖** ដែលថា អ្នកទោសចងកខ្ញុំអាចដឹងព្រោះនៅក្នុងក្រុមខ្ញុំនុ៎ងហើយ មេខ្ញុំនុ៎ងហើយកាលមុនគាត់ភ័យពេក ខ្លាចស្លាប់ដូច បងប៉ោ មុនអ៊ីចឹង ។ ព្រោះគេចាប់មេមុនឈ្មោះ ប៉ោ ហ្នឹង គេចាប់អារឿងខុសអ៊ីចឹងដល់គាត់ភ័យ មូលហេតុដែលគាត់ខុសគាត់ចាកថ្នាំអ្នកទោសនុ៎ងមានការស្លាប់ មានការគ្រោះថ្នាក់ប្រតិកម្ម ។

**ស៖** នៅក្នុងកិច្ចប្រជុំទិតៀន ស្វ័យទិតៀននោះបើសិនជាមានការអ្នកណាធ្វើមិនបានល្អត្រឹមត្រូវថាតើមានរឿងអ្វីកើតឡើង? ហើយការប្រជុំនោះច្រើនតែនិយាយពីរឿងអ្វីខ្លះដែរ?

**ធ៖** ការប្រជុំផ្នែកអង្គភាពពេទ្យខ្ញុំមានតែនិយាយពីរឿងអានាម័យ និងគោរពម៉ោងពេលវេលាបើកសាងហើយមិនធ្វើតាមមានតែដកចេញ ។

**ស៖** នៅពេលដែលលោកនិយាយថា ដកចេញនោះតើមានន័យថាដូចម្ដេច? តើមានន័យថា គេចាប់ទៅ?

**ធ៖** ខ្ញុំថា ដកចេញហ្នឹង គឺគេចាប់ទៅហ្នឹង ។

[១០:០៣:១៦]

**ស៖** តើអ្នកដែលគេដកចេញទៅ គេជួបបញ្ហាអ្វីដែរ តើធ្លាប់ឃើញអ្នកនោះមកវិញដែរឬទេ?

**ធ៖** អ្នកដែលគេដកចេញយកទៅមិនដែលឃើញមកវិញទេ ។

**ស៖** តើគេប្រាប់លោកថាម៉េចដែរ អំពីអ្នកទោសដែលគេប្រាប់ថាកុំឲ្យនិយាយទៅរកអ្នកទោស ឬក៏កុំឲ្យសាកសួរអ្នកទោសច្រើន តើលោកព្យាបាលអ្នកទោស ឬក៏លោកគ្រាន់តែទុកឲ្យគេនៅរស់ ឬក៏គ្រាន់តែឲ្យថ្នាំព្យាយាមឲ្យគេនៅរស់តែប៉ុណ្ណឹង?

**ធ៖** ឲ្យថ្នាំគ្រាន់តែបាន ពេលដែលគេសួរចម្លើយចប់ហើយ គេយកទៅបាត់ គេគ្រាន់តែដូចបណ្ដោះអាសន្នអ៊ីចឹង ។

**ស៖** ដូច្នេះ តើបញ្ហា តើលោកទទួលបញ្ហាពីអ្នកណា? ពី ឌុច ឬក៏អ្នកណាដែលថាគ្រាន់តែព្យាបាលឲ្យនៅរស់រហូតទាល់តែសួរចម្លើយចប់ ហើយចាំឈប់ព្យាបាល តើលោកទទួលការណែនាំហ្នឹងពីអ្នកណា?

**ធ៖** ខ្ញុំអត់ដែលបានមានទទួលពាក្យអស់ហ្នឹង ប៉ុន្តែខ្ញុំឃើញតែព្យាបាល ឲ្យតែគេសួរចម្លើយហើយ យូរហើយ ចប់ហើយ តែបាត់មនុស្សខ្ញុំដឹងថា គេយកចេញបាត់ហើយ ព្រោះខ្ញុំដឹងថា ខ្ញុំព្យាបាលរាល់ថ្ងៃ ខ្ញុំដឹងថាមនុស្សហ្នឹងធ្លាប់នៅ ដល់ពេលបាត់ មានអាថ្មីមកទៀត បាត់អាចាស់បាត់ហើយ ។

**ស៖** តើលោកបានឃើញជនជាប់ចោទបានវត្តមាននៅក្នុងបន្ទប់សវនាការនេះទេ? តើលោកបានឃើញគាត់នៅពេលដែលលោកធ្វើការជាកុមារពេទ្យនោះដែរឬទេ? តើលោកស្គាល់គាត់ទេ រហូតមកដល់ពេលនេះ?

**ឆ៖** បានឃើញ ។

**ស៖** ឆ្លើយតបទៅនឹងសំណួរដោយលោកចៅក្រម ធូ មណី លោកនិយាយថា លោកមិនដែលបានហានមើលមុខគាត់ទេ តើថ្ងៃនេះលោកនៅតែខ្លាចគាត់ទេ ឬយ៉ាងម៉េច?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំដែលធំហើយ ខ្ញុំលែងសូវខ្លាចហើយ ព្រោះសង្គមគេក៏ផ្លាស់ប្តូរដែរ បច្ចុប្បន្ននេះខ្ញុំអត់មានខ្លាចទេ ។

**ស៖** លោកបានចាកចេញពីគ្រួសារពីអាយុ១៤ឆ្នាំ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាកចេញពីគ្រួសារមកនៅភ្នំពេញនេះ អាយុ១១ឆ្នាំ ។

**ស៖** ១១ឆ្នាំ តើក្រុមគ្រួសារអនុញ្ញាតឲ្យលោកចាកចេញទេ តើលោកសម្រេចថាមិនចាកចេញបានទេ ឬក៏ការយកលោកចេញពីគ្រួសារនោះដោយបង្ខំ?

**ឆ៖** កាលសម័យនោះ គេអត់មានប្រើពាក្យថា បង្ខំ ឬស្ម័គ្រចិត្តអីទេ គេនិយាយតែពីការចាត់តាំងសម័យនុ៎ង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមិនមានសំណួរអ្វីទៀតទេ សម្រាប់សាក្សី ហើយសូមអរគុណសាក្សី ។ ប៉ុន្តែ ខ្ញុំចង់ដឹងថា តើជនជាប់ចោទឯកភាពតែអ្វីដែលថា សាក្សីធ្លាប់ជាសមាជិក ឬក៏បុគ្គលិកកុមារពេទ្យនៅស-២១ នោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញជនជាប់ចោទឆ្លើយតបនឹងសំណួររបស់ចៅក្រម ហ្សង់ម៉ាក ដែលបានសួរសំណួរនេះ ។

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រម! ក្នុងប្រវត្តិមន្ទីរ ស-២១ គឺមានទៅសុំក្មេងជំទង់អំពីកំពង់ឆ្នាំងមកមែនបានប្រហែលជាសែសិបនាក់ បើម្យ៉ាងពិនិត្យមើលទៅកម្រិតវប្បធម៌របស់លោក សេង ដន ដែលមិនចេះអក្សរ ហើយនិងការចងចាំរបស់គាត់នៅទាប ខ្ញុំអាចទទួលស្គាល់បានថា គាត់ជាកុមារមកពីខាងកំពង់ឆ្នាំងមែន ពាក្យថាការចងចាំរបស់គាត់ទាប ខ្ញុំសូមលើកឧទាហរណ៍មួយដែលគាត់ធ្វើសក្ខីកម្មព្រឹក នេះ គាត់ថាថ្ងៃនេះគាត់មានអាយុ៤៨ឆ្នាំហើយ ឆ្លើយជាមួយលោកប្រធាន គាត់ឆ្លើយអ៊ីចឹង

បើគិត៤៨ឆ្នាំ គាត់កើតនៅឆ្នាំ១៩៦១ ។ នៅពេលដែលឆ្លើយជាមួយនឹងលោកចៅក្រម ធូ មណី គាត់មានប្រសាសន៍ថា គាត់ចូលមកស-២១ អាយុ១១ឆ្នាំ លោកចៅក្រមខ្លួនលោក លោក ឡាវ៉ែន៍ លោកក៏បញ្ជាក់អំមិញថា អាយុ១១ឆ្នាំ បើលោកអាយុ១១ឆ្នាំ គឺលោកត្រូវកើតនៅឆ្នាំ១៩៦៤ នេះហើយដែលខ្ញុំថា ការចងចាំរបស់គាត់ទាប កម្រិតវប្បធម៌ក៏ទាប ការចងចាំក៏ទាប ខ្ញុំអាចទទួលបានថាជា កុមារខាងកំពង់ឆ្នាំងដែលកើតនៅជើងភ្នំមែន ។ ក៏ប៉ុន្តែ មួយទៀត ភស្តុតាងច្រើនទៀតដែលនាំឲ្យខ្ញុំមិនទាន់ច្បាស់លាស់ គឺទីមួយ គាត់និយាយពីរឿងមិត្ត ប៉ោ ។ មិត្ត ប៉ោ ជាប្រធានអង្គភាពមន្ទីរពេទ្យរបស់ខ្ញុំបាទមែន ប្រធានមន្ទីរពេទ្យរបស់ ស-២១ មែន ប្រធានមន្ទីរពេទ្យដំបូង ។

ក៏ប៉ុន្តែមិត្ត ប៉ោ ត្រូវចាប់ប្រហែលជាពាក់កណ្តាល៧៦ ឬក៏ដើម៧៧ ។ ដូច្នេះ លោក សេក ដន គាត់មានប្រសាសន៍ថា គាត់ចូលមក៧៨ ហើយនៅមានមិត្ត ប៉ោ មិនមែនទេ ។ ពេលនោះមានមិត្ត រិន ហើយនិងមិត្ត ទ្រី ជាពិសេសមិត្ត ទ្រី ហ្នឹង ហើយដែលខ្ញុំប្រើស្និតមែនទែន ឲ្យទៅយកឈាម យកអីហ្នឹងយកទៅឲ្យពេទ្យ៩៨ ។ នេះជារឿងមួយ ដែលធ្វើឲ្យខ្ញុំមិនទាន់អស់ចិត្ត មិនទាន់ជឿជាក់ថា សេក ដន ជាបុគ្គលិករបស់មន្ទីរស-២១ ហើយកម្មាភិបាលដឹកនាំមន្ទីរស-២១ គាត់ស្គាល់តែខ្ញុំម្នាក់ ថាមិនស្គាល់បង ម៉ម ណៃ ដែលទៅយកក៏ហីទៅចុះ ក៏ប៉ុន្តែគួរណាស់តែស្គាល់ ប៉េង ប្រធានកងការពារនៅហ្នឹង ចេញចូលព្រឹកល្ងាច ហើយអុងអាត់ជាង គេ គឺ ប៉េង ហ្នឹងឯង គាត់មិនស្គាល់ទៀត ។

សរុបមក ភស្តុតាងទាំងពីរនេះ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍ សង្ស័យថា សេក ដន ដូចជាមិនមែនបុគ្គលិករបស់មន្ទីរស-២១ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ ហើយសំណូមពរខ្ញុំនៅដដែលទេ គឺសូមឲ្យមានភស្តុតាងខាងការិយាល័យសហព្រះរាជអាជ្ញាបញ្ជាក់មកឲ្យខ្ញុំផងពីរឿងបញ្ជី ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះ សូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាដើម្បីធ្វើការសួរសំណួរដល់សាក្សីរូបនេះ ហើយតំណាងសហព្រះរាជអាជ្ញាមានពេលវេលាដប់ប្រាំនាទី សម្រាប់ការសួរចំពោះសាក្សីរូបនេះ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**សួរដោយលោក តាន់ សេងណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ ។ សូមស្វាគមន៍លោក សេក ដន ដោយលោកបានជម្រាបជូនអង្គជំនុំជម្រះរួចរាល់ខ្លះៗហើយ ថាលោកធ្លាប់បានទៅរៀនសូត្របច្ចេកទេសនៅព្រៃកន្ធោត ។

**ស៖** តើសំណួរសួរថា តើនៅពេលដែលបង្រៀនបច្ចេកទេសនៅព្រៃកន្ធោតនោះ តើគេបង្រៀនលោកពីជំនាញអ្វីដែរលោក?

**ឆ៖** ហាត់រៀនលូន រៀនបាញ់ រៀនដោះកាំភ្លើង ។

**ស៖** អរគុណលោក ។ សំណួរបន្ទាប់ នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត នៅពេលដែលលោកបានធ្វើការសម្ភាសន៍ចុះថ្ងៃទី១៦ ខែ១ ឆ្នាំ២០០៨ ដែលមានលេខ ERN លេខ00163817 ក្នុង D28/16 ហ្នឹង លោក ក្នុងនោះលោកបាននិយាយថា ខ្ញុំរៀន នៅកន្លែងរៀនខ្ញុំនុ៎ង វាមានអ្នកតវ៉ាថាហូបមិនគ្រប់គ្រាន់ ហ្វឹកហាត់ច្រើន ហើយគាត់ក៏ត្រូវបានចោទថាជា ខ្មាំងប្រឆាំងនឹងបដិវត្តន៍ ហើយអ្នកនោះត្រូវចាប់យកទៅបាត់អស់ ហើយមិនឃើញត្រឡប់មកវិញទេ ។ សំណួរថា តើលោកអាចប្រាប់ឈ្មោះថាមនុស្សដែលត្រូវចាប់នុ៎ង តើលោកមានស្គាល់ឈ្មោះ ថាជាឈ្មោះជាមិត្តរបស់លោកហ្នឹង អ្នកណាខ្លះបានទេ នៅពេលដែលរៀនសូត្របច្ចេកទេសនោះ?

**ឆ៖** មានតែក្រុមកងគេផ្សេងទេ មិនមែនក្រុមយើងខ្ញុំទេ ព្រោះទើបមកថ្មីដូចគ្នាអត់សូវស្គាល់ទេ។

**ស៖** អរគុណលោក ។ សំណួរបន្ទាប់ នៅក្នុងបទសម្ភាសន៍ដដែលនុ៎ងចុះថ្ងៃទី១៦ ខែ១ ឆ្នាំ ២០០៨ ដែលមានលេខERN ដដែលហ្នឹង លោកបាននិយាយថា មានកុមារប្រហែលមួយរយនាក់ដែលគេបានបែងចែកទៅធ្វើការនៅមន្ទីរស-២១ តើក្នុងនោះលោកមានចាំថា តើសិស្សកុមារ ជាកុមារីទេ ជាស្ត្រីហ្នឹង? ហើយកុមារដែល អ្នកដែលមកពីស្រុកជាមួយលោកនុ៎ង លោកមានស្គាល់ទេ លោកមាននៅចងចាំទេ?

**ឆ៖** កុមារដែលមកពីស្រុកនៅជាមួយខ្ញុំមាននៅសព្វថ្ងៃហ្នឹង ពីរនាក់មានឈ្មោះ សុន ឈ្មោះផាត គេធំៗជាងខ្ញុំកាលនុ៎ង ។

**ស៖** មានជាកុមារីទេ ពេលនោះមកធ្វើការនៅមន្ទីរស-២១ ជាមួយលោក?

**ឆ៖** កាលនោះ អត់មានស្រីទេ មានសុទ្ធតែក្មេងប្រុស ។

**ស៖** អរគុណលោក ។ នៅក្នុងបទសម្ភាសន៍ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតចុះថ្ងៃដដែល និង លេខ ERN ដដែលនោះលោកបានបញ្ជាក់ថា ពេទ្យក្មេងៗលោក ឃើញតែពេទ្យក្មេងៗទេ ហើយពេទ្យចាស់ៗត្រូវចាប់សម្លាប់ទាំងអស់ ។ សំណួរសួរថា តើលោកមានដឹងថា ពេទ្យចាស់ៗហ្នឹងមកពីខេត្តណាខ្លះ ដែលមកធ្វើការទីនោះលោក?

**ឆ៖** ខ្ញុំអត់ដឹងមកពីខេត្តណាទេ ព្រោះឃើញ ខ្ញុំធ្លាប់តែទៅឃើញនៅនុ៎ង អត់ដឹងថាមនុស្សនៅស្រុកណាផង ។

**ស៖** អរគុណលោក ។ សំណួរបន្ទាប់នៅក្នុងបទសម្ភាសន៍ដែលចុះនៅថ្ងៃខែឆ្នាំដដែល និងលេខ ERN ដដែលនៅក្នុងទំព័រ ERN ដែលមានលេខ 00163819 នៅក្នុង D28/16 ដដែលនុ៎ង លោកបានបញ្ជាក់ថា លោកបានឃើញអ្នកទោសវៀតណាមក្នុងឯកសណ្ឋានក៏មាន ស៊ីវិលក៏មាន ត្រូវនាំចូល ហើយបាននិយាយថា ហើយខ្ញុំគិតថាវៀតណាមទាំងនេះ ក៏ត្រូវធ្វើទារុណកម្មដូចគ្នាដែរ តើនៅពេលនោះលោកបាននិយាយនូវពាក្យពេចន៍អ៊ីចឹងមែនទេ?

**ឆ៖** កាលនោះ ខ្ញុំបាននិយាយអ៊ីចឹងដែរមែនហើយ ប៉ុន្តែឃើញពណ៌ខោអាវទាហានក៏មាន ខោអាវស៊ីវិលក៏មាន ប៉ុន្តែដឹងជាយួន ដឹងខ្មែរ ។

[១០:១៧:២២]

**ស៖** បាទ សំណួរបន្ទាប់តែក្នុងនោះដែរ តើលោកដែលបានឃើញគេធ្វើទារុណកម្មនូវអ្នកទោសវៀតណាមហ្នឹងដែរទេ?

**ឆ៖** អ្នកទោសវៀតណាមអត់មានដាក់នៅអគារខ្ញុំទេ ខ្ញុំអត់មានដែលបានឃើញទេ ។

**ស៖** អរគុណលោក នៅសំណួរបន្ទាប់នៅក្នុងការសម្ភាសន៍ដដែលនោះ លោកបាននិយាយថា លោកធ្វើការជាមួយ-- អ្នកធ្វើការជាមួយលោកបាននិយាយប្រាប់ពីការបូមឈាម តើអ្នកប្រាប់លោក អ្នកប្រាប់លោកនៅពេលនោះមានឈ្មោះអ្វីដែរលោក?

**ឆ៖** អ្នកប្រាប់ខ្ញុំមានក្មេងៗគ្នាឯងដែលដូចគ្នា ដែលធ្វើការអគារខុសគ្នា គេថា ហ៎! មានបូមឈាមបូមអីណា ។ រួចខ្ញុំថា អ្ហ៎! បូមឈាមអាម៉េចទេវ៉ី ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ។ សូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីឲ្យខាងសោតទស្សន៍បង្ហាញនូវរូបភាពមួយដែលមានលេខ 00181396 ក្នុង D48/2 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍បង្ហាញនូវឯកសារដែលមានលេខ ERN 00181396 ឬក៏ D48/2 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាជាតិ ។

**សួរដោយលោក តាន់ សេងណារ៉ុង៖**

**ស៖** លោក សេក ដន នេះគឺជារូបភាពរបស់សារមន្ទីរទួលស្លែង ដែលជាអតីតមន្ទីរស-២១ ពីមុនមកហ្នឹង ហើយនៅក្នុងនុំងមាន អគារ “ក” អគារ A , អគារ B អគារC, D, និង E ដែលមាន ដែលជាអក្សរខ្មែរគេហៅ ក, ខ, គ, ឃ និង ង ។ តើលោកនៅចងចាំបានទេ ថាតើអគារណាមួយដែល លោកធ្លាប់បានដើរចែកថ្នាំដល់អ្នកទោសទាំងនោះ អគារហ្នឹងបែរមុខមកកើត នេះជាសារមន្ទីរទួលស្លែង ដែលមានមុខ ដែលលោកមើលចំនេះ គឺមើលចំ យើងមើលពីកើតទៅ ខាងក្រោយនោះ គឺជាទិសខាង លិច ខាងមុខចំ យើងមើលៗពីមុខទៅអ៊ីចឹង គឺថា ដែលលោកអង្គុយមើលនៅក្នុងកៅអីហ្នឹង គឺថាលោក មើល ទៅទិសខាងលិច តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ ថាអគារណាមួយដែលលោក បានធ្លាប់ធ្វើការ?

[១០:២០:00]

**ឆ៖** ដែលខ្ញុំធ្លាប់ធ្វើការនៅអគារផ្ទះលេខបី ។

**ស៖** អគារអីដែរលោក លេខបីហ្នឹង?

**ឆ៖** អគារ “C” ។

**ស៖** អរគុណលោក តើក្នុងនុំងដែរ តើអគារណាមួយដែលៗមានថាអនុប្រធានរបស់ឈ្មោះ ប៉ោ នោះចងកនោះ លោកអាចចងចាំទេ នៅអគារណាមួយ?

**ឆ៖** គាត់ឈ្មោះ យឺន ដែលថាចង់កគាត់នៅអគារទីបួន អគារ “D” ។

**ស៖** នៅក្នុងរូបភាព នៅក្នុងរូបភាពដដែលនេះ តើលោកអាចចងចាំទេថានៅខាងមុខអគារ “A” និង“B” ហ្នឹង ឬមួយក៏ច្រកចូល នេះកន្លែងនេះមានច្រកចូលនៅមុខអគារក្រហមនោះ អគារក្រហម ដែល មានដូចអក្សរ “A” ហ្នឹងតើលោកចងចាំទេ ថាតើកន្លែងណាមួយជាកន្លែងមន្ទីរពេទ្យដែលលោក ធ្លាប់ធ្វើការ នោះដែលដើរតាមអ្នកធំៗចែកថ្នាំនោះ? មើលអាផ្ទះខាងមុខនោះ ដែលមានផ្ទះក្បឿងមួយ ផ្ទះក្បឿងរាង ក្រហមបន្តិច មួយទៀត ផ្ទះក្បឿងរាងអាប់បន្តិច ដែលនៅចុងគេហ្នឹង តើលោកប្រាប់ ជម្រាបអង្គជំនុំជម្រះបានទេពេលនេះ? អាផ្ទះក្បឿងក្រហមនេះ វាហាក់ដូចជាចំនៅពីមុខខ្លោងទ្វារនោះ លោកឃើញទេនុំង? ហើយអាមួយ អាក្បឿងនៅខាងៗនោះ ខាងនោះបន្តិច នៅអាប៉ែកខាងដែលបង្ខិត អំមិញនោះ រាងខ្មៅៗនោះគេហៅអគារអី?

**ឆ៖** អានេះ គាត់អត់សួរយល់ ។

**ស៖** អាមុខ អាកន្លែងក្រហមនោះ អគារក្រហមហ្នឹង គឺជា គឺច្រកចូល នោះអាឃើញស្នឹមៗនោះ គឺច្រកចូលហើយ មុខអគារក្រហមហ្នឹង តើអគារណាមួយជាអគារមន្ទីរពេទ្យ អគារពេទ្យដែលលោកធ្លាប់បានធ្វើការ និងស្នាក់នៅ និងដើរតាមបងៗនុំង?

**ឆ៖** ផ្ទះក្រហម ផ្ទះក្បឿងពីរខ្នងនេះ ។ មានប្រហុកនៅពីក្រោមផ្ទះហ្នឹង មានផ្អកនៅពីក្រោម។

**ស៖** អរគុណលោក ។ នៅសំណួរបន្ទាប់ នៅក្នុងកិច្ចសម្ភាសន៍នាថ្ងៃខែឆ្នាំ ដដែល និងលេខ ERN ដដែលហ្នឹង លោកបានបញ្ជាក់ប្រាប់ជូនចៅក្រមស៊ើបអង្កេតថា លោកបានឃើញមានឡានពណ៌ស សញ្ញាពេទ្យ មួយខែម្តង ឬក៏ពីរដង មកដឹកយកឈាម មិនដឹងថាមកយកឈាម ឬយកអ្នកទោសទៅដាក់នោះទេ ។ សំណួរសួរថា តើឡានដែលចូលនោះ ដែលមានសញ្ញាពេទ្យនោះ លោកឃើញមានសញ្ញាពេទ្យ គេដាក់សញ្ញាពេទ្យមកពីរបស់មន្ទីរស-២១ ឬក៏របស់មន្ទីរពេទ្យ លេខ “៣” ណាមួយនៅក្នុងអង្គភាពមន្ទីរពេទ្យនៅទីក្រុងភ្នំពេញដែលលោកអាចចងចាំបាននោះ?

[១០:២៣:៣៥]

**ឆ៖** គ្រាន់តែបានឃើញឡានពណ៌ស ប៉ុន្តែខ្ញុំអត់ស្គាល់ទេ ។ ឡានពេទ្យនៅក្នុងនុំងមិនដឹង ឡានពេទ្យនៅពីក្រៅមិនដឹង ប៉ុន្តែឡានៗពេទ្យមែន ។

**ស៖** អរគុណ ប្រសិនបើខ្ញុំបង្ហាញជូនលោកនូវផែនទីដែលមានលេខផ្លូវ តើលោកអាចបង្ហាញជូនអង្គជំនុំជម្រះបានទេ ថាតើផ្លូវណាមួយដែលធ្លាប់បានឆ្លើយនៅនឹងក្នុងកិច្ចសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃខែឆ្នាំដដែល និងលេខ ERN ដដែលនុំង លោកបានបញ្ជាក់ថា ផ្ទះរបស់កុមារ គឺខាងកើត ខាងជើងច្រកចូលសព្វថ្ងៃ កាច់ជ្រុងលេខ ផ្លូវលេខ ៣១០ ឬ ៣២០ ឬ៣៣០ និង ១១៣ បើសិនជាអង្គជំនុំជម្រះបង្ហាញជូនលោក ខ្ញុំបង្ហាញជូនលោក តើលោកអាចផ្គុលបង្ហាញជូនអង្គជំនុំជម្រះបានទេលោក សេក ដន?

**ឆ៖** សុំឆ្លើយម្តងទៀតលោក?

**ឆ៖** ខ្ញុំអត់សូវចាំស្គាល់លេខទេ ព្រោះខ្ញុំភ្លេចច្រើនណាស់ ។ ព្រោះផ្ទះខ្ញុំធ្លាប់នៅនុំងមែន ប៉ុន្តែខ្ញុំអត់សូវចាំលេខ ប៉ុន្តែកាច់ជ្រុងហ្នឹងមែន ។

**ស៖** ក្នុងនោះដែរ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីនឹង នៅពេលចុងបញ្ចប់ ខ្ញុំសុំឱ្យលោក សេក ដន ហ្នឹងធ្វើការគូសគំនូរបង្ហាញពីទីតាំងមន្ទីរពេទ្យ ហើយនិងកន្លែងដែលគាត់ធ្លាប់បានដើរចែកថ្នាំនៅអគារ “C” និងអគារដែលចងកដោយអនុប្រធានមន្ទីរពេទ្យនៅក្នុងអតីតមន្ទីរស-២១ តាម

រូបភាពនេះ ។

**ប្រធានអង្គជំនុំ៖**

ឈប់ ដោយសារអំមិញៗសាក្សីឆ្លើយជាក់លាក់ទេ ថាអគារណាមួយដែលប្រធានមន្ទីរពេទ្យ--ប្រធានក្រុមមន្ទីររបស់គាត់ចងក ដើម្បីធ្វើការកត់ត្រា ឬក៏ធ្វើការកត់សម្គាល់នៅក្នុងរូបភាព ។ លោកអាចបញ្ជាក់ចំណុចនេះបានទេ តាមយើងស្តាប់ដូចជាមិនមានចំណុចជាក់លាក់ដែលឆ្លើយដោយសាក្សីទេ ហើយឲ្យគូសយ៉ាងម៉េច?

ទីពីរ គឺអគារ “C” គឺលោកបានបង្ហាញ ហើយគាត់ឆ្លើយថាអគារ “C” រួចហើយ អ៊ីចឹងចំណុចអគារ “C” មិនចាំបាច់គូសទៀតទេ ពីព្រោះការបង្ហាញនេះ គឺបានកំណត់ជាក់លាក់ ហើយអ្នកណាក៏ស្គាល់ដែរ ប្រសិនជាស្គាល់ទីតាំងនេះ របៀបចុះមើលទីតាំងនេះ គឺបានស្គាល់អគារ “C” ប្រាកដប្រជារួចហើយ ។ ឥឡូវចំណុចណាដែលលោកចង់ឲ្យសាក្សីធ្វើការកត់សម្គាល់នូវលើរូបភាពជាក់លាក់ លើការិយាល័យដែលគាត់ធ្វើការ ហើយនិងកន្លែងចងកដែលប្រធានក្រុមរបស់គាត់ឈ្មោះ យឹន ឬក៏អនុប្រធានក្រុមរបស់ យឹន បានចងកស្លាប់នោះ? លោកមានបានទទួលចម្លើយនូវឥឡូវហ្នឹង ដែលៗអាចសុំដូច្នេះ?

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ ។

**ស៖** ខ្ញុំចង់ ទីមួយ គឺចង់សុំឲ្យលោក សេក ដន ហ្នឹងបញ្ជាក់ ទីតាំងកន្លែង ដែលគាត់ដើរចែកថ្នាំអ្នកទោស ដើម្បីថាសាក្សីមួយនេះ គឺជាកុមារចែកថ្នាំ ហើយវាអាចកត់សម្គាល់នៅក្នុងប្រតិចារឹកវាមានហើយ ប៉ុន្តែនៅក្នុងរូបភាពវាអាចជាៗរូបភាពនិមិត្តរូបនៃសាក្សីម្នាក់នេះដែលបានចង្អុលបង្ហាញថា កាលគាត់នៅកុមារគាត់បានដើរចែកថ្នាំនៅក្នុងអគារនេះ ។ ហើយការកត់សម្គាល់របស់គាត់អាចជានិមិត្តរូបនៅក្នុងរឿងក្តីផងដែរ ហើយក៏អាចប្រវត្តិសាស្ត្រដើម្បីឲ្យក្មេងជំនាន់ក្រោយដឹងដែរថា ទីតាំងនេះ គឺសាក្សី សេក ដន កាលនៅកុមារជាអ្នកដើរចែកថ្នាំ ។ ហើយអគារមួយទៀត ដែលលោកបានអះអាងថាអនុប្រធានមន្ទីររបស់លោកចងកនោះ លោកបានបញ្ជាក់ថា អគារ អក្សរ “D” ឌីនុ៎ង តើលោកអាចបញ្ជាក់ទីតាំងថាជាន់ណាមួយ កន្លែងណាមួយដែលអនុប្រធានមន្ទីរពេទ្យបានធ្វើអត្តឃាតខ្លួនឯងនោះ? តើលោកស្តាប់សំណួរខ្ញុំបានដែរទេ លោក?

[១០:២៧:៥៤]

**ឆ៖** ធ្វើអត្តឃាតខ្លួនឯង មិនមែនចងក្នុងគុកទេ គាត់មកចងនៅក្រៅនៅតាមផ្ទះទេ ផ្ទះខាងជើង ផ្ទះពេទ្យនុំង ផ្ទះឥឡូវហ្នឹងវាច្រើនខ្ញុំអត់ស្គាល់ទេ ។ ពីមុនផ្ទះដែលនៅគ្នាតិច ខ្ញុំអាចស្គាល់ ។

**ស៖** អគុណលោក សេក ដន ចុះចំពោះអគារពេទ្យដែលនៅស្ថិតនៅខាងមុខផ្លូវចូលសារមន្ទីរទួលស្លែង តើលោកអាចបញ្ជាក់ឡើងវិញបានទេថា អគារណាមួយនៃផ្ទះដែលមានដំបូលក្បឿងពណ៌ខ្មៅនិងពណ៌ក្រហមមុខច្រកចូលហ្នឹង? ឥឡូវលោកមើលរូបភាពហ្នឹងឡើងវិញ ថាតើអគារផ្ទះដំបូងក្រហមហ្នឹង ឬក៏អគារបញ្ឆិតនៅប៉ែកៗបន្ទាប់ពីផ្ទះក្រហមនុំង ដែលសឹងថា ស្ថិតនៅក្រោមបញ្ឆិតមួយនឹងអាគំនូសអគារ “A” នោះ?

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាមានរូបភាពរឹងទេ? ដើម្បីដាក់ *ស្លាយ* ឲ្យគាត់ចង្អុយ ពីព្រោះគាត់និយាយទទេអ៊ីចឹង គឺទាំងអស់ជំនុំជម្រះក៏គាត់មិនដឹងដែរ ហើយទម្រាំតែសាធារណជនម៉េចនឹងយល់បានថាទីតាំងកន្លែងណាមួយច្បាស់លាស់ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** នៅពេលដែលលោកចង្អុលបង្ហាញសូមលោកគូសឲ្យជិតលើនុំង ថាទីតាំង-- លោកសរសេរជាអក្សរ “ក” ក៏បាន “ខ” ក៏បាន ថាទីតាំងអគារណាមួយ? កន្លែងណាមួយ? សូមគូសឲ្យច្បាស់ៗ ហើយលោកឆ្លើយប្រាប់ជូនអង្គជំនុំជម្រះផង ថានៅពេលដែលលោកគូសនោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីប្រឹក្សាសាក្សី ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន ។ ដោយសាក្សីគាត់មើលរូបអត់យល់ ដូច្នេះបើសិនជាលោកសហព្រះរាជអាជ្ញាជាតិអាចមានរូបភាពផ្សេងដែលអាចធ្វើឲ្យគាត់ងាយយល់បាន ឬក៏អាចអញ្ជើញមកពន្យល់ឲ្យចំនៅខាងមុខតែម្តងទៅងាយយល់ជាង ពីទីតាំងកន្លែងមួយៗ ។ សូមអញ្ជើញ អាចអញ្ជើញលោកសហព្រះរាជអាជ្ញាមកឲ្យជិតសាក្សី ដើម្បីពន្យល់ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមលោកតំណាងសហព្រះរាជអាជ្ញាជាតិ តាំងសំណួរដាក់លាក់ចំពោះសាក្សី ហើយសំណួរទាំងអស់ត្រូវគិតផងអំពីកម្រិតយល់ដឹងរបស់សាក្សី តើគាត់យល់ដឹងកម្រិតណា? គួរប្រើប្រាស់សំណួរ

ប្រភេទណា? ដើម្បីឲ្យសាក្សីដែលមានកម្រិតសមត្ថភាពប៉ុណ្ណឹង អាចនិយាយប្រាប់ដល់អង្គសវនាការបានជាក់លាក់ ប្រសើរជាជាងសួរនូវសំណួរដែលហួសពីលទ្ធភាពដែលគាត់យល់ដឹង។ វាឥតប្រយោជន៍សម្រាប់ការផ្តល់នូវសក្ខីកម្មចំពោះអង្គសវនាការនោះ ។

**លោក តាន់ សេណារ៉ុង៖**

តំណាងសហព្រះរាជអាជ្ញាយល់ថា រូបភាពនេះប្រសិនជាអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្ញុំទៅបង្ហាញ និងពន្យល់នៅជិតបាន ខ្ញុំនឹងព្យាយាមបង្ហាញដើម្បីពន្យល់ឲ្យសាក្សីហ្នឹងបានយល់តាមរូបភាពដែលដាក់*ស្លាយ*ហ្នឹង ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ឥឡូវហ្នឹងព្រោះពេលវេលាលោកអាចចំណាយពេលវេលាលើសប្រាំមីនុតរួចហើយ ។ ឥឡូវហ្នឹងគឺអនុញ្ញាតចុងក្រោយលោកអាចទៅបញ្ជាក់បាន ប៉ុន្តែបញ្ជាក់ណាដែលវាមិនទាន់ច្បាស់ ឬក៏វាមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ឲ្យសាក្សីយល់ ។

[១០:៣៣:២៨]

តំណាងសហព្រះរាជអាជ្ញាមិនអាចធ្វើការខ្សឹបខ្សៀវ ដូចជាមេធាវីប្រឹក្សាជាមួយនឹងសាក្សីបានទេ លោកតំណាងអយ្យការត្រូវចង្អុលបង្ហាញមានលក្ខណៈជាសាធារណៈសម្រាប់អង្គជំនុំជម្រះទាំងមូល និងសាធារណជនបានយល់អំពីការបង្ហាញរបស់លោក ។ បើពុំដូច្នោះទេ ភាគីសាធារណជនអាចច្រឡំថាលោកនឹងណែនាំចង្អុលបង្ហាញដើម្បីដឹកមុខ នៅក្នុងការបង្ហាញហេតុផលផ្សេងៗនៅក្នុងរូបភាពនេះដល់សាក្សីហើយ ។

**លោក តាន់ សេណារ៉ុង៖**

លោក--ដែលបានណែនាំ តើលោក សេក ដន នេះ គឺជារូបភាពទីតាំងរបស់សារមន្ទីរទួលស្លែងទាំងមូល ដែលមានអគារ “ក”, “ខ” , “គ”, “ឃ” និង “ង” ហ្នឹង ។ ហើយអំមិញលោកបានបញ្ជាក់ថាៗ រូបនេះ គឺកន្លែងលោកដើរចែកថ្នាំមិនអ៊ីចឹង?

**ឆ៖** បាទ, ទីបី ។

**ស៖** ហើយចុះអគារមួយត្រង់នេះ លោកបញ្ជាក់ថា គូស លោកគូសមកអាណាមួយជាមន្ទីរនោះ ដែលលោកអាចបង្ហាញបានទេ?

**ឆ៖** ផ្ទះពេទ្យហ្នឹង នៅអាផ្ទះពីរខ្នងហ្នឹង ។

**ស៖** ផ្ទះពីរខ្នងហើយ អាហ្នឹងច្បាស់ហើយ?

**ផ៖** បាទ, ខ្ញុំនៅហ្នឹងមានប្រហោងនៅ--

**ស៖** លោកគូសពីលើផងៗ ។

**ផ៖** ហ្នឹង ។

**ស៖** គូសរង្វង់មូលទៅ ។ គ្រាន់តែចង់បញ្ជាក់ នេះគឺច្រកចូល ហើយនេះច្រករបស់សារមន្ទីរទួលស្លែងនេះ កាលពីមុនក៏អ៊ីចឹង ហើយឥឡូវហ្នឹងក៏អ៊ីចឹងដែរ--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តី ។

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំយល់ថា ដូចជាយឺតពេលបន្តិចហើយ អ៊ីចឹងខ្ញុំចង់ឲ្យលោក ការ សាវុត្ថ ដែលជាសហសេវិករបស់ខ្ញុំហ្នឹងឯង គាត់អង្គុយនៅក្បែរសាក្សីដែរ នៅពេលដែលសហព្រះរាជអាជ្ញាជាតិបានចង្អុលបង្ហាញរូបភាពនោះ ។

**ប្រធានអង្គជំនុំ៖**

ទីមួយ គឺបញ្ឈប់នូវពេលវេលានៃការសួរសាក្សីរូបនេះ ដោយសហព្រះរាជអាជ្ញា ព្រោះការប្រើពេលវេលាលើស ។ បញ្ហាទីពីរ ក្នុងការលក្ខខណ្ឌដូចគ្នា គឺអង្គជំនុំជម្រះនឹងពិចារណាលើលទ្ធភាពជាក់ស្តែងក្នុងការបង្ហាញ ឲ្យតែរបៀបបង្ហាញហ្នឹងមានលក្ខណៈច្បាស់លាស់ធ្វើឲ្យសាធារណជនយល់អំពីរបៀបក្នុងការសួរ ហើយនិងឲ្យបង្ហាញជាសាធារណៈនោះបាន ចៀសវាងការសួរហ្នឹងមានភាពអត្តនោម័តិដោយខ្លួនគាត់ហើយយល់តែម្នាក់ឯង ។ ភាគីណាក៏បានដែរនៅក្នុងលក្ខខណ្ឌដូចគ្នា ឲ្យតែអង្គជំនុំជម្រះយល់ថា ដើម្បីការចង្អុលបង្ហាញនោះក្នុងគោលបំណងស្វែងរកការពិត ។

ដោយសារពេលវេលាត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ ហើយមន្ត្រីតុលាសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះ ហើយឲ្យនាំគាត់មកកាន់សាលសវនាការមុនម៉ោងកំណត់ ។

*[សវនាការសម្រាកពីម៉ោង ១០:៣៧នាទីដល់ម៉ោង ១១:០៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការពិភាក្សាដេញដោលស្ដាប់សក្ខីកម្មសាក្សីឈ្មោះ សេក ដន បន្តមកទៀត ។ ហើយជាបន្តនេះ សូមប្រគល់វេទិកាទៅមេធាវីអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីទាំងបួនក្រុម ថាតើវិធីនៃការសួរស្ដាប់សក្ខីកម្មសាក្សីរូបនេះ ដោយវិធីយ៉ាងណាម៉េច? ហើយក្រុមណាជាអ្នកសួរ?

សូមអញ្ជើញ ។

**ការតាំងសំណួរដោយក្រុមមេធាវីដើមណ្ដឹងរដ្ឋប្បវេណី៖**

**សួរដោយកញ្ញា ម៉ុច សុវណ្ណារី៖**

ជាដំបូង នាងខ្ញុំសូមគោរពដល់លោកប្រធាន និងអង្គជំនុំជម្រះសាលាដំបូងទាំងមូល ។ ដោយមានការព្រមព្រៀងអំពីជាមួយនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រុមផ្សេងទៀត ដូច្នេះក្រុមនាងខ្ញុំមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រុមបី និងប្រើប្រាស់ពេលវេលាទាំងអស់ សួរសំណួរទៅដល់សាក្សីរូបនេះ នៅក្នុងនាមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ។

ជាដំបូង នាងខ្ញុំនឹងចាប់ផ្ដើមសួរសំណួរ ហើយមេធាវីសហភាតារបស់នាងខ្ញុំ លោកស្រីមេធាវីហ្វាប៊ីយ៉ែន ទ្រូស្សូណាព្រូស គាត់នឹងបន្តសំណួរ ។

សួស្ដីលោកសាក្សី! នាងខ្ញុំមេធាវី ម៉ុច សុវណ្ណារី ។ នាងខ្ញុំ ជាមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋ-ប្បវេណីក្រុមបី ។ នាងខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរទៅលោក ។ បើសិនជាលោកស្ដាប់សំណួរនាងខ្ញុំមិនច្បាស់ ឬក៏លោកមិនយល់នឹងសំណួរ លោកអាចសួរបញ្ជាក់នាងខ្ញុំ មុននឹងលោកឆ្លើយ ។ ហើយនាងខ្ញុំ សូមអរគុណលោកជាមុន ចំពោះការព្យាយាមឆ្លើយនឹងសំណួររបស់នាងខ្ញុំ ។

**ស៖** សំណួរទីមួយ ដែលនាងខ្ញុំចង់សួរគឺទាក់ទងទៅនឹងស្ថានភាពពេលមួយ គឺនៅពេលដែលលោកត្រូវបានគេនាំចេញពីភូមិរបស់លោកមកដើម្បីនឹងធ្វើការងារតាមការចាត់តាំងរបស់អង្គការ ។ នៅពេលនោះ លោកបានផ្ដល់-- មុននឹងបន្តិចលោកបានផ្ដល់ព័ត៌មាន ឆ្លើយនឹងសំណួររបស់លោកចៅក្រមឡាវ៉ែន៍ លោកបានឆ្លើយថា មានកងឈ្លបមកនាំយកលោកទៅ ហើយប្រាប់ថាមានការចាត់តាំង ។

អ៊ីចឹងនៅពេលនោះ ខ្ញុំចង់ឲ្យលោករៀបរាប់អំពីស្ថានភាពនៅពេលនោះ រូបភាពទាំងមូល ថាតើដំណើរការ ដែលគេនាំលោកចាកចេញទៅហ្នឹង គឺវារបៀបណា? ថាតើលោកមានឱកាស ដើម្បីនឹងជួបជាមួយនិងឪពុកម្ដាយរបស់លោកក្នុងការនិយាយលាគ្នា ឬក៏ផ្ដល់ព័ត៌មានដល់ឪពុកម្ដាយរបស់លោកថា

លោកត្រូវបានអង្គការចាត់តាំងទៅហើយដែរឬទេ? តើលោកយល់ៗសំណួរខ្ញុំទេ?

[១១:០៦:១២]

**ឆ៖** សូមបញ្ជាក់ ពន្យល់បន្តិតទៀត ។

**ស៖** នាងខ្ញុំចង់ឲ្យលោករៀបរាប់បន្តិចថា ស្ថានភាពនៅពេលនោះ នៅពេលដែលគេមកនាំយកលោកទៅពីផ្ទះ ពីកន្លែងដែលលោក ពីភូមិរបស់លោកហ្នឹង ថាតើពេលនោះ គេមកយ៉ាងម៉េច? ហើយគេនិយាយយ៉ាងម៉េច? ហើយពេលនោះ លោកនៅកន្លែងណា? ហើយតើលោកមានឱកាសដើម្បីនឹង-- គេមានផ្តល់ឱកាសឲ្យលោកទៅជួបជាមួយនឹងឪពុកម្តាយរបស់លោក ដើម្បីនិយាយលាគ្នាមុនដែលគេនាំលោកមកភ្នំពេញហ្នឹង តើគេមានផ្តល់ឱកាសបែបហ្នឹង ដល់លោកដែរឬទេ?

**ឆ៖** អត់មានបានលាគ្នាទេ យកមកបណ្តោយទៅ ។

**ស៖** អរគុណ ។ ចំពោះព័ត៌មានរបស់លោក ។

ជាបន្តទៅទៀតនេះ នាងខ្ញុំសុំចូលដល់សំណួរទីពីរ ទាក់ទងជាមួយនឹងការចាប់ខ្លួនរបស់ប្រធានក្រុមរបស់លោក មេក្រុមរបស់លោក ដែលមានឈ្មោះថា ប៉ោ ហ្នឹង ។ ប្រសិនបើលោកអាចដឹងបាន តើលោកដឹងទេថា ប្រធានក្រុមរបស់លោកហ្នឹង ត្រូវបានគេចាប់យកទៅដាក់នៅក្នុងគុកទួលស្លែងហ្នឹងតែម្តង ឬគេបានបញ្ជូនគាត់ទៅកន្លែងផ្សេង ដូចជាទៅព្រៃស តើលោកបានដឹងពីហេតុការណ៍ទាំងអស់នេះដែរឬទេ?

**ឆ៖** គេចាប់ដាក់ក្នុងគុកកន្លែងហ្នឹងហើយ ប៉ុន្តែអត់មាន ខ្ញុំអត់ដែលបានឃើញគាត់នៅបន្ទប់លេខប៉ុន្មានទេ ព្រោះផ្សេង ផ្ទះផ្សេងគ្នា អត់ឲ្យឃើញទេ អ្នកនៅជាមួយគ្នា ។

**ស៖** សូមអរគុណ ។ តើលោកអាចជម្រាបជូនអង្គសវនាការទាំងមូលបានទេ ថាអ្វីបានជាលោកអាចដឹង ថាគាត់ត្រូវគេចាប់ខ្លួនឃុំនៅក្នុងគុកទួលស្លែងហ្នឹងតែម្តង?

**ឆ៖** ព្រោះបាត់អត់មានយកទៅណាទេ មានតែដាក់គុកនៅហ្នឹងទេ មនុស្សហ្នឹង មនុស្សអ្នកការពារនៅហ្នឹង ។ អ្នកធ្វើការនៅហ្នឹង អត់មានយកទៅណាទេ ។

**ស៖** នាងខ្ញុំសូមអរគុណ ។ សំណួរបន្ទាប់មកទៀត ទាក់ទងទៅជាមួយស្នាមរបួសដែលលោកបានឃើញនៅលើរូបរាងកាយរបស់អ្នកទោស ជនរងគ្រោះនៅទីនោះ ។ នៅពេលដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានជួបសម្ភាសជាមួយនឹងលោក ពេលនោះគេបានសួរសំណួរលោកថា “នៅពេលដែលដើរចែកថ្នាំ និងព្យាបាលនោះ តើលោកបានឃើញខ្លះនៅស-២១?” ពេលនោះ

លោកបានឆ្លើយថា "លោកបានឃើញរបួសមានជាច្រើន ដូចជា ការបាត់ក្រចក មានស្នាមរបួសលើនៅលើខ្នង" ហើយនៅពេលនោះ នៅក្នុងកំណត់ហេតុហ្នឹង នាងខ្ញុំបានឃើញលោកបញ្ជាក់ប្រាប់គេថា "លោកឃើញអ្នកទោសមានបែកក្បាល ហើយមានហូរឈាមទៀត" ។ តើលោកចាំបានទេថា អ្នកទោសមានបែកក្បាលអ៊ីចឹង ហើយថាតើលោកអាច ប្រសិនបើជាបាន តើលោកអាចរៀបរាប់បានទេ តើស្នាមរបួសហ្នឹង វាយ៉ាងម៉េច? ហើយវាកើតឡើងដោយ-- គេវ៉ៃរបៀបណា បានទៅជាអ៊ីចឹង?

**ឆ៖** សំណួរហ្នឹងបញ្ជាក់ទៀត ខ្ញុំអត់សូវយល់ទេ ។

[១១:០៩:១៨]

**ស៖** អ៊ីចេះ! នៅពេលដែលលោកបានឆ្លើយនឹងសំណួររបស់អ្នកស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេតចៅក្រមស៊ើបអង្កេត លោកបានឆ្លើយថា លោកបានឃើញមានអ្នកទោសមានស្នាមរបួសបែកក្បាល មានហូរឈាមអ៊ីចឹង ។ អ៊ីចឹងនាងខ្ញុំចង់សួរថា តើលោកអាចប្រាប់ថាស្នាមរបួសហ្នឹងវាយ៉ាងម៉េចខ្លះ? ហើយបើសិនជាអាចបាន តើលោកដឹងទេ តើប្រភេទដែលធ្វើឲ្យមានស្នាមរបួសហ្នឹង តើគេវ៉ៃអ្នកទោសរបៀបម៉េចបានជាក្បាលគាត់បែកហូរឈាមរបៀបអ៊ីចឹង? លោកយល់សំណួរនាងខ្ញុំទេ?

**ឆ៖** អត់និយាយ ។

**ស៖** សូមអរគុណ ។ នាងខ្ញុំនឹងសួរសំណួរចុងក្រោយមួយទៀតដល់លោក ហើយនាងខ្ញុំនឹងបន្តផ្តល់វេទិកានេះ ទៅដល់សហមេធាវីដៃគូរបស់នាងខ្ញុំ ។ នៅក្នុងឯកសារលេខ D28/19 នៅក្នុងទំព័រដែលមាន ERN លេខ 00163851 នៅពេលនោះលោកបាននិយាយថា តើលោកៗចាំបានទេថា លោកបានថា លោកបានឃើញជនជាប់ចោទ គឺលោក ឌុច ហ្នឹង នៅក្នុងសាលារៀននយោបាយចំនួនពីរដងតើលោកចាំបានទេ? បើសិនជាលោកចាំបាន លោកអាចជម្រាបជូនអង្គសវនាការថា លោកអាចចាំបានបើសិនជាលោកចាំអត់បាន លោកអាចជម្រាបថា លោកចាំអត់បានទេពីហេតុការណ៍ទាំងអស់នេះ?

**ឆ៖** ខ្ញុំបានឃើញពីរដងមែន ប៉ុន្តែបាន-- ប៉ុន្តែខ្ញុំអត់សូវចាំ ។

**ស៖** អ៊ីចឹង បានន័យថា លោកបានឃើញជនជាប់ចោទ គឺលោក ឌុច ពីរដងមែន តែលោកអត់ចាំថានៅកន្លែងណា? នៅសាលារៀននយោបាយ ឬក៏នៅកន្លែងណាទេ? តើអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែន ។

**កញ្ញា ម៉ុច សុវណ្ណារី៖**

អ៊ីចឹង នាងខ្ញុំសូមអស់សំណួរទៅដល់រូបលោក ហើយនាងខ្ញុំ សូមអនុញ្ញាតផ្ទេរវេទិកានេះ ទៅ

ដល់សហមេធាវីដៃគូរបស់នាងខ្ញុំ លោកស្រីមេធាវី ហ្វាប៊ីយ៉ែន ទ្រូស្សូណាព្រូស ។

**លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សូ ណាព្រូស៖**

ជម្រាបសួរលោក សេក ដន ខ្ញុំឈ្មោះ ទ្រូស្សូ ណាព្រូស ខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី ហើយសូមអរគុណ ដែលលោកវត្តមាន ហើយលោកអាយុ៤៨ឆ្នាំហើយ តើលោកប្រាប់យើងបានទេ តើលោកមានអារម្មណ៍ដូចម្តេច? តើអ្វីលោកដែលឆ្លងកាត់ក្នុងឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ តើលោកយល់ដូចម្តេច? តើលោកយល់ឃើញដូចម្តេចថា សម័យនោះយ៉ាងដូចម្តេចដែរថ្ងៃនេះ?

[១១:១២:១៧]

**ឆ៖** សម័យនោះ បើខ្ញុំយល់ ខ្ញុំនឹកឃើញទៅ ខ្ញុំថាប្រហែលជាសម្លាប់ៗងាប់អស់ហើយ បើចង់រស់តែឯង ដែលនៅគ្នាតិចទេ មើលទៅ ។

**ស៖** ខ្ញុំយល់អ្វីដែលលោកបាននិយាយ ប៉ុន្តែសំណួរខ្ញុំនោះ ខ្ញុំចង់ដឹងថាតើៗលោកយល់ដូចម្តេចនៅពេលនេះដែរថាលោកជាមនុស្សចាស់ហើយ តើលោកនៅទទួលអារម្មណ៍ដែលលោកបានឆ្លងកាត់នៅក្នុងសម័យនោះដែរឬទេ នៅក្នុងជីវិតនេះ?

**ឆ៖** សំណួរអត់សូវយល់ ។

**ស៖** តើលោកយល់ថា លោកមានការឈឺចាប់អំពីអ្វីដែលលោកបានឃើញនៅពេលនោះដែរឬទេ? តើលោកអ្វីៗ ដែលលោកបានឃើញបណ្តាលឲ្យលោកមានការឈឺចាប់ ឬក៏មានបញ្ហាអ្វី តើលោកគេងមិនសូវលក់ ឬក៏លោកនឹកឡើងពេលដែលបានឃើញនោះ មានការព្រួយបារម្ភអ្វីទេ?

**ឆ៖** មានការព្រួយបារម្ភ ខ្លាចដល់ខ្លួនឯង ដែលធ្វើខុស ។

**ស៖** ខ្ញុំចង់ត្រឡប់មកសំណួរមួយ ដែលមេធាវី ម៉ុច សុវណ្ណារី បានសួរទៅលោក ។ គាត់បានសួរលោកថាៗ លោកបានឃើញ ឌុច នៅក្នុងពីរដង តើ ឌុច បាននិយាយអ្វីក្នុងពេលដែលលោកបានឃើញគាត់ពីរដងនុ៎ង ដែរថានៅក្នុងអង្គប្រជុំនោះ ក្នុងពេលប្រជុំ?

**ឆ៖** គាត់បើកបង្រៀន ដូចជាសាលានយោបាយបក្សកុម្មុយនីស្តហ្នឹង។ ប៉ុន្តែ ខ្ញុំមិនសូវចេះច្បាប់ដែរ ច្បាប់អស់ហ្នឹង ។

**ស៖** ខ្ញុំមិនមានសំណួរទៀតទេ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅសល់ពេលដប់មីនុតទៀត តើមានការប៉ុនប៉ង

ក្នុងការសួរសំណួរដល់សាក្សីរូបនេះដែរឬទេ ចំពោះក្រុមផ្សេង? បើមិនមានទេ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសួរសំណួរដល់សាក្សីរូបនេះ ប្រសិនបើមាន សូមអញ្ជើញ ។

[១១:១៦:១១]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី៖**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណ លោកប្រធាន និងសូមគោរព លោកប្រធាន ។ សូមគោរព លោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរព អង្គសវនាការទាំងមូល ។

**ស៖** លោក សេក ដន លោកថាលោកជាកុមារពេទ្យនៅស-២១ ។ លោកបានឃើញឡានមានសញ្ញាពេទ្យចូលមកមុខគុក ។ ខ្ញុំសុំសួរលោកថា តើឡានហ្នឹងពណ៌អី លោកមានចាំទេ?

**ឆ៖** ឡានហ្នឹង ឡានពណ៌ស សញ្ញាពេទ្យ ។

**ស៖** តើលោកមានដឹងទេ ឡានហ្នឹងជាឡានរបស់ស-២១ ឬក៏ជាឡានរបស់អង្គភាពផ្សេង ដែលបានចូលមកដល់មុខគុកទួលស្លែង? សូមលោកបញ្ជាក់មើល។

**ឆ៖** អត់និយាយ អាហ្នឹង ។

**ស៖** ទីពីរ លោកថា ផ្ទះពេទ្យហ្នឹង មានដាក់ប្រហុកនៅខាងក្រោមហ្នឹង ក្រោយហ្នឹង ផ្ទះពេទ្យហ្នឹង ។ លោកមានឆ្ងល់ដែរ ហេតុអីក៏គេយកប្រហុកហ្នឹងទុកនៅផ្ទះពេទ្យ គេមិនយកទៅទុកនៅផ្ទះបាយ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំអាចឆ្ងល់ដែរ មានប្រហុកមានផ្អកអីមកនៅក្រោមផ្ទះ អង្កាល់ពីមុនអត់មាន ទើបតែយកមកដាក់ ។ ខ្ញុំនឹកស្មានថាយ៉ាងម៉េច គេយកទៅដាក់ឲ្យអ្នកណា? ឯណា? បានយកមកដាក់នៅក្រោមផ្ទះយើងហ្នឹង ។

**ស៖** សូមអរគុណ ។ អ៊ីចឹង ប្រហុក ផ្អក ហ្នឹង ទើបតែយកមកទេ អង្កាល់ពីមុនអត់មានទេ លោកបញ្ជាក់មើល?

**ឆ៖** ប្រហុក ផ្អក ហ្នឹង អង្កាល់មុនអត់មានទេ ទើបតែយកមកទេ ។

**ស៖** សូមអរគុណ ។ ពេលលោកដើរចែកថ្នាំអ្នកទោស លោកមានដែលជួបប្រទះឃើញ តាឌុច នែ៎ ធ្វើទារុណកម្មអ្នកទោសដោយផ្ទាល់ ឬក៏ តាឌុច ហ្នឹង បញ្ជាអ្នកយាមឲ្យធ្វើបាប ឲ្យធ្វើទារុណកម្ម

ដល់អ្នកទោសទេ ដែលលោកនៅអគារហ្នឹង នៅចាំចែកថ្នាំ តើលោកមានដែលឃើញទេ? សូមលោកបញ្ជាក់ទៅមើល ។

**ឆ៖** ខ្ញុំអត់ដែលឃើញគាត់ ឃើញផ្ទាល់ទេ ឃើញតែ ក្រែងតែគាត់បញ្ជា ព្រោះផ្ទាល់ខ្ញុំអត់ដែលឃើញទេ ប៉ុនមានកងគេធំៗ គេបញ្ជាតាមអាមេៗដូចតាអីណា តាប៉េង តាអ៊ីនុំង ។

**ស៖** អ៊ីចឹងលោកអត់ដែលបានឃើញបញ្ជាផ្ទាល់ទេ? អ៊ីចឹងការដែលគេបញ្ជាថា ទៅបញ្ជា តាប៉េង ទៅអ៊ីហ្នឹង អានេះលោកសន្និដ្ឋានខ្លួនឯងទេ លោកក៏មិនដែលឮដែរ? អ៊ីចឹងមែនទេ?

**ឆ៖** សំណួរហ្នឹងបដិសេធ ។

**ស៖** លោកថា អ្នកឲ្យចាប់ពេទ្យធំៗមេរបស់លោកហ្នឹង ពេទ្យចាស់ៗហ្នឹង គឺមានតែ តាឌុចទេ ។ អ៊ីចឹង តើលោកមានភស្តុតាងអី? សូមលោកបង្ហាញមកផងមើល បង្ហាញតុលាការមើលដែលបញ្ជាក់ថា ឌុច ដែលលោកដឹងនោះ ដោយសារអី? សូមលោកបញ្ជាក់ផង ។

**ឆ៖** ព្រោះគាត់ជាមេដឹកនាំនៅកន្លែងនោះហើយ ។

**ស៖** អ៊ីចឹងគ្រាន់តែគាត់ជាមេ ហើយលោកសន្និដ្ឋានថា ប្រហែលជាគាត់ហើយអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំសន្និដ្ឋានថា ប្រហែលជាគាត់ហ្នឹងហើយគ្មានអ្នកណាទេ ព្រោះគាត់ជាមេដឹកនាំនៅហ្នឹងហើយ អ្នកណាលើគាត់ទៀត មិនដឹង ។

**ស៖** អ៊ីចឹងត្រង់គាត់ទទួលបញ្ជាពីលើមកទៀតលោកអត់មាននឹកសង្ស័យទេ អីយ៉ាងម៉េច? សូមលោកបញ្ជាក់ផង ។

**ឆ៖** ទទួលពីលើទៀតខ្ញុំអត់បានដឹងទេ ខ្ញុំដឹងតែត្រឹមហ្នឹងទេ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន។ សូមផ្ទេរឲ្យលោកមេធាវី ហ្វ្រង់ស្វ័រ គាត់សួរបន្ត។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ សូមអរគុណលោកសាក្សី ។

**ស៖** ខ្ញុំចង់សួរសំណួរលោកមួយចំនួន ដើម្បីឲ្យលោកអាចជួយយើងបំភ្លឺនូវព័ត៌មានមួយចំនួនកាលពីសម័យនោះ ។ នៅក្នុងចម្លើយរបស់លោក ដែលលោកបានឆ្លើយទៅអ្នកស៊ើបអង្កេតរបស់សហ

ចៅក្រមស៊ើបអង្កេតនោះដែលបានបញ្ជាក់ដែលថា លោកកើតនៅឆ្នាំ១៩៦១ នៅក្នុងភូមិចាមក្របៅ ។ តើត្រូវដែរឬទេ? តើលោកពិតជាកើតនៅភូមិត្រពាំងក្របៅនោះមែនឬទេ?

**ឆ៖** ខ្ញុំកើតនៅភូមិត្រពាំងក្របៅមែន ឃុំខ្លុងពពក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំងមែន ។

**ស៖** ហើយលោកបានកើតនៅក្នុងឆ្នាំ១៩៦១ តើអ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែនហើយ ត្រឹមត្រូវ ។

**ស៖** លោក សេក ដន ប្រសិនបើលោកកើតនៅឆ្នាំ១៩៦១ នៅឆ្នាំ១៩៧៥ លោកមិនអាចអាយុ ១១ឆ្នាំដូចដែលលោកប្រាប់តុលាការទេ ។ តាមពិតលោកអាយុ១៤ ឆ្នាំបើតាមពិនិត្យលេខហ្នឹង តើអ៊ីចឹងមែនទេ?

**ឆ៖** សំណួរនេះខ្ញុំអត់សូវចេះគិតទេ អាយុភ្លេច ។

**ស៖** នៅក្នុងប្រទេសរបស់ខ្ញុំ គឺថាតួលេខ គឺថាបញ្ជាក់លេខហើយថា ឲ្យច្បាស់ ។ តើលោកបញ្ជាក់ទេថា លោកពិតជាកើតនៅឆ្នាំ១៩៦១? អ៊ីចឹងនៅឆ្នាំ១៩៧៥ លោកត្រូវមានអាយុ១៤ឆ្នាំ ។ លោកបាននិយាយដែរថា នៅឆ្នាំ១៩៧៥ គេបានបង្ខំលោក គឺចាត់តាំងឲ្យលោកមកភ្នំពេញ ហើយលោកបានចូលទៅរៀននៅសាលាយោធាមួយ ហើយលោកបាននៅទីនោះបីខែ ។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** អ៊ីចឹងមែន ។

**ស៖** បន្ទាប់មកលោកបាននិយាយថា លោកប្រាប់ទៅអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតថា លោកបានទៅធ្វើស្រែ ហើយនិងបានលើកទំនប់ដីកប្រឡាយដូចអ្នកផ្សេងៗទៀតដែរ ។ តើលោកនៅចាំទេ តើរយៈពេលប៉ុន្មានដែលលោកទៅធ្វើស្រែដាំស្រូវ ហើយនិងលើកទំនប់ដីកប្រឡាយហ្នឹង អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ធ្វើកន្លែងនេះបន្តិច កន្លែងនោះបន្តិច រាប់តែខែ ប៉ុន្តែខ្ញុំអត់សូវចាំ ។

[១១:២៦:៣០]

**ស៖** តើយើងអាចសួរលោកជាដំណាក់កាលៗ តើលោកចំណាយពេលមួយឆ្នាំធ្វើការនៅស្រែ ឬ ក៏លោកធ្វើការនៅស្រែហ្នឹងមួយរដូវ? ឬក៏តិចជាងមួយរដូវនៅកន្លែងនោះ?

**ឆ៖** ធ្វើមួយរដូវៗ ។

**ស៖** ដូច្នេះយើងអាចនិយាយថា ធ្វើស្រែនោះពីររដូវ តើអ៊ីចឹងត្រូវដែរទេ?

**ឆ៖** អត់និយាយ ។

**ស៖** លោកសាក្សី ខ្ញុំនឹកឃើញថា លោកអាចនឹងបដិសេធនូវសំណួរមួយចំនួនដែលថា អាចនឹងដាក់បន្ទុកលើខ្លួនឯង ប៉ុន្តែមិនមែនសំណួរផ្សេងទៀតទេ ។ ប៉ុន្តែ ខ្ញុំព្យាយាមជួយលោក ប្រសិនបើលោកនៅធ្វើស្រែនោះពីររដូវ ។ តើលោកឯកភាពជាមួយខ្ញុំទេ បើខ្ញុំនិយាយថា លោកបាននៅធ្វើស្រែនោះអស់រយៈពេលប្រហែលមួយឆ្នាំ?

**ឆ៖** អត់យល់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីប្រឹក្សាយោបល់ដល់សាក្សី ហើយមុននឹងប្រគល់វេទិកានេះទៅដល់មេធាវីប្រឹក្សាយោបល់សាក្សី អង្គជំនុំជម្រះសូមជម្រះសាក្សីថា សាក្សីអាចបដិសេធនឹងសំណួរដែលសួរ ដែលនាំឲ្យចម្លើយហ្នឹងដាក់ពិរុទ្ធភាពលើខ្លួនឯង ។ ដូចជាថា តើលោកធ្លាប់សម្លាប់មនុស្សដែរទេ? សំណួរនេះជាសំណួរ បើសិនលោកឆ្លើយថា លោកធ្លាប់វានាំឲ្យលោកមានពិរុទ្ធភាព ។ សំណួរនេះ គឺលោកអាចបដិសេធបាន ប៉ុន្តែសំណួរផ្សេងទៀតដែលគ្រាន់តែជាព័ត៌មាន លោកមានករណីកិច្ចត្រូវតែឆ្លើយការណ៍ណា ដែលពិត ដែលលោកបានដឹង បានឮបានឃើញ ហើយនៅចងចាំរហូតដល់ពេលនេះ ។ ប្រសិនបើលោកមិនចងចាំ លោកអាចឆ្លើយថា លោកមិនចងចាំ ។ ប៉ុន្តែ មិនគប្បីមិននិយាយ ឬក៏បដិសេធនូវសំណួរដែលមិនមែនលទ្ធផលនៃចម្លើយតបនឹងសំណួរ ជាបន្ទុកលើខ្លួនឯងនោះឡើយ ។ យល់ដែរឬទេ សាក្សី?

**លោក សេក ជន៖**

អត់សូវយល់ ។ ខ្ញុំអត់សូវយល់ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីប្រឹក្សាយោបល់ ដើម្បីពន្យល់ដល់សាក្សីអំពីការធ្វើសក្ខីកម្មរបស់គាត់។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទនឹងជួបផ្ទាល់ក្នុងពេលបន្តិចទៀតនេះ ។ ហើយខ្ញុំសូមគ្រាន់ធ្វើកំណត់សម្គាល់បន្តិចថា ដោយសារតែសាក្សីមានបញ្ហាការចងចាំមិនបានល្អដូចលោកប្រធានបានមានប្រសាសន៍មុនហ្នឹងអំមិញ ។ ដូច្នេះ អ្នកតាំងសំណួរគួរតែសួរសំណួរខ្លីៗបានន័យថា សំណួរតែមួយក្នុងពេលម្តង ។ កុំសួរសំណួរច្រើនពេក ហើយអាចធ្វើឲ្យសាក្សីគាត់មិនចាំនៅពេល ដែលសំណួរសួរម្តងមានពីរបីសំណួរអីចឹងទៅគាត់ភ្លេច ។ គាត់អាចចាំបានតែចុងក្រោយ ឬមួយគាត់មិនយល់ ។ ដល់តែពេល គាត់មិនយល់គាត់ថាគាត់អត់ឆ្លើយ ។ បាទ ការពិតមកពីគាត់មិនយល់សំណួរអីចឹង ។ ឥឡូវខ្ញុំបាទ

សុំពេលបន្តិច ដើម្បីជួបជាមួយសាក្សី ។ សូមអនុញ្ញាត ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតសូមអញ្ជើញមេធាវី ។

[១១:៣៥:១១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ប្រាង់ស្វ័រ រូ អាចបន្តនូវសំណួរ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក ដន ខ្ញុំព្យាយាមចង់យល់ដឹងទៅតាមលំដាប់លំដោយពេលវេលាដែលលោកបានផ្តល់នៅក្នុងបទសម្ភាសន៍របស់លោក ។ តើលោកមានចាំទេបទសម្ភាសន៍មួយដែលលោកបានផ្តល់ឲ្យខាងអ្នកស៊ើបអង្កេតរបស់ខាងការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ លោកមានចាំទេ?

**ឆ៖** ខ្ញុំអត់សូវចាំទេ ។

**ស៖** នៅក្នុងបទសម្ភាសន៍នោះ លោកបានផ្តល់នូវថ្ងៃខែឆ្នាំជាក់លាក់មួយចំនួន ហើយខ្ញុំគ្រាន់តែចង់បញ្ជាក់ឡើងវិញជាមួយលោកនៅថ្ងៃនេះ ។ ប្រសិនបើថ្ងៃខែហ្នឹង វាត្រឹមត្រូវឬក៏អត់ ឬមួយក៏ថ្ងៃខែឆ្នាំដែលលោកបានផ្តល់ឲ្យនៅក្នុងបទសម្ភាសន៍នោះ គឺវាមិនមែនជាថ្ងៃខែពិតប្រាកដដែលលោកបានចាំនោះទេ ។ អ៊ីចឹង ឥឡូវខ្ញុំចាប់ផ្តើមនិយាយឡើងវិញ នៅក្នុងកិច្ចសម្ភាសន៍នោះលោកបាននិយាយថា ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥ លោកបានចូលមកទីក្រុងភ្នំពេញ ហើយលោកបានចំណាយពេលបីខែនៅក្នុងសាលារៀនរបស់ទ័ព ។ ហើយបន្ទាប់មកទៀត លោកបានទៅធ្វើស្រែ ធ្វើស្រែពីររដូវ ។ តើនោះ គឺជាអ្វីដែលលោកនិយាយនៅក្នុងកិច្ចសម្ភាសន៍នោះឬ?

**ឆ៖** ត្រឹមត្រូវហើយ ខ្ញុំនិយាយសម្ភាសន៍នោះ ត្រឹមត្រូវ ។

**ស៖** ដូច្នេះបើសិនជាយើងព្យាយាម រៀបចំឡើងវិញនូវថ្ងៃខែទៅតាមដែលលោកបានផ្តល់ឲ្យនូវបទសម្ភាសន៍នោះ មានន័យថា លោកបានមកដល់ភ្នំពេញហ្នឹង គឺនៅខែមេសា ហើយបន្ទាប់មកទៀតលោកបានចំណាយពេលបីខែនៅក្នុងសាលាហ្វឹកហាត់កងទ័ព ហើយបន្ទាប់មកទៀត គឺលោកបានធ្វើស្រែពីររដូវ ។ មានន័យថាពីររដូវនោះ គឺត្រូវការចំណាយពេលជាងមួយឆ្នាំ ។ ដូច្នេះមានន័យថា លោកបានមកដល់ ស-២១ ហ្នឹងនៅពាក់កណ្តាលឆ្នាំ៧៦ ។ នេះបើសិនជាយើងគិតទៅតាមកាលវេលាដែល

លោកបានផ្ដល់ឲ្យក្នុងបទសម្ភាសន៍នោះ ។ ដូច្នេះ គឺលោកបានមកដល់ស-២១ ហ្នឹង នៅពាក់កណ្ដាលឆ្នាំ ៧៦ មែនទេ?

[១១:៣៨:២៥]

**ឆ៖** ឆ្នាំ៧៨ ។ ដើមឆ្នាំ៧៨ ។

**ស៖** នុំងគឺជាអ្វីដែលលោកបាននិយាយប្រាប់អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងកិច្ចសម្ភាសន៍នោះ ។ ក៏ប៉ុន្តែលោក សេក ដន បើសិនជាលោកមកដល់នៅឆ្នាំ៧៨ នោះ មានន័យថា លោកមិនមែនអាយុ១១ឆ្នាំទេ គឺលោកអាយុ ១៧ឆ្នាំទៅហើយ ។ មែនទេ?

នេះគឺជាអ្វីដែលខ្ញុំត្រូវនិយាយ មានន័យថា លោកមានសិទ្ធិមិនចាំបាច់ឆ្លើយទៅនឹងសំណួររបស់ខ្ញុំ ។ ប៉ុន្តែ បើសិនជាលោកកើតទៅតាមឆ្នាំរបស់លោកនោះ មានន័យថានៅឆ្នាំ៧៨នោះ លោកមិនមែនអាយុ១១ឆ្នាំទេ ។ តើមានចាំទេថា នៅឆ្នាំណាដែល ប៉ោ ត្រូវបានគេសម្លាប់នោះ? ពីព្រោះលោកបាននិយាយប្រាប់យើងខ្ញុំថា ក្រុមរបស់លោកហ្នឹង គឺមាន ប៉ោ ជាអ្នកដឹកនាំ ។ ហើយតើឆ្នាំណាទៅដែលគាត់ត្រូវបានគេសម្លាប់នោះ?

**ឆ៖** ដើមឆ្នាំដែលខ្ញុំមកនៅហ្នឹង ប៉ុន្តែខ្ញុំអត់ចាំថ្ងៃខែទេ ដែលខ្ញុំទើបមកនៅហ្នឹង ខ្ញុំនៅបានតិច ។

**ស៖** អ៊ីចឹងទៅតាមការរចងចាំរបស់លោកនោះ នៅពេលដែលលោកមកដល់កន្លែងអង្គភាពពេទ្យនោះ គឺ ប៉ោ ជាអ្នកដឹកនាំនៅក្នុងអង្គភាពពេទ្យនោះ មែនទេ?

**ឆ៖** ត្រឹមត្រូវហើយ មេក្រុម ។ គាត់មេក្រុមដឹកនាំកុមារពេទ្យហ្នឹង ។

**ស៖** ហើយលោកក៏បាននិយាយផងដែរ អំពីឈ្មោះ យឿន ហើយនិងអនុរបស់គាត់ដែលក្រោយមកបានឡើងជំនួសគាត់នោះ ហើយលោកបាននិយាយថា យឺន ហ្នឹងគឺថាបានចងកសម្លាប់ខ្លួនឯង ។ អ៊ីចឹងនៅពេលដែល យឿន គាត់ស្លាប់ទៅនោះ តើនរណាគេជាអ្នកឡើងជំនួស យឺន?

**ឆ៖** ដល់ពេលរត់ហើយ ដល់ពេលផ្ទុះហើយ ។ អត់មានចងក្រងថាអ្នកណាជាមេក្រុមនៅឡើយទេ ។

**ស៖** អ៊ីចឹងដូច្នេះ លោកចង់និយាយថា យឺន ហ្នឹងគឺថាគាត់បានចងកសម្លាប់ខ្លួនហ្នឹង គឺមុនខែមករា ឆ្នាំ៧៩ គឺមុនពេលដែលវៀតណាមចូលមកនោះមែនទេ?

**ឆ៖** បាទ, ត្រឹមត្រូវ ។

**ស៖** ហើយតើនរណាគេទៅដែលជាមេ នៅពីលើមេក្រុមរបស់លោកនោះ?

**ឆ៖** កន្លែងក្រុមខ្ញុំហ្នឹង អត់មាន គ មានអីផង មានតែក្រុមពេទ្យហ្នឹងហើយ ។ អត់មានកងរយ កងអីហ្នឹងទេ កន្លែងខ្ញុំមានតែមេក្រុមហ្នឹងហើយ ព្រោះពេទ្យនៅផ្សេងពីគេ ។

[១១:៤៣:១៣]

**ស៖** ប្រសិនបើខ្ញុំនិយាយពាក្យថា ប៉េង តើលោកមានស្គាល់ឈ្មោះ ប៉េង នៅពេលដែលខ្ញុំនិយាយ ឈ្មោះនេះដូច្នេះ?

**ឆ៖** ខ្ញុំធ្លាប់ឮគេហៅធ្លាប់ឃើញដែរ ប៉ុន្តែអត់មាននៅ “គ” ជាមួយខ្ញុំទេ គ្រាន់តែគេថាមេ “គ” ហើយ និងឈ្មោះ ប៉េង ហ្នឹងហើយអ្នកចាប់នោះ ។

**ស៖** អ៊ីចឹងតើគាត់នរណាគេចុះ បើសិនជាគាត់មិនមែនជាអ្នកនៅក្នុងក្រុមរបស់លោក តើ ប៉េង នោះជានរណាគេ? ហើយគាត់មានតួនាទីអ្វីដែរ?

**ឆ៖** គាត់ជាកងរយនៅកងផ្សេងទេ ខ្ញុំគ្រាន់តែទៅមើលអ្នកទោសហ្នឹង គឺគាត់ហ្នឹងអ្នកមេការៗ កងរយហ្នឹង សម្រាប់កាន់ទាហានការពារយាមអ្នកទោសហ្នឹងហើយ ។

**ស៖** តើលោកមានចាំឈ្មោះ ហ៊ា ដែរឬទេ? ឈ្មោះ ហ៊ា?

**ឆ៖** ខ្ញុំធ្លាប់ដែលឃើញមុខដែរ តាហ៊ា ហ្នឹងវៀចមាត់ ។

**ស៖** បាទ, អ៊ីចឹងតើ ហ៊ា ហ្នឹងគាត់មានតួនាទីអ្វីដែរ?

**ឆ៖** តាហ៊ា ហ្នឹង ដឹងគាត់មានតួនាទីជាអ្វីទេ ប៉ុន្តែខ្ញុំធ្លាប់ឃើញគាត់ស្គាល់ ប្រហែលជាមេដែរ ហើយមើលទៅ ។ ជាមេដឹកនាំហ្នឹងដែរ ជាមួយតាឌុច ជាមួយអីនុ៎ងហើយមេធំៗ ។

**ស៖** លោកចាំទេនៅពេលដែលចៅក្រម ធូ មណី បានសួរសំណួរទៅលោកនោះ ហើយថាលោក ស្គាល់ថ្នាក់ដឹកនាំអ្នកណាទៀតទេ ពេលនុ៎ងលោកបាននិយាយថា លោកមិនបានស្គាល់ទេ ប៉ុន្តែឥឡូវនេះ មានន័យថាលោកបានស្គាល់ថ្នាក់ដឹកនាំនៅទីនោះ? ដូច្នេះ ខ្ញុំនឹងបន្តព្យាយាមឲ្យលោកចងចាំឡើងនូវអ្វី ដែលលោកបានឆ្លងកាត់ ។ ចុះឈ្មោះ ទ្រី វិញ តើលោកស្គាល់ ទ្រី ដែរឬទេ?

**ឆ៖** តាទ្រី ខ្ញុំបានធ្លាប់បានឃើញគាត់នៅប្រហែលជា ខ្ញុំមកនៅហ្នឹងប្រហែលជាមួយខែ ពីរខែ ដែរ បានឃើញគាត់ ស្គាល់ឈ្មោះគាត់ដែរ ។ គាត់ពេទ្យជាមួយ តាប៉ោ, តាទ្រី, តាឃឹន អីហ្នឹង ដឹង ប៉ុន្តែមិនដឹងពេទ្យហ្នឹងរៀនពីណាមកទេ ខ្ញុំអត់ដឹងដែរ ។ គ្រាន់តែស្គាល់ឈ្មោះមនុស្សហ្នឹងនៅហ្នឹងដែរ ។ ប៉ុន្តែស្លាប់អស់ហើយ ពួកអស់នេះ ។

[១១:៤៧:១៩]

**ស៖** ដូច្នេះ គឺលោកបានឃើញគាត់តែមួយខែ ឬក៏ពីរខែទេ មានន័យថានៅដើមឆ្នាំ៧៨ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវសំណួរដែលខ្ញុំនិយាយអំមិញ ត្រឹមត្រូវ ។

**ស៖** ដូច្នេះ ខ្ញុំចង់ប្រាប់លោកថា មានសាក្សីមួយចំនួនដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គសវនាការនេះបាននិយាយថា ទ្រី គឺគាត់នៅស-២១ ហ្នឹងរហូតដល់ចុងបញ្ចប់នៃជំនាន់នោះ នៃរបបនោះ ហើយបានរត់ចេញទៅនៅពេលរបបនោះបែក ប៉ុន្តែលោកបាននិយាយផ្សេងពីនេះមែនទេ?

**ឆ៖** កាលនោះ គេចាប់គាត់ទៅបាត់ ខ្ញុំថាស្លាប់ហើយ អត់មាននៅទេ ។

**ស៖** តើលោកអាចប្រាប់ពួកយើងបានទេ នៅពេលដែលលោករត់ចេញពីស-២១ នោះ តើលោកបានរត់ចេញជាមួយនរណាខ្លះកាលពីខែមករា ឆ្នាំ១៩៧៩ នោះ?

[១១:៤៨:៤៣]

**ឆ៖** កាលនុ៎ងរត់ចេញទាំងអស់គ្នា កុមារៗច្រើន ខ្ញុំរត់ចេញជាមួយអ្នកនៅស្រុកភូមិជាមួយខ្ញុំដូចជា សុន ដូចអី ដែលគេមកជាមួយខ្ញុំហ្នឹង ។ ដល់រត់ទៅៗ រត់ទៅតែបីនាក់ទៀត នាំគ្នាមុនដំបូងទៅជាមួយគេ ដល់មានគេបាញ់អី ខ្ញុំរត់បែកគ្នាទៅរកម៉ែរកឪខ្ញុំបីនាក់ផ្សេង ។ អត់មាននៅអីជាមួយគេទៀតទេ ខ្ញុំរត់បីនាក់ ។ សុទ្ធតែប្រុសៗកុមារៗ សុន នោះគេគ្រាន់ធំ ហើយខ្ញុំតូច, ភា នោះតូចពីរនាក់ធំម្នាក់ ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារ, ដូចជាការប្រើប្រាស់ពេលវេលារបស់លោកលើសច្រើនដែរប្រាំពីរមីនុតហើយ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកប្រធាន! ខ្ញុំចង់ឲ្យលោកប្រធានធ្វើការពិចារណាផងដែរទៅលើ ពេលវេលាដែលមេធាវីបានចំណាយពេលជាមួយនឹងកូនក្តីរបស់គាត់ ដែលជាសាក្សីនោះ ហើយដែលមិនគួរជាពេលវេលាត្រូវកាត់ពីពេលវេលាដែលខ្ញុំត្រូវសួរសាក្សីនេះទេ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ជាក់លាក់លោកត្រូវការពេលវេលាប៉ុន្មានទៀត ដើម្បីអង្គជម្រះសម្រេច ពីព្រោះវាគោលការណ៍ដែលយើងបានបែងចែកពេលវេលារួចហើយ ។ ហើយអង្គជំនុំជម្រះ ក៏មានការគិតថា

វាមានប្រយោជន៍ទើបអង្គជំនុំជម្រះបានអនុញ្ញាតពន្យារពេលលោករហូតដល់ប្រាំពីរមីនុតនោះ ។ អ៊ីចឹងការសម្រេចត្រូវលោកមានត្រូវការបន្ថែមទៀត ដើម្បីយើងធ្វើការ ។ ហើយពេលវេលាសម្រាប់មួយព្រឹកគឺនៅការកត់សម្គាល់របស់ជនជាប់ចោទ ចំពោះសក្ខីកម្មរបស់សាក្សី ។ ហើយប្រហែលជាឱ្យធ្វើសាក្សីឆ្លើយតបនឹងការកត់សម្គាល់របស់ជនជាប់ចោទផងដែរ អំពី-- គាត់ព្រឹកមិញគាត់កត់សម្គាល់មិនច្បាស់លាស់រវាងមិនទទួលស្គាល់សាក្សីនេះថាជា បុគ្គលិកពេទ្យនៃមន្ទីរស-២១ ។

[១១:៥០:៥៧]

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកប្រធាន ខ្ញុំត្រូវការពេលវេលាតែបីនាទីទៀត តែប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! អង្គជំនុំជម្រះអនុញ្ញាត ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រ៉ូ៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក ដន តើលោកអាចប្រាប់យើងខ្ញុំបានទេថា នៅពេលដែលលោករត់ចេញកាលពីថ្ងៃទី៦ ឬក៏ថ្ងៃទី៧ ខែមករា ៧៩ នោះតើលោកបានរត់ចេញជាមួយមេដឹកនាំណាមួយដែរចេញពីស-២១នោះ?

**ឆ៖** រត់គ្នាច្រើនៗ ដឹងអ្នកណាដឹកនាំអ្នកណាទេ ជ្រួលច្របល់ក្នុងការភ័យផង ។ អត់បានដឹងថាអ្នកណាដឹកនាំរត់ អ្នកណាអី ប៉ុនដល់ពេលនេះរត់គេរត់ នាំឱ្យថយៗចេះតែថយទៅ រួចខ្ញុំលែងបានទៅមើលកន្លែងអគារនុំងឯងនុំង ថយខ្លួនហើយ ។ ឈប់ទៅហើយ ។ ត្រៀមនឹងរត់នុំង ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

ខ្ញុំមិនមានសំណួរទៀតទេ លោកប្រធាន សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់អំពីសក្ខីកម្មរបស់សាក្សីនេះរូប ។ ហើយអង្គជំនុំជម្រះ សូមជម្រាបដល់ជនជាប់ចោទថា លោកអាចធ្វើការកត់សម្គាល់ក្នុងកម្រិតនៃសក្ខីកម្មរបស់សាក្សីរូបនេះតែប៉ុណ្ណោះ ដោយមិនអនុញ្ញាតឱ្យលោកធ្វើការកត់សម្គាល់ពាក់ព័ន្ធដល់ទៅសាក្សីផ្សេងទៀតទេ ទោះបីសាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយ ឬក៏សាក្សីមិនទាន់ផ្តល់សក្ខីកម្មក៏ដោយ ។ សូមអញ្ជើញ ។

[១១:៥៣:១៤]

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! សេចក្តីបញ្ជាក់របស់ខ្ញុំ ជូនអង្គសវនាការពេលនេះ អត់ប្លែកអីពីព្រឹកទេ ។ ទីមួយ លក្ខណៈសម្បត្តិរបស់ សេក ដន ជាលក្ខណៈសម្បត្តិកូនកសិករនៅជើងភ្នំ ។ ការចងចាំក៏តិច កម្រិតវប្បធម៌ក៏ទាប ។ បើសិនជាយើងគិតកត្តានេះ ខ្ញុំគិតថា ប្រហែលជាត្រូវបញ្ជូនមកស-២១មែន ក៏ប៉ុន្តែដោយឃើញហេតុផលនៃសក្ខីកម្មរបស់គាត់ វាខុសពេលវេលាច្រើន ឧទាហរណ៍ដូចគាត់និយាយថា ប្រធានរបស់គាត់គឺ មិត្តប៉ោ ។ មិត្តប៉ោ អត់រស់នៅដល់ឆ្នាំ១៩៧៨ ទេ ស្លាប់មុននោះមូលហេតុគឺ មិត្តប៉ោ ពេលដែលមិត្ត ហ៊ី រាកមួលគាត់ឲ្យ *បេម៉ាកស្បូល* ដល់ទៅអា *បេម៉ាកស្បូល* ហ្នឹងទៅធ្វើទុក្ខធ្វើឲ្យគាត់ឈឺខ្លាំង ដូចជាប្រកាច់ផងមិនដឹងទេ ខ្ញុំរាយការណ៍ជូនមេ ជូនលោកគ្រូ សុន សេន លោកគ្រូ សុន សេន គាត់ដឹងថា ឱ! *បេម៉ាកស្បូល* មានជាតិ*អេសេទិក* មិត្ត ឌុច ចាប់ ខ្ញុំក៏ឲ្យគេចាប់ ប៉ោ កម្ទេចទៅ ។ ដូច្នេះ គាត់ចូលមកត្រូវនៅក្រោម មិត្តទ្រី ពេទ្យពីមុនមកខ្ញុំអត់និយាយទេ ពេទ្យមុនមិត្ត ប៉ោទៅទៀត ខ្ញុំអត់និយាយទេ ។ មាន១ពេទ្យមួយទៀត ។ ដូច្នេះ ការដែលឲ្យសក្ខីកម្មឆ្គងបែបនេះ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍សង្ស័យថា គាត់ហាក់ដូចជាមិនមែនបុគ្គលិមន្ទីរស-២១ទេ នេះលក្ខណៈទីមួយ ។

[១១:៥៥:១០]

លក្ខណៈទីពីរ ក្នុងមួយចំណោមអ្នកកំពង់ឆ្នាំងគ្នាគាត់ គាត់ស្គាល់៤នាក់ គឺរូបគាត់ មិត្តម៉ុន ពេទ្យ ហើយនិងមិត្តយឹម ដែលខ្ញុំមិនដែលដឹង ។ ហើយទីពីរទៀត គាត់និយាយអំមិញអំពីរឿង មិត្តយ៉ឹន ទៅចងកអត្តឃាត ខ្ញុំធ្វើប្រធានស-២១នោះ ដូចមិនដែលឮអ្នកណានែ៎-- មិនឮអ្នកណានិយាយពីរឿងស-២១ចងកអត្តឃាតទេ ។ ពេលដែលខ្ញុំទៅទទួលភារកិច្ចដំបូងជាអនុប្រធាន មានមែន មានម្នាក់ស្លាប់ដោយសារខ្សែភ្លើងឆក់ ទៅអូសស័ង្កសីពេលភ្លៀងប៉ះខ្សែភ្លើងឆក់ ខ្ញុំរាយការណ៍ជូនមេ ។ រួចបើនិយាយអំពីឡានពេទ្យចូលទៅដល់ផ្លូវមុខគុកនោះ បើតាមខ្ញុំចាំផ្លូវមុខគុកនោះ គឺផ្លូវលេខ១១៣ គ្មានឡានណាបានចូលទៅដល់ស-២១ ដល់ផ្លូវនោះ ដល់មុខគុកទេ គឺចូលតាមផ្លូវលេខ៣៦០ ទៅដល់កន្លែងទទួលត្រង់អក្សរដែលខ្ញុំដាក់ *អេទ* ចប់ហើយ ។ អត់មាននរណាបានចូលទេ ក្រៅតែពីឡានមេគឺឡានលោកគ្រូ សុន សេន អញ្ជើញទៅម្តង ខ្ញុំឈរចាំជាមួយមិត្ត ហ៊ី នៅមុខគុកនោះ មុខទ្វារចូលគុក មានតែឡានមួយហ្នឹងគត់ចូលដល់កន្លែងហ្នឹង ។

ដូច្នេះសក្ខីកម្មអស់នេះ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍ថា វាហាក់ដូចជាក្តាប់សភាពការណ៍នៅស-២១ពិតមិនបាន ។ ខ្ញុំចាប់អារម្មណ៍ថា គាត់និយាយសក្ខីកម្មជាទូទៅរបស់គាត់ មានលក្ខណៈរួមត្រឹមត្រូវហើយ មានអ្នកទោសឈឺ មានអ្នកទោសស្លាប់ ថ្នាំអាចម៍ទន្សាយអីៗ ។ ហើយគាត់ថា គាត់ស៊ីថ្នាំទាំងកម្បង់អីនោះវាមិនអី ។ ថ្នាំហ្នឹងមែនមាន គឺវីតាមីនសេ ធ្វើអាយ ។ ដូច្នេះ សភាពការណ៍សក្ខីកម្មជាទូទៅរបស់គាត់ល្មមទទួលបាន ក៏ប៉ុន្តែសក្ខីកម្មដែលជាក់ស្តែងលើប៉ុន្មានបញ្ហានោះ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍សង្ស័យ ។

នេះសូមរាយការណ៍ជូនប៉ុណ្ណេះ សូមគោរព ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់ដឹងបន្តិចថា តើជនជាប់ចោទមានឯកសារអ្វីដែលអាចឲ្យយើងធ្វើការកំណត់នៅកាលបរិច្ឆេទដែលថា ហ៊ វ ត្រូវបានទទួលការរងគ្រោះពីថ្នាំដែលបានផ្តល់ឲ្យគាត់នោះ? ហើយតើអាចមានឯកសារណាដែលថា ប៉ោ ហ្នឹងត្រូវបានគេសម្លាប់នោះដែរឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រម! ឈ្មោះ ប៉ោ ដែលចាប់នៅមន្ទីរស-២១ ខ្ញុំរកមិនឃើញទេ ព្រោះខ្ញុំអត់ចាំវង្សត្រកូលគេ ឈ្មោះត្រកូលគេ ។ ឯកសារដែលអាចរកឲ្យឃើញថា ប៉ោ ត្រូវសម្លាប់ គឺសេចក្តីសារភាពរបស់ ប៉ោ ខ្ញុំជឿថា មាននៅស-២១ ។ ដូច្នេះ នៅសល់ពេលនុ៎ង ថ្ងៃខែឆ្នាំដែលចាប់នោះច្បាស់នៅនុ៎ង ។ នេះគឺសូមបញ្ជាក់ជូនលោកប្រធានប៉ុណ្ណេះដោយគោរព អ៎! លោកចៅក្រមប៉ុណ្ណេះដោយគោរព ។

[១១:៥៩:០៧]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ម៉េចទៅ សេក ដន ។ មានហេតុផលអ្វីអះអាងចំពោះអង្គសវនាការទាំងមូលទេ អំពីថាលោកពិតជាបុគ្គលិកពេទ្យដែលជាកុមារពេទ្យធ្វើការជាអ្នកចែកថ្នាំលាងរបួសដល់អ្នកទោសនៅក្នុងមន្ទីរស-២១ អគារ “C” ក្រៅពីលោកនិយាយរួចហើយនោះ តើមានអ្វីដែលមានអំណះអំណាងឲ្យបានជាក់លាក់ជាងនេះទេ ដើម្បីតបទៅនឹងការកត់សម្គាល់របស់ជនជាប់ចោទអំមិញ គឺភាពមិនប្រាកដប្រជារវាងភាពថាជឿលោកជឿជាក់ថាលោកជាបុគ្គលិកក្រុមពេទ្យនៅមន្ទីរស-២១ ឬក៏មិនមែនទេនោះ ។

**ធ៖** ខ្ញុំនៅនុ៎ងមែនឲ្យច្បាស់លាស់ មានអ្នកមកជាមួយខ្ញុំហ្នឹង ក៏គេស្គាល់ថាខ្ញុំកូនពេទ្យហ្នឹងដែរ។

**ស៖** អ្នកមកជាមួយលោកឈ្មោះអ្វីទៅ?

**ធ៖** ដូចឈ្មោះ មាន អីគេស្គាល់ថា ខ្ញុំដែរថា កូនពេទ្យនេះ ។

**ស៖** ឈ្មោះ មាន អីឈ្មោះ មាន ទៅ?

**ធ៖** ខ្ញុំអត់សូវស្គាល់យាយតា សាក្សីវានេះ ប៉ុនមកជាមួយខ្ញុំហ្នឹងដែរ ។

**ស៖** ឈ្មោះ មាន ហ្នឹងគាត់ធ្វើការអីកាលពីនៅមន្ទីរស-២១? ចាំៗមានភ្លើងក្រហមសឹមឆ្លើយ ន៎ែ កាលណាអ៊ីចឹងលោក សំឡេងរបស់លោកមិនចូលទៅក្នុងការស្តាប់របស់អ្នកទាំងអស់ហ្នឹងទេ គិតទាំងអង្គជំនុំជម្រះផង ហើយនិងការកត់ត្រាសម្តីរបស់លោកនៅក្នុងកំណត់ហេតុក៏អត់បានកត់ដែរន៎ែ ។ ឈ្មោះ មាន អំមិញដែលលោកថា ហ្នឹងតើគាត់ធ្វើការងារអ្វីកាលពីសម័យដែលធ្វើការជាមួយលោកនៅក្នុងមន្ទីរស-២១ នោះ?

**ធ៖** គាត់នោះ គាត់អ្នកយាមទេ ប៉ុនស្គាល់ៗថា ខ្ញុំនេះឈ្មោះ ដន កូនពេទ្យ ។

[១២:០១:៥៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោក សេក ដន ដែលលោកបានអញ្ជើញមកធ្វើសក្ខីកម្មនៅចំពោះមុខអង្គសវនាការសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមការកោះហៅ។ ហើយអង្គជំនុំជម្រះក៏បានដឹងផងដែរថា អំពីភាពលំបាកនៃការផ្តល់សក្ខីកម្មរបស់លោក ដោយហេតុផលនៃការសួរពីច្រើនភាគី ហើយចំពោះរូបលោក ។ ហើយទីពីរ គឺអង្គហេតុដែលបានកើតមានឡើងនេះ គឺអាចថា និយាយជាងសាមសិបឆ្នាំមកហើយ សាមសិបបី សាមសិបបួន ឬក៏សាមសិបពីរឆ្នាំកន្លងមកហើយ ។ ហើយកាលណោះ គឺលោកមានវ័យក្មេងផង ហើយកម្រិតនៃការយល់ដឹងផ្នែកខាងចំណេះដឹងទូទៅក៏មានបញ្ហាដោយសារខ្វះការរៀនសូត្រអ៊ីចឹងហើយនាំឲ្យភាពចងចាំរបស់លោកហ្នឹង មានបញ្ហា ។ តែទោះបីយ៉ាងណាក៏ដោយ គឺអង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោកប្រឹងប្រែងអស់ពីលទ្ធភាពនៅក្នុងការបំពេញករណីយកិច្ចក្នុងនាមជាសាក្សីឆ្លើយផ្តល់ព័ត៌មានជូនដល់អង្គសវនាការ និងសំណួរពាក់ព័ន្ធនានាពីភាគីនោះ ។

ហើយឥឡូវនេះ គឺអង្គជំនុំជម្រះអស់សំណួរចំពោះលោកហើយ ហើយអនុញ្ញាតឲ្យលោកវិលត្រលប់ទៅលំនៅដ្ឋានវិញបានហើយ ។ ហើយមន្ត្រីតុលាការសម្របសម្រួលដល់លោក សេក ដន ដើម្បី

ធ្វើការជូនគាត់ទៅជួបជាមួយនឹងផ្នែកខាងគាំពារសាក្សី និងអ្នកជំនាញដើម្បីឲ្យខាងអង្គភាពនោះរៀបចំជូនគាត់ទៅលំនៅដ្ឋានរបស់គាត់វិញ ។

ហើយអង្គជំនុំជម្រះដល់ពេលសវនាការនេះ គឺដល់ពេលត្រូវពិសាថ្ងៃត្រង់ហើយ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាក សម្រាប់ដំណើរការសវនាការថ្ងៃនេះត្រឹមនេះ ។ ហើយសវនាការថ្ងៃនេះ លើកទៅបន្តនៅរសៀលវេលាម៉ោងមួយកន្លះ ។ ហើយចាប់ពីម៉ោងមួយកន្លះទៅ អង្គជំនុំជម្រះនឹងធ្វើសក្ខីកម្មចំពោះសាក្សីមួយរូបទៀតគឺ KW-21 ហ្នឹងសូមភាគី និងសាធារណជនជ្រាប ។

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការវិញ ឲ្យបានមុនម៉ោងមួយកន្លះ ។

[១២:០៤:១៨]

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:០៥នាទី ដល់ម៉ោង ១៣:៣២នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សីជាបន្តទៀត ហើយសាក្សីដែលស្តាប់នាពេលនេះ គឺសាក្សី KW-21 ។

សូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន។ មុននឹងអនុញ្ញាតឲ្យសាក្សីចូលមកសាលសវនាការ ខ្ញុំសូមអនុញ្ញាតក្នុងនាមមេធាវីការពារដើម្បីសម្តែងនូវសិទ្ធិរក្សាសិទ្ធិដ៏ម៉ឺងម៉ាត់មួយទាក់ទងអង្គហេតុមួយដែលថា យើងមិនមានអត្ថបទបកប្រែជាភាសាបារាំងនៅចម្លើយរបស់សាក្សីនេះ ដោយគាត់បានផ្តល់ទៅឲ្យសហចៅក្រមស៊ើបអង្កេតនោះ នៅក្នុង D22\13 យើងមានអត្ថបទជាភាសាអង់គ្លេស ហើយជាឯកសារចុះថ្ងៃទី២៤ តុលា ឆ្នាំ២០០៧ ។ មួយឆ្នាំកន្លះក្រោយមក យើងក៏មិនមានអត្ថបទបកប្រែជាភាសាបារាំងនៃឯកសារនេះដដែល ។ ហើយខ្ញុំពិនិត្យឃើញថាវាជាការមិនធម្មតាក្នុងចំណុចនេះ ។

ដូច្នេះ ខ្ញុំសូមស្នើអង្គជំនុំជម្រះ សូមឲ្យខាងរដ្ឋបាលធានាថា កុំឲ្យមានស្ថានភាពនេះកើតឡើងជាថ្មីម្តងទៀត ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការអញ្ជើញសាក្សី KW-21 ចូលមកកាន់បន្ទប់សវនាការ ។

*[សាក្សី KW-21 ចូលកាន់បន្ទប់សវនាការ]*

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សាក្សី! តើលោកមានឈ្មោះអ្វីដែរ?

**លោក ឡាច មាន៖**

**ឆ៖** បាទ, ខ្ញុំមានឈ្មោះ ឡាច មាន ។

**ស៖** ក្រៅពីឈ្មោះ មាន តើលោកដែលប្រើប្រាស់ឈ្មោះអ្វីផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ, ខ្ញុំអត់មានឈ្មោះក្រៅទៀតទេ ។

**ស៖** លោក ឡាច មាន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** អាយុ៥២ឆ្នាំ ។

**ស៖** សព្វថ្ងៃនេះ តើលោកប្រកបមុខរបររកស៊ីអ្វីដែរ?

**ឆ៖** ខ្ញុំបាទរកស៊ីធ្វើស្រែ ។

[១៣:៣៧:២១]

**ស៖** តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ កាលពីព្រឹកមិញថា លោកពុំមានចំណងញាតិលោហិត ឬក៏ញាតិពន្ធ ឬសហព័ន្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ ហើយថាលោកបានស្បថរួចហើយ ។ តើជាពិតដែរឬទេ?

**ឆ៖** ការពិត ។

**ស៖** រំឭកឡើងវិញ សាក្សីមុននឹងឆ្លើយសាក្សីមើលភ្លើងក្រហមនៅក្បាលមីក្រូនេះ ដើម្បីជាសញ្ញាសម្គាល់មុននឹងលោកចាប់ផ្តើមនិយាយ ដើម្បីឲ្យសំឡេងរបស់លោកហ្នឹងចូលទៅក្នុងប្រព័ន្ធនៃការផ្សព្វផ្សាយហ្នឹងដល់អ្នកបកប្រែ ហើយដល់អ្នកប្រតិចារឹក ដើម្បីបកប្រែជូនដល់ភាគីផ្សេងទៀតដែលមិនប្រើប្រាស់ភាសាខ្មែរ ឬក៏ប្រើប្រាស់ភាសាខ្មែរដែរ ប៉ុន្តែខាងក្រៅនោះស្តាប់អត់បានទេ ប្រសិនបើលោកមិនភ្ជាប់ជាមួយនឹងប្រព័ន្ធសំឡេងនៅក្នុងសាលសវនាការនេះ ។ តើលោកយល់ដែរទេ?

**ឆៈ** យល់ (យី! ចេះតែច្រឡំ ទាន់បើកភ្លើង) ។

**សៈ** ឥឡូវនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់លោកក្នុងនាមលោកជាសាក្សី លោក ឡាច មាន ក្នុងនាមលោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏ការសុំឲ្យធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលោកខ្លួនលោក គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង ។ មានន័យថា ដោយសារតែចម្លើយ ឬក៏អំណះអំណាងនោះ នាំឲ្យលោកប្រឈមនឹងការចោទប្រកាន់ ។ ទន្ទឹមនឹងនេះ លោក ឡាច មាន ក្នុងមានលោកជាសាក្សី លោកមានករណីកិច្ចនិយាយការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ ដោយផ្ទាល់ ហើយសុំរំឭកថា មិនគប្បីឆ្លើយជាដោយសន្និដ្ឋានទេ ។ តើលោកយល់ដែរឬទេ?

**ឆៈ** បាទ, ខ្ញុំយល់ ។

**សៈ** លោក ឡាច មាន តើលោកអាចនិយាយរៀបរាប់ប្រាប់អំពីប្រវត្តិរបស់លោកនៅក្នុងអំឡុងពេលចន្លោះចាប់ពីឆ្នាំ១៩៧០ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើរូបលោករស់នៅទីកន្លែងណាខ្លះ? ហើយលោកធ្វើអ្វីខ្លះ? បញ្ជាក់ឡើងវិញ គឺអំឡុងពេលឆ្នាំ១៩៧០ រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ។

[១៣:៤០:១២]

**ឆៈ** ខ្ញុំប្រវត្តិខ្ញុំតាំងពីឆ្នាំ៧០ រហូតដល់៧៥ ពីប្រវត្តិខ្ញុំពីដំបូងពីខ្ញុំឆ្នាំ៧០ ខ្ញុំនៅជាមួយឪពុកម្ដាយធ្វើស្រែ បន្ទាប់មកខ្ញុំបួសជាលោកសង្ឃ នៅឆ្នាំ១៩៧២-៧៣ ។ បន្ទាប់មកទៀត គេឲ្យខ្ញុំទៅនៅប្រចាំការសែងរបួសតាមអង្គភាពឃុំ ។ បន្ទាប់មកទៀត គេឲ្យខ្ញុំធ្វើឈ្លបឃុំ នៅឃុំផ្លូកវៀន បន្ទាប់មកទៀតរហូតដល់ឆ្នាំ៧៤ ។ ខ្ញុំ ចុងឆ្នាំ៧៤ ខ្ញុំទៅនៅអង្គភាពទ័ពស្រុក ជាយោធា ជាកងទ័ព នៅទ័ពស្រុករហូតដល់ឆ្នាំ ១៩៧៥ ។

បន្ទាប់ពីឆ្នាំ១៩៧៥ បានចប់សង្គ្រាមហើយ ខ្ញុំនៅអង្គភាពនេះគេបញ្ជូនឲ្យខ្ញុំមកនៅបឹងទំពុន មកនៅចិញ្ចឹមជ្រូក បោចត្រកួន ចិញ្ចឹមជ្រូក ។ បន្ទាប់ពីនោះមកទៀត នៅឆ្នាំហ្នឹងដដែល គេបញ្ជូនខ្ញុំឲ្យទៅនៅរៀនបច្ចេកទេសយោធា លត់ដំនៅសាលាម៉ាជួរដងស្ទឹងតាខ្មៅ ។ អស់រយៈពេល លត់ដំអស់រយៈពេលជិតបួនខែ បន្ទាប់មក ខ្ញុំគេបញ្ជូនខ្ញុំឲ្យមកនៅតាខ្មៅនៅជាអង្គភាព ។ កាលហ្នឹងមិនច្បាស់ មិនដឹងអង្គភាពអីទេ តែនៅភារកិច្ចជាអ្នកយាមអ្នកទោស ដើរស្រោចបន្លែនៅតាម នៅអង្គភាពតាខ្មៅ ។ នៅទីនោះខ្ញុំមិនបានយូរប៉ុន្មានទេ ប្រហែលជាពីរបីប៉ុណ្ណោះទេ គេឲ្យខ្ញុំមកនៅជិតផ្សារថ្មីកន្លែង *ប៉េហ្ស៊ី* ។

ខ្ញុំនៅ *ប៉េហ្ស៊ី* អស់រយៈប្រហែលជាជិតប៉ុន្មាន ជិតមួយឆ្នាំ ឬជាងមួយឆ្នាំក៏មិនដឹងដែរ ខ្ញុំមិនបាន

ចាំច្បាស់ ។ ភារកិច្ចខ្ញុំពេលនោះ គឺឲ្យខ្ញុំយាមអ្នកទោសតាមផ្ទះ តាមបន្ទប់ ។ អស់រយៈពេលហ្នឹង នៅប្រហែលជាដើមឆ្នាំ ឬចុងឆ្នាំ៧៧ ដើមឆ្នាំ៧៨ ឬ៧៦ ក៏មិនដឹងដែរ ខ្ញុំមិនបានច្បាស់ ត្រង់ហ្នឹងវាមិនបានចាំ ។ គេរើពីនោះមកនៅមន្ទីរស-២១ នៅគុកទួលស្លែង ។ នេះជាប្រវត្តិរបស់ខ្ញុំរហូតមកដល់ឆ្នាំ៧៩ ទើបចេញពីក្រុងភ្នំពេញ ។ នេះជាប្រវត្តិរបស់ខ្ញុំ ចង់ប៉ុណ្ណេះ ។

**ស៖** លោកនិយាយអំមិញថា ពីចន្លោះ៧០ ទៅ៧៣ គឺលោកនៅជាមួយឪពុកម្ដាយ ហើយបានបួសក្នុង៧៣ នៅឃុំធ្លកវៀន នៅក្នុងស្រុកអីដែរ ក្នុងខេត្តអីដែរ ធ្លកវៀនហ្នឹង?

**ឆ៖** ខ្ញុំនៅបួសជាលោកសង្ឃនៅក្នុងឃុំធ្លកវៀន ហ្នឹងជា នៅពីដើម ពីសង្គមគេហៅស្រុកកំពង់ត្រឡាចលើ បច្ចុប្បន្នគេហៅស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

[១៣:៤៤:៥០]

**ស៖** លោកនិយាយថា លោកក្រោយពីសឹក លោកទៅធ្វើជាអ្នកសែងអ្នករងរបួសពីសមរភូមិ ឬក៏ដឹកសែងដឹកជញ្ជូនស្បៀងអីជាដើម ហើយរហូតដល់៧៤ លោកចូលទៅអង្គភាពទ័ពស្រុករហូតដល់ឆ្នាំ៧៥ ។ តើលោកនៅក្នុងអង្គភាពទ័ពស្រុកឈ្មោះអ្វីដែរ ដែលលោកធ្វើការកាលនោះ?

**ឆ៖** ខាងអង្គភាពទ័ពស្រុកកាលនោះជាអង្គភាព-- ខ្ញុំអត់ដឹងដែរកាលនោះ គេហៅអង្គភាពទ័ពស្រុកៗ តែមិនដឹងជាអង្គភាពអីទេ អង្គភាពទ័ពយោធា ។

**ស៖** កាលនោះស្រុកនោះនៅកំពង់ត្រឡាច ឬក៏កំពង់ត្រឡាច ឬក៏សេរីសាមគ្គីមានជ័យ ឬក៏កំពង់ត្រឡាចបច្ចុប្បន្ន?

**ឆ៖** កាលនោះស្រុក គេហៅស្រុក១២ ស្រុកកំពង់ត្រឡាចលើ បច្ចុប្បន្ននេះគេហៅស្រុកសាមគ្គីមានជ័យ ។

**ស៖** លោកអាចរៀបរាប់ជូនដល់អង្គសវនាការបានដែរឬទេ អំពីកិច្ចការដែលលោកធ្វើនៅគុកដែលលោកអះអាងថានៅតាខ្មៅ? ហើយតើស្ថានភាពអ្នកទោសដែលលោកធ្វើការយាមកាមនៅតាខ្មៅនុ៎ងវាមានស្ថានភាព ឬក៏ទិដ្ឋភាពយ៉ាងម៉េចដែរ ដែលលោកបានឃើញ ហើយនៅចងចាំរហូតដល់បច្ចុប្បន្ន?

**ឆ៖** កាលនោះសភាពអ្នកទោសនៅតាខ្មៅ តាមជាការសន្និដ្ឋានរបស់ខ្ញុំ គឺអ្នកទោសដែលគេលែងសួរចម្លើយ ឬក៏គេលែងត្រូវការ គេទៅដាក់ឲ្យធ្វើពលកម្ម ស្រោចបន្លែ ឬក៏ធ្វើជាតុ ជាទូ អីនៅកន្លែងនុ៎ង ។

**ស៖** អ្នកទោសកាលនោះ គឺដឹងប្រវត្តិរបស់អ្នកទោសទាំងអស់ហ្នឹងទេ ថាជាអតីតជាទាហាន ឬជាអ្នករាជការ ឬមន្ត្រីរដ្ឋការក្នុងរបប លន់ នល់? ឬក៏ជាកម្មាភិបាលបុគ្គលិកបដិវត្តន៍?

**ឆ៖** កាលនោះខ្ញុំមិនបានដឹងទេ ព្រោះការងាររបស់អស់ទាំងនេះជាការងាររបស់គេ ខ្ញុំអត់មានភារកិច្ចដឹងថា ជាអ្នកទោសអ្វី ឬអ្នកទោសអ្វី គឺខ្ញុំអត់បានដឹងទេ ព្រោះគេខ្ញុំឱ្យយាម គឺការពារអ្នកទោសកុំឱ្យតែរត់រួចតែប៉ុណ្ណោះ គេមិនបានប្រាប់ថាអ្នកទោសនេះ ជាអានេះ ជានោះ ឬជាអ្វី គឺគេអត់ឱ្យខ្ញុំដឹង ។

[១៣:៤៨:០៩]

**ស៖** កាលនោះគុកដែលលោកនិយាយថា លោកធ្វើ-- គេឱ្យទៅយាមអ្នកទោសស្រោចបន្លែស្រោចអីផ្សេងៗនៅតាខ្មៅហ្នឹង ទីតាំងនុំងជាក់លាក់នៅកន្លែងស្អីគេ? ជាមន្ទីរពេទ្យ? ជាសាលារៀន? ឬក៏កន្លែងដែលគេធ្វើថ្មី សម្រាប់ធ្វើជាគុកតែម្តង?

**ឆ៖** កន្លែងនុំង ពីសង្គមមកគេដាក់ថា ពេទ្យ កន្លែងពេទ្យឆ្កួតពីដើម ពីសង្គមចាស់ ។

**ស៖** ចំនួនអ្នកទោសកាលពីលោកចាត់ឱ្យទៅយាម ធ្វើជាអ្នកយាមអ្នកទោសនៅអតីតមន្ទីរពេទ្យឆ្កួត យកធ្វើជាគុកនោះ ។ តើមានចំនួនប្រហែលប៉ុន្មាននាក់ទៅ នៅក្នុងអំឡុងពេលដែលលោកទៅយាមកាមនៅទីនោះ?

**ឆ៖** កាលនោះអ្នកទោសច្រើនដែរ ប្រហែលខ្ទង់មួយរយ ឬក៏តិចជាងមួយរយ ឬក៏មួយរយលើសប៉ុណ្ណឹង អ្នកទោសនៅកន្លែងនោះ ។

**ស៖** មុនពេលលោកចាកចេញពីកន្លែងគុកដែលយកមន្ទីរពេទ្យឆ្កួតតាខ្មៅមកជាគុក ហើយមានអ្នកទោសប្រហែលជាមួយរយនាក់ ។ នោះសួរថា មុនពេលលោកចាកចេញមក តើអ្នកទោសប្រហែលមួយរយនាក់ហ្នឹង គេទៅឯណា? លោកដឹងដែរឬទេ?

**ឆ៖** កាលនោះគឺខ្ញុំអត់បានដឹងទេ ព្រោះគេបញ្ជូនខ្ញុំផុតមក មកនៅជិតផ្សារថ្មី ហៅ *ប៉េហ្ស៊ី* នេះ ខ្ញុំអត់បានដឹងគេយកទៅណាអារឿង គឺខ្ញុំអត់បានដឹងផង ។

**ស៖** ឥឡូវនេះ លោករៀបរាប់អំពីការងាររបស់លោកនៅ មកធ្វើការងារនៅគុកមួយដែលយកអតីត *ប៉េហ្ស៊ី* ធ្វើជាគុក ហើយនិងទិដ្ឋភាពនៃអ្នកទោសនៅទីនោះ ដែលលោកបានឃើញ ។ តើវាមានទិដ្ឋភាពនុំងយ៉ាងដូចម្តេចខ្លះ?

**ឆ៖** កាលនៅ *ប៉េហ្ស៊ី* ខ្ញុំដើរយាមអ្នកទោសតាមបន្ទប់ គឺគេដាក់អ្នកទោសដាក់ខ្នោះជើងតាមបន្ទប់ ហ្នឹងតែប៉ុណ្ណឹងខ្ញុំ ។ កាលនោះគេឲ្យខ្ញុំយាមតែប៉ុណ្ណឹង ។

**ស៖** កាលពីគុកនៅ *ប៉េហ្ស៊ី* ដែលលោកបាននិយាយថា គេរើសលោកមកការនៅទីនោះ កាលនោះមានអ្នកទោសមានចំនួនសរុបប្រហែលប៉ុន្មាននាក់ដែរ តាមដែលលោកចងចាំនៅក្នុងអំឡុងពេលដែលលោកដើរយាមអ្នកទោសតាមបន្ទប់នោះ?

**ឆ៖** កាលដែលខ្ញុំនៅយាមតាមបន្ទប់នោះ កន្លែងដែលផ្ទះដែលខ្ញុំធ្លាប់យាម មនុស្សប្រហែលជាដប់នាក់ ឬដប់នាក់ជាងប៉ុណ្ណោះទេ តែចំពោះផ្ទះផ្សេងទៀតខ្ញុំអត់បានដឹង ។

[១៣:៥២:១៣]

**ស៖** កាលនោះលោកចងចាំទេពេលដែលលោកមកដល់ តើកន្លែងនោះគេហៅច្បាស់លាស់ប្រាកដប្រជា គេហៅឈ្មោះអ្វីជាក់លាក់នៅគុក នៅ *ប៉េហ្ស៊ី* ដែលលោកបាននិយាយអ៊ីចឹង? ថាតើឈ្មោះ ឈ្មោះពិតប្រាកដហ្នឹង គេហៅអ្វីដែលនៅទីនោះ?

**ឆ៖** កាលដែលខ្ញុំនៅទីនោះ កាល-- ខ្ញុំមើលអក្សរ គេដាក់ថា "នាយកដ្ឋាននគរបាលជាតិ" កន្លែងនោះ ។

**ស៖** លោកដែលឮ គេហៅ "គុកដាំផេង" ដែរទេ? ដែលឮពាក្យនេះដែរទេ?

**ឆ៖** បាទ, បានដែលឮ គុកហ្នឹង គេដាក់ "ដាំ ផេង" ហ្នឹងហើយគុកហ្នឹង ។

**ស៖** អ្នកដែលគេហៅខ្លះ ហៅគុក "ដាំ ផេង" គឺគុកដែលលោកមកធ្វើការ ដែលគេយកនាយកដ្ឋាននគរបាលជាតិធ្វើជាគុកហ្នឹង ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, កន្លែងហ្នឹង គឺដូចលោកចៅក្រមថាអ៊ីចឹង កន្លែងហ្នឹង ។

**ស៖** ហើយចុះប្រធាន ប្រធានគុកកាលនោះ កាលដែលលោកមកដល់ភ្លាម មកធ្វើការនៅនោះ តើប្រធានគុកហ្នឹងឈ្មោះអី? ហើយអនុប្រធាននឹងឈ្មោះអ្វីដែរ? ឬក៏អ្នកគ្រប់គ្រងតាមលំដាប់ឋានុក្រមបន្តបន្ទាប់ផ្សេងទៀតហ្នឹង តើលោកស្គាល់អ្នកណាខ្លះ?

**ឆ៖** កាលនោះខ្ញុំស្គាល់ដែលជាមេធំៗនៅកន្លែងនោះ គឺមានឈ្មោះ ឌុច និងឈ្មោះ ហ៊ី និងឈ្មោះ ប៉ូច ជាប្រធានកងការពាររបស់ខ្ញុំ ។

**ស៖** លោកដែលស្គាល់ឈ្មោះ ណាត ទេ? ឬក៏ឈ្មោះ អ៊ិន លន ដែរឬទេ?

**ឆ៖** បាទ, ឈ្មោះនេះខ្ញុំមិនដែលបានស្គាល់ទេ គ្រាន់តែប្រហាក់ប្រហែល ខ្ញុំបានអត់បានស្គាល់ច្បាស់ទេ អត់ បើនិយាយរួចថាអត់បណ្តោយ ។

**ស៖** នៅទីនោះ តើលោកដែលបានដឹងរឿងហេតុនៃការសួរចម្លើយអ្នកដែលត្រូវបានចាប់ឃុំឃាំងដែលលោកថាយាមនោះ? មើលយាមមើលការខុសត្រូវមកឲ្យរត់រួចហ្នឹង តើមានការសួរចម្លើយដែរឬទេ?

**ឆ៖** កាលដែលគេសួរចម្លើយ គេមិនបានឲ្យអ្នកយាមឃើញទេ ព្រោះអ្នកសួរចម្លើយគេយកទៅសួរនៅកន្លែងផ្សេង ផុតពីកន្លែងយាម ។

**ស៖** ចុះមនុស្សដែលនៅទីនោះ តើមានការបាត់ខ្លួនដែរឬទេ នៅក្នុងអំឡុងពេលដែលលោកយាមហ្នឹង? តើអ្នកទោសដែលត្រូវគេចាប់យកទៅឃុំឃាំងនៅនោះ មានការបាត់ខ្លួននេះដែរឬទេ?

[១៣:៥៦:០៣]

**ឆ៖** កាលនៅទីនោះ គឺដែលកន្លែងដែលខ្ញុំយាម មិនបានដែលបាត់ខ្លួនទេ ។

**ស៖** លោកនិយាយអម្បាញ់មិញថា លោកមិនចាំនូវពេលវេលាច្បាស់ទេក្នុងការដែលរើកន្លែងគុកពីកន្លែង *ប៉េហ្ស៊ី* ហើយមកដល់កន្លែងបច្ចុប្បន្ន ។ សំណួរសួរថា កាលពីរើភ្លាមហ្នឹងមកដល់កន្លែងបច្ចុប្បន្ន គឺគេដាក់ថា សារមន្ទីរគុកទួលស្លែងបច្ចុប្បន្ន ឬក៏គេរើមកដាក់នៅកន្លែងណាផ្សេងមួយកន្លែងទៀត? ឬក៏រើមកដាក់នៅកន្លែងដែលយើងប្រើស្គាល់ជាទូទៅថាជា សារមន្ទីរទួលស្លែងនេះតែម្តង?

**ឆ៖** កន្លែងអា-- កាលដែលរើពី *ប៉េហ្ស៊ី* ហ្នឹងមក គឺមកនៅសារមន្ទីរស-២១ គឺទួលស្លែងនេះតែម្តង អត់មានទៅកន្លែងណាទៀតផង ។

**ស៖** ហើយមកដល់ទីនោះ តើគេប្រើប្រាស់ថា ដាក់ឈ្មោះមន្ទីរអ្វីដែរ ច្បាស់លាស់ ជាផ្លូវការក្នុងកាលដែលលោក អំឡុងពេលដែលលោកធ្វើការងារនៅទីនោះ? ឈ្មោះនៃគុកដែលបច្ចុប្បន្នហ្នឹង គេដាក់ថា សារមន្ទីរគុកទួលស្លែង នេះជារឿងបច្ចុប្បន្ន ។ ប៉ុន្តែពេលមុន ពេលដែលលោកផ្លាស់ទីតាំងគុកពី *ប៉េហ្ស៊ី* មកដល់ទីនោះដំបូង ។ តើឈ្មោះពិតប្រាកដនៃមន្ទីរនេះ គេហៅថាឈ្មោះអ្វី? ជាផ្លូវការ?

**ឆ៖** កាលនោះ គឺដាក់ឈ្មោះថា សារមន្ទីរស-២១ តែម្តង អត់មានឈ្មោះអីទៀត ។

**ស៖** រំឭកឡើងវិញថា សារមន្ទីរស-២១ ហ្នឹង គឺឈ្មោះបច្ចុប្បន្នទេ ដោយសារគេចង់តម្កល់រក្សាទុកនូវទិដ្ឋភាពនៃគុកស-២១ ហ្នឹង ដើម្បីធ្វើការសិក្សាជាប្រវត្តិសាស្ត្រតទៅ ។ អ៊ីចឹង គឺថាពាក្យសារមន្ទីរហ្នឹង គឺទើបតែកើតក្រោយទេ ។ សំណួរសួរថា ឈ្មោះពិតប្រាកដដែលលោកមកធ្វើការហ្នឹង កាលពីនុ៎ង

មិនមែនគិតពីឥឡូវនេះទេ គិតថាពីជំនាន់នុ៎ង ដែលលោកមកដល់ធ្វើការនៅទីនោះ ថាតើឈ្មោះដែលលោកមកធ្វើការនៅមន្ទីរនោះ គឺមន្ទីរអ្វី?

**ឆ៖** ឈ្មោះកាលនោះ គឺមន្ទីរស-២១ តែម្តង ។

**ស៖** លោកកាលពីមកដល់មន្ទីរស-២១ហ្នឹង តើគេចាត់ឲ្យលោកធ្វើការងារអ្វី? ហើយក្នុងមុខងារដែលលោកធ្វើហ្នឹង តើលោកធ្វើការងារអ្វីខ្លះ?

[១៣:៥៩:៤០]

**ឆ៖** ការងារមកនៅមន្ទីរស-២១ ការងារភារកិច្ចរបស់ខ្ញុំ គឺគេយាមតាមផ្ទះ តាមបន្ទប់ តាមអគារ ។ យាមផ្លាស់ពេលម្តងម្នាក់ ម្តងមួយក្រុមអ៊ីចឹង ។ បន្ទាប់មកគឺ គេឲ្យខ្ញុំទៅនៅរៀនវ៉ៃអង្គុលីលេខចម្លងឯកសារ ។ បន្ទាប់មកទៀត គេឲ្យខ្ញុំរៀនសួរចម្លើយនៅចុងឆ្នាំ៧៨ ខ្ញុំរៀនសួរចម្លើយបានប្រហែលជាបីខែ គឺទើបវៀតណាមចូលស្រុក ។ នេះជាប្រវត្តិខ្ញុំហ្នឹងនៅមន្ទីរស-២១ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

សូមអញ្ជើញលោកចៅក្រម យ៉ា សុខន ។

**ចៅក្រម យ៉ា សុខន៖**

សូមអរគុណលោកប្រធាន ។

**សួរដោយចៅក្រម យ៉ា សុខន៖**

**ស៖** ពេលដែលលោកផ្លាស់មកនៅស-២១ តើលោកដឹងថាអ្នកណាជាប្រធាន ជាគណៈដឹកនាំមន្ទីរ ស-២១ នេះ?

**ឆ៖** ខ្ញុំផ្លាស់មកនៅមន្ទីរ ស-២១ នេះ គឺថ្នាក់ដឹកនាំដែលខ្ញុំដឹងគឺមានតែឈ្មោះ ឌុច និងឈ្មោះហ៊ី និងប្រធានកងការពារខ្ញុំឈ្មោះ ផូ ឈ្មោះ ប៉ូច ហ្នឹងហើយ ។

**ស៖** តើលោកស្គាល់ឈ្មោះ នុន ហ៊ុយ ទេ? ហៅ ហ៊ុយស្រែ លោកស្គាល់ទេ?

**ឆ៖** បាទ, ហ៊ុយ ស្រែ ហ្នឹង គឺខ្ញុំស្គាល់គាត់មកក្នុងកន្លែង២១ ហ្នឹងម្តងម្កាលដែរ ។ គាត់កាន់អង្គភាពនៅខាងព្រៃស ខាងធ្វើស្រែ ។

[១៤:០២:០០]

**ស៖** តើ ហ៊ុយស្រែ នុ៎ងស្ថិតនៅក្នុងគណៈដឹកនាំ ស-២១ ហ្នឹងទេ?

**ឆ៖** បាទ, ឈ្មោះ ហ៊ុយ នេះជា បើតាមខ្ញុំដឹងគឺគាត់ជាសមាជិកមន្ទីរ ស-២១ ដែរ ។

**ស៖** លោកបានដឹងទេ នៅស-២១ ហ្នឹងគេចែកចេញជាប៉ុន្មានអង្គភាព ហើយអង្គភាពហ្នឹងមានអង្គភាពអីខ្លះ?

**ឆ៖** បាទ, ខ្ញុំអត់បានដឹងទេ ដឹងថាពីរចំណែកហ្នឹង ថាមន្ទីរស-២១ មានកន្លែងស្រែមួយកន្លែង និងកន្លែងមន្ទីរហ្នឹងមួយកន្លែង តែពីរកន្លែងទេ ដែលខ្ញុំអាចដឹង ។

**ស៖** គេចាត់ឲ្យលោកទៅធ្វើការនៅស-២១ តើលោកគេចាត់ឲ្យនៅក្នុងក្រុមអី? ហើយអ្នកណាជាប្រធានក្រុម?

**ឆ៖** បាទ ជាប្រធានក្រុមរបស់ខ្ញុំគឺ កាលខ្ញុំនៅកងការពារប្រធានក្រុមរបស់ខ្ញុំ គឺឈ្មោះ សេង ជាប្រធានកងការពារ ។

[១៤:០៣:៣៥]

**ស៖** ប្រធានក្រុមក្នុងក្រុមការពាររបស់លោកនុ៎ងមានប៉ុន្មាននាក់?

**ឆ៖** បាទ, ប្រធានកងការពាររបស់ខ្ញុំឈ្មោះ សេង ខ្ញុំចាំបានតែម្នាក់ទេ គឺប្រធានក្រុមខ្ញុំ ។ ខ្ញុំនៅជាមួយឈ្មោះ សេង ហ្នឹងរហូតទាល់ខ្ញុំចេញពីគាត់មកៗនៅអង្គភាពសួរចម្លើយ គឺនៅជាមួយឈ្មោះ កាក់ ជាអ្នកបង្រៀនឲ្យខ្ញុំសួរចម្លើយ ។

**ស៖** លោកអត់មានចាំមិត្រភក្តិរបស់លោកមួយចំនួនទៀតដែលនៅយាម នៅកងការពារជាមួយលោកទេ?

**ឆ៖** ជំនាន់កងការពារ ខ្ញុំមិនសូវបានចាំទេ ព្រោះវាភ្លេចហើយព្រោះយូរពេកហើយ ។ ហើយឈ្មោះគឺអាចចាំបានពីរបីនាក់ដែរ ដូចជាឈ្មោះ យ៉ែម យាន ហៅ ច្រិច នេះមួយ ហើយនិងឈ្មោះ រ៉ី ឈ្មោះ ភាព ឈ្មោះ ចេស ឈ្មោះ សឿ ។ ចាំបានប៉ុណ្ណឹង មិនសូវចាំបានច្រើន ។

**ស៖** លោកធ្វើការនៅជាយាមគេឲ្យលោកយាមនៅខាងណា ខាងក្នុង ឬខាងក្រៅស-២១?

[១៤:០៥:០៧]

**ឆ៖** គេឲ្យខ្ញុំយាមនៅតាមបន្ទប់ ជួនកាលឲ្យជាន់ទីមួយ ឬជាន់ទីពីរ នៅអគារកណ្ដាល ឬអគារខាងជើងបន្ទប់ធំ ។

**ស៖** តើលោកគឺជាអ្នកយាមខាងក្នុងមែនទេ?

**ឆ៖** បាទ, ជាអ្នកយាយខាងក្នុង ។

**ស៖** គេចាត់ឲ្យលោកជាអ្នកយាម តើគេមានបង្រៀនវិធីយាមការពារនោះទេដល់លោក? ហើយអ្នកណាគេជាអ្នកបង្រៀនពីវិធីយាមការពារនុ៎ង?

**ឆ៖** កាលនោះ គឺមានឈ្មោះ សេង នេះជាមេក្រុមគាត់បង្រៀនឲ្យខ្ញុំយាម កុំឲ្យអ្នកទោសរត់រួច កុំឲ្យអ្នកទោសធ្វើអត្តឃាត ។

**ស៖** លោកដឹងទេថានៅក្នុងស-២១ នុ៎ងមានអគារប៉ុន្មាននៅទីនោះ?

[១៤:០៦:២៧]

**ឆ៖** បាទ,អគារធំៗមានបីអគារ ។ អគារមួយមានបីជាន់ ហើយនិងការិយាល័យខាងមុខមួយ។

**ស៖** លោកនៅចាំឲ្យច្បាស់ទេ ថាគេឲ្យលោកយាមនៅអគារណាខ្លះ? ហើយនៅជាន់ណាខ្លះ?

**ឆ៖** បាទ, ខ្ញុំចាំកាលនោះ គេឲ្យខ្ញុំយាមនៅអគារកណ្តាលជាន់ទីមួយ និងជាន់ទីពីរ ហើយនិងខាងជើងជា-- ឲ្យយាមជាន់ទីពីរជាបន្ទប់ធំៗ ។

**ស៖** ពេលយប់គេឲ្យលោកសម្រាកនៅឯណា?

**ឆ៖** ពេលយប់គេឲ្យខ្ញុំសម្រាកនៅតាមផ្ទះខាងក្រៅរបង ។

**ស៖** ពេលហូបបាយ តើគេឲ្យហូបបាយនៅទីណា?

**ឆ៖** បាទ, គេឲ្យហូបបាយនៅខាងក្រៅរបង ដែលមានសេដ្ឋកិច្ចគេធ្វើនៅខាងក្រៅ ។

**ស៖** កន្លែងហូបបាយនុ៎ង គឺជាកន្លែងហូបបាយរួមទូទាំងបុគ្គលិកស-២១ នៅទីនោះតែម្តង ឬក៏ចែកដាច់តាមកន្លែងនីមួយៗ?

**ឆ៖** បាទ, តាមកន្លែងកងនីមួយៗ ។ កងការពារគឺផ្នែកការពារហូបផ្សេង ។ កងសួរចម្លើយគេហូបផ្សេង ។

[១៤:០៨:៣៤]

**ស៖** ចុះលោកមានដែលឃើញជនជាប់ចោទទៅហូបបាយនៅកន្លែងនោះទេ?

**ឆ៖** បាទ, សូមបញ្ជាក់ជាប់ចោទ ឥឡូវហ្នឹង ឬសម័យមុន?

**ស៖** តើឈ្មោះ ឌុច ហ្នឹងគាត់មានបានទៅហូបបាយនៅកន្លែងលោកដែរទេ កាលនោះ?

**ឆ៖** បាទ, កាលនោះគាត់ទៅហូបបាយកន្លែងកងសួរចម្លើយ គឺគាត់ទៅហូបនៅកន្លែងនោះម្តងម្កាលដែរ ។

**ស៖** អ៊ីចឹងគាត់មិនដែលបានទៅហូបបាយនៅកន្លែង អ្នកយាមការពារទេអ៊ីចឹង?

**ឆ៖** បាទ, កន្លែងកងការពារ គឺគាត់មិនដែលឃើញទៅហូបនៅកន្លែងនោះទេ ។

**ស៖** គេឲ្យលោកយាមនៅខាងក្នុងនុ៎ង ពីម៉ោងណាទៅម៉ោងណា?

**ឆ៖** បាទ, គឺចាប់តាំងពីម៉ោងប្រាំល្ងាចទាល់ម៉ោង-- មិនមែនម៉ោងប្រាំទេ ម៉ោងប្រាំមួយដល់រហូតដល់ម៉ោងដប់ពីរយប់បានដូរអ្នកយាមទៀត ។

**ស៖** ពេលយាមនោះ គេមានឲ្យកាន់កាំភ្លើងទេ? ហើយកាំភ្លើងអីដែរ កាំភ្លើងនុ៎ង?

**ឆ៖** បាទ, ជំនាន់នោះគឺអត់មានឲ្យកាន់កាំភ្លើងទេ គឺដើរតែខ្លួន ដើរមើល បើនិយាយរួមដើរចុះដើរឡើងអត់ឲ្យយើងអង្គុយ អត់ឲ្យយើងសម្រាក ដើរអើតមើលតាមបន្ទប់រហូត ទៅមកៗ ។

**ស៖** ពេលលោកយាមនៅខាងក្នុងនុ៎ង តើលោកមានដែលឃើញគេនាំអ្នកទោសយកទៅឃុំទេ?

**ឆ៖** បាទ, ឃើញគេនាំយកអ្នកទោសទៅដាក់កន្លែងបន្ទប់ហ្នឹង គឺឲ្យខ្ញុំយាមតែម្ដង គឺឃើញ ។

**ស៖** អ្នកទោសនុ៎ងគេបណ្ដើរមក ហើយគេមានធ្វើអីខ្លះលើអ្នកទោសនុ៎ង គេមានបានចងមុខគេដាក់ខ្នោះ ហើយស្លៀកពាក់ដូចម្ដេចដែរ នៅពេលដែលគេបណ្ដើរមកកន្លែងបន្ទប់ដែលយើងទៅយាមនុ៎ង?

**ឆ៖** កាលនោះ គេបណ្ដើរមក គេៗដាក់ខ្នោះដៃ ហើយមានតែខោខ្លីចងមុខរហូតទាល់តែដាក់ក្នុងបន្ទប់រួចបានគេស្រាយមុខចេញ ។

**ស៖** លោកជាអ្នកយកទៅដាក់ ឬក៏មានអ្នកផ្សេងដទៃទៀតជាអ្នកយកទៅដាក់នៅក្នុងបន្ទប់ឃុំ?

**ឆ៖** បាទ, គឺគេផ្សេងទេ គេអ្នកយកទៅដាក់ ។ ខ្ញុំចាំតែយាមការពារតែប៉ុណ្ណោះ ។

**ស៖** លោកមានដែលឃើញគេបណ្ដើរអ្នកទោសស្រី ហើយនិងកុមារចូលទៅកន្លែងឃុំនោះទេ?

**ឆ៖** បាទ, ចំពោះស្រីគឺមាន តែកុមារមិនដែលឃើញផង ។

**ស៖** អ្នកទោសស្រីដែលគេបណ្ដើរមកគេចងមុខ ហើយគេដាក់ខ្នោះដៃដូចអ្នកទោសប្រុសដែរទេ?

**ឆ៖** ចំពោះអ្នកទោសស្រី ខ្ញុំមិនដែលបានឃើញបណ្ដើរទេ ឃើញតែកន្លែងគេជាប់ទោសនៅកន្លែងការិយាល័យខាងមុខ ភេទស្រី អាហ្នឹងអ្នកទោសស្រី ។ មិនដែលបានឃើញបណ្ដើរចងមុខ ឬក៏បណ្ដើរខ្លួនទទេ គឺខ្ញុំអត់បានឃើញផ្ទាល់ផង ។

**ស៖** តើការនាំអ្នកទោសយកមកឃុំហ្នឹង តើវាប្រព្រឹត្តទៅរាល់ថ្ងៃ ហើយជាប់គ្នាជារដឹករាល់តែថ្ងៃហ្នឹងតែម្ដង ឬយ៉ាងម៉េច?

**ឆ៖** បាទ,ចំពោះរឿងយកមកគឺជួនកាលអត់ ថ្ងៃហ្នឹងអត់ក៏មាន ជួនកាលមួយថ្ងៃពីរបីដងក៏មាន ជួនកាលអត់មួយអាទិត្យក៏មានដែរ ។ នេះតាមដែលខ្ញុំយាមធ្លាប់ឃើញ ។

**ស៖** តើលោកដែលឃើញគេនាំអ្នកទោសជាក្រុមយកទៅឃុំតែម្តងមានដែលឃើញទេ?

**ឆ៖** បាទ, ជំនាន់នោះមាន គេយកជាក្រុមទៅគេដាក់ឡាន អាឡានកាលនុ៎ងវាឡានអាកាត់ៗចិន គេដាក់ឃ្នុបជិតឈឹង គេដាក់មនុស្សមួយឡានហ្នឹងយកទៅដាក់ក្នុងបន្ទប់ធំមួយខាងជើងគេ អាហ្នឹងដាក់បន្ទប់លើ ។

[១៤:១៣:៥៨]

**ស៖** នៅក្នុងខណៈដែលលោកជាអ្នកយាមនៅខាងក្នុង លោកដែលមានឃើញគេនាំអ្នកទោសទៅខាងក្រៅម្តងវិញទេ?

**ឆ៖** ចំពោះអ្នកទោសដែលគេៗនាំចេញទៅក្រៅគឺគេដាក់ឡានទៅ បញ្ចេញពីបន្ទប់ធំៗគឺ គេដាក់ឡានអាឃ្នុបជិតៗហ្នឹងហើយ គេបញ្ចូលមកក៏ឡានឃ្នុបហ្នឹង ចេញក៏ឡានឃ្នុបហ្នឹង ។ យើងខ្ញុំឃើញតែប៉ុណ្ណឹង ។

**ស៖** តាមការប៉ាន់ប្រមាណរបស់លោក នៅក្នុងពេលវេលាដែលលោកជាអ្នកយាមនៅខាងក្នុង តើប៉ុន្មានឡានដែលលោកកត់សម្គាល់ចាំដោយខ្លួនឯង ដែលគេដឹកអ្នកទោសចេញទៅខាងក្រៅ លោកមានចាំបានទេ?

**ឆ៖** បាទ, កាលនៅនេះខ្ញុំអត់បានចាំទេ ។

**ស៖** លោកគ្រាន់តែប្រហាក់ប្រហែល តើប៉ុន្មានឡានដែរ?

**ស៖** លោកគ្រាន់តែប្រហាក់ប្រហែល ប្រហែលប៉ុន្មានឡានដែរ?

**ឆ៖** ការប្រហាក់ប្រហែលវា ខ្ញុំស្មានបានទេ ព្រោះជួនកាលយូរទៅឃើញម្តង ។ ជួនកាលគេបញ្ចេញយប់ បញ្ចូលយប់ គឺខ្ញុំមិនអាចសន្និដ្ឋានបាន ។ ជួនកាលខ្ញុំអត់បានឃើញផង ស្រាប់តែឃើញមនុស្សពេញបន្ទប់ធំក៏មាន ជួនកាលបាត់ឈឹងក៏មាន ។ អានេះ ខ្ញុំមិនអាចសន្និដ្ឋានបាន ។

**ស៖** លោកបញ្ជាក់អម្បាញ់មិញថា ប្រធានក្រុមរបស់លោកឈ្មោះ សេង មែនទេ?

**ឆ៖** បាទ, ឈ្មោះ សេង ។

**ស៖** ក្នុងអំឡុងពេលដែលលោកធ្វើជាអ្នកយាមខាងក្នុង គេមានដែលឲ្យលោកចេញទៅចាប់មនុស្សខាងក្រៅ ពីអង្គភាពផ្សេងៗ ពីមន្ទីរ ឬតាមបណ្តាលតំបន់ភូមិភាគនានាទេ?

**ឆ៖** បាទ, គឺគ្មានទេ មិនដែលបានចេញទៅក្រៅទេ ។

**ស៖** តើលោកមានដឹងទេថា ក្រុមណាដែលចេញទៅខាងក្រៅទៅចាប់មនុស្សពីខាងក្រៅមកស-២១ តើក្រុមណាលោកដឹងទេ?

**ឆ៖** បាទ, រឿងចាប់ ទៅយកមនុស្សពីខាងក្រៅមក គឺខ្ញុំអត់បានដឹង ។ ដឹងតែ ឮគេហៅថាក្រុមនីរសារ១ គឺខ្ញុំអត់បានស្គាល់ អត់បានដឹងឮតែឈ្មោះ ឮតែក្រុមនីរសារ១ ។

**ស៖** លោកមានដែលឃើញគេចាប់ជនបរទេស ស្បែកស សក់លឿងមកស-២១ ទេ?

**ឆ៖** ជំនាន់នោះ គឺខ្ញុំបានឃើញគេបណ្តើរប្រហែលជាពីរនាក់ដែរ ពីរ ឬបី មិនដឹងទេ ពីព្រោះខ្ញុំមិនបានចាំច្បាស់ដែរ ។ ឃើញគេបណ្តើរទៅសួរចម្លើយអ៊ីចឹងទៅ ប្រហែលជាពីរ ឬបីនាក់ប៉ុណ្ណឹង ។

**ស៖** តើឃើញគេចាប់អ្នកទោសឈ្លើយសឹកវៀតណាម និងប្រជាជនសាមញ្ញវៀតណាមមានគេចាប់មកដែរនៅស-២១?

**ឆ៖** ចំពោះអាជនជាតិវៀតណាម គឺឃើញច្រើនដែរ គេចាប់មកទាំងឡាន១នៅចុងឆ្នាំ៧៨ច្រើន ប្រហែលជាពីរបីឡានដែរ ។

**ស៖** មានចាំទេ ប្រហែលជាចំនួនប៉ុន្មាននាក់ទៅ តាមប៉ាន់ស្មាន?

**ឆ៖** បាទ, មិនអាចស្មានត្រូវ ព្រោះឃើញតែដឹកឡានមក ច្រើនហើយប្រហែលជាខ្ទង់មួយរយលើស ឬពីររយក៏មិនដឹង អានេះជាការសន្និដ្ឋានរបស់ខ្ញុំ ។ ឬក៏ច្រើនជាងហ្នឹងទៀត ក៏មិនដឹង ឬក៏តិចជាងហ្នឹងក៏មិនដឹងដែរ ខ្ញុំមិនអាចសន្និដ្ឋានបាន ។ តែឃើញ១ដូចច្រើនដែរ ។

**ស៖** អ្នកទោសជាស្ត្រីគេចាប់មកច្រើនទេ និងកុមារ?

**ឆ៖** អ្នកទោសស្រី គឺកាលដែលខ្ញុំនៅជាអង្គភាពយាម គឺកាលនោះ វាតិចដែរទេ អ្នកទោសស្រីប្រហែលជាបួន ប្រាំនាក់ ឬដប់នាក់ប៉ុណ្ណឹង ។ ដប់នាក់ចុះ កាលខ្ញុំនៅយាម តែក្រោយមកខ្ញុំអត់បានដឹង។

[១៤:១៩:៣២]

**ស៖** លោកមានដឹងថា មានការចាប់១បុគ្គលិកស-២១?

**ឆ៖** ចំពោះបុគ្គលិកស-២១ គឺបានបាត់ខ្លួនជាបន្តបន្ទាប់ តែមិនដឹងគេចាប់ ឬយ៉ាងណាទេព្រោះទទួលភ្នួយឃុំ១ គឺការសន្និដ្ឋានរបស់ខ្ញុំ គឺអង្គភាពស-២១ តែម្តង ។ អ្នកដែលបាត់ខ្លួនហ្នឹងហើយ ។

**ស៖** លោកបានឃើញផ្ទាល់ភ្នែកការចាប់បុគ្គលិកស-២១ ដែលថាទទួលភ្នួយ?

**ឆ៖** បាទ,គឺមិនដែលបានឃើញផ្ទាល់ខ្លួនទេ គ្រាន់តែជាការសន្និដ្ឋានរបស់ខ្ញុំ គឺមិនឲ្យអ្នកនៅក្នុងមន្ទីរហ្នឹងមើលឃើញមុខច្បាស់ជា-- នេះជាការសន្និដ្ឋានរបស់ខ្ញុំ គឺច្បាស់ជាអ្នកនៅក្នុងអង្គភាពស-២១ បានគេទទួលភ្ញួយ ។

**ស៖** លោកឃើញគេទទួលភ្ញួយទេ?

**ឆ៖** បាទ, គឺឃើញគេបណ្ដើរទទួលភ្ញួយឃ្មុំៗ ហើយបាត់ខ្លួន ។ ឧបមាថាបាត់ខ្លួនឈ្មោះណាមួយទៅ ស្រាប់តែថ្ងៃក្រោយមកឃើញបណ្ដើរទទួលភ្ញួយឃ្មុំៗ អត់ឲ្យមើលឃើញទេ ។

**ស៖** នៅក្នុងក្រុមរបស់លោកមានគេចាប់ទេ?

**ឆ៖** បាទ, នៅក្នុងក្រុមរបស់ខ្ញុំ មេក្រុមរបស់ខ្ញុំបាត់ជាបន្តបន្ទាប់ តែមិនគេចាប់ មិនដឹងគេដកទៅខាងណាទេ?

**ស៖** អ្នកដែលបាត់ឈ្មោះ អីខ្លះទៅ?

**ឆ៖** មេក្រុមខ្ញុំកងសួរចម្លើយ គឺបាត់ឈ្មោះ កាក់, ឈ្មោះ ហេង, ឈ្មោះ នន ។

**ស៖** លោកមានដឹងថាអ្នកណា អ្នកបញ្ជាឲ្យចាប់អ្នកទាំងនោះ?

**ឆ៖** រឿងហ្នឹង រឿងបញ្ជា គឺខ្ញុំអត់បានដឹង អង្គភាពណាក៏ខ្ញុំអត់ដឹង ។

[១៤:២២:១១]

**ស៖** លោកស្គាល់ឈ្មោះ ប៉ង់ ទេ?

**ឆ៖** បាទ, អត់ស្គាល់ផង ។

**ស៖** លោកមានដឹងថាគេចាប់ នុន ហ៊ុយ ទេ?

**ឆ៖** បាទ, ខ្ញុំអត់បានដឹងគេចាប់ផង ។

**ស៖** តើមានការចាប់បុគ្គលិកព្រៃសបញ្ជូនមកស-២១ ទេ?

**ឆ៖** ចំពោះបុគ្គលិកព្រៃស គឺខ្ញុំអត់ដែលបានស្គាល់ផង។ មិនដឹងគេចាប់ឬអត់ ខ្ញុំអត់បានដឹងដែរ។

**ស៖** លោកអ្នកយាមនៅខាងក្នុង នៅពេលដែលគេនាំមកឃុំមានបានចែកថាអ្នកទោសនេះសំខាន់ដាក់នៅអគារនេះ អ្នកទោសមិនសំខាន់ដាក់នៅអគារនោះទេ?

**ឆ៖** បាទ, ចំពោះអ្នកទោសដែលសំខាន់ខ្លាំងមែនទេ គឺខ្ញុំមិនបានដឹងទេ តែបន្ទប់ណាដែលតាមបន្ទប់តូចៗ គឺគេដាក់អ្នកទោសដែលគេយកទៅសួរចម្លើយ ក្រុមសួរចម្លើយអាចយកទៅសួរចម្លើយ ។

**ស៖** លោកមានបានដែលយាមនៅបន្ទប់ឃុំរួម?

**ឆ៖** បាទ, ខ្ញុំធ្លាប់យាមនៅបន្ទប់ទីពីរ អគារខាងជើង ។ បន្ទប់ធំហ្នឹងធ្លាប់យាម ។

**ស៖** បន្ទប់ឃុំរួមហ្នឹង គេដាក់អ្នកទោសប្រភេទណា?

**ឆ៖** បន្ទប់ឃុំរួមហ្នឹងគេដាក់ មានកងគេដាក់កងជើង ហើយមានខ្នោះមួយវែងស្វកតម្រៀបជួរគ្នាស្វកជើង ។ ជួនកាលដាក់ជើងទាំងពីរ ជួនកាលដាក់ជើងម្ខាងម្នាក់អ៊ីចឹងទៅ ជួនដាក់ជើងទាំងពីរទៅតម្រៀបជួរគ្នាទៅ ។

**ស៖** ក្នុងមួយជួរៗ ក្នុងមួយរនងគេដាក់អ្នកទោសប៉ុន្មាននាក់?

**ឆ៖** មួយរនងប្រហែលជាច្រើនដែរ ប្រវែងជិតប្រវែងបន្ទប់ហ្នឹងប្រហែលប្រាំម៉ែត្រទេ មនុស្សប្រហែលជាប់ម្ភៃចុះ ឬដប់ប្រាំឡើងអីអ៊ីចឹង ។

**ស៖** គេដាក់ខ្នោះដាក់នៅដៃ ឬដាក់នៅជើង?

**ឆ៖** គេដាក់កជើង គេដាក់ខ្នោះកជើង ។

**ស៖** កជើងទាំងពីរ ឬកជើងតែម្ខាង?

**ឆ៖** បាទ,ជួនកាលដូចខ្ញុំថា ជួនកាលកជើងទាំងពីរ ជួនកាលកជើង-- ដល់មនុស្សច្រើន កជើងមួយ ម្ខាងម្នាក់ទៅ ។

**ស៖** អ្នកទោសមានសម្លៀកបំពាក់ដូចម្ដេចដែរ?

**ឆ៖** បាទ, កន្លែងបន្ទប់រួមហ្នឹង មានអាវ មានខោខ្លី ។

**ស៖** មានអាវគ្រប់គ្នាទេ?

**ឆ៖** បាទ, មានគ្រប់គ្នា ចំពោះបន្ទប់ធំ ។

**ស៖** អ្នកទោសទាំងនោះ គឺតម្រូវឲ្យតែដេក ឬក៏អាចឈរអង្គុយបានស្រេចចិត្ត?

**ឆ៖** បាទ, ចំពោះអ្នកទោសទាំងនោះ គេឲ្យអង្គុយ ឬដេក តែបើឈរគឺឲ្យ គ្រាន់តែឈរតម្រង់បានមួយភ្លែត ហើយឲ្យអង្គុយវិញ ។

**ស៖** តើចាំបាច់សួរសុំអនុញ្ញាតពីអ្នកយាមទេ ចង់អង្គុយ ចង់ឈរ?

**ឆ៖** បាទ, វាត្រឹមតែអង្គុយ គឺមិនបាច់សុំអ្នកយាមទេ បើសិនជាឈរ គឺគ្រាន់តែងើបឈរមួយភ្លែតឲ្យត្រង់ខ្លួន គឺអង្គុយទៅវិញមិនបាច់សុំអ្នកយាមទេ ។

**ស៖** នៅបន្ទប់ឃុំរួម មានគេឃុំស្ត្រីទេ ហើយនិងកុមារ?

**ឆ៖** ពួកបន្ទប់រួម គឺអត់មានទេស្ត្រី មានតែបុរស ហើយកុមារក៏អត់ដែលឃើញដែរ ។

**ស៖** លោកមានដែលយាមគេឃុំអ្នកទោសស្រីទេ?

**ឆ៖** ចំពោះអ្នកទោសស្រីកាលខ្ញុំនៅយាម គឺអត់ដែលបានយាមអ្នកទោសស្រីទេ គ្រាន់តែដើរទៅឃើញនៅការិយាល័យអាខាងមុខ ។

**ស៖** ចុះចំពោះជនបរទេសបស្ចិមប្រទេស ស្បែកស គេឃុំនៅអគារណា?

**ឆ៖** បាទ ឃើញគេបណ្តើរអគារខាងត្បូង ។

**ស៖** លោកមានបានឃើញគេឃុំទេ ឃុំជនបរទេសនោះទេ?

**ឆ៖** ចំពោះអាអ្នកឃុំជនបរទេស គឺខ្ញុំអត់បានឃើញទេ ។

**ស៖** ចុះចំពោះឈ្លើយសឹកវៀតណាម គេឃុំនៅអគារណាដែរ?

**ឆ៖** ចំពោះជនជាតិវៀតណាម គេច្រើនតែឃុំនៅអគារខាងជើងអាដាក់រួម អគារធំ គេដាក់គ្នាច្រើនបន្ទប់ធំ ។

**ស៖** អ្នកទោសនោះគេមានដោះខោអាវទុកតែខោខ្លីទេ?

[១៤:៣០:០០]

**ឆ៖** គឺច្រើនតែខោខ្លី គឺគ្មានអាវទេ នៅតែខោខ្លី ។

**ស៖** ចំពោះអ្នកទោសជាបុគ្គលិកស-២១ គេឃុំនៅអគារណាដែរ?

**ឆ៖** ចំពោះអ្នកទោសនៅបុគ្គលិកនៅស-២១ គឺដាក់អគារខាងត្បូងដែរ ។

**ស៖** លោកបានទៅយាមនៅទីនោះទេ?

**ឆ៖** គឺខ្ញុំអត់ដែលបាននៅយាមទេ អគារខាងត្បូង អត់ដែលបានចូលផង ។

**ស៖** អ៊ីចឹងម៉េចបានលោកដឹងថាគេយកអ្នកទោសបុគ្គលិកស-២១ យកទៅដាក់អគារខាងត្បូង?

**ឆ៖** បាទ, គឺកាលនោះ គឺខ្ញុំឃើញបណ្តើរទូលភ្លួយឃ្លុំៗ គឺចូលអគារខាងត្បូង ។

**ស៖** របបអាហារដែលគេផ្តល់ឲ្យអ្នកទោសដែលជាប់ឃុំ តើអាហារអ្វីដែលគេផ្តល់ឲ្យហ្នឹង? មួយថ្ងៃប៉ុន្មានពេល?

**ឆ៖** អាហារដែលគេឲ្យ ផ្តល់ឲ្យអ្នកទោសកាលនោះ គឺមានបាយស្រូបនិងទឹកសម្ល ។ សម្លជាច្រើនគឺស្ងោប្រហុក ឬក៏សម្លអី គឺខ្ញុំមិនសូវបានចាំដែរកាលនោះ ច្រើនតែស្ងោទឹកប្រហុកស្រូបជាមួយបាយ ដើរចែកគ្នាមួយបោយៗ ។

**ស៖** លោកយាមខាងក្រៅហ្នឹង យាមនៅមុខបន្ទប់អ្នកឃុំ?

**ឆ៖** ខ្ញុំយាម អត់ដែលបានយាមខាងក្រៅ គឺខ្ញុំយាមតែខាងក្នុងតាមបន្ទប់អ្នកទោស ។ ដើរចល័តតាមបន្ទប់ ។

**ស៖** លោកដើរចល័តតាមបន្ទប់ នៅពេលដែលចែកបាយដល់អ្នកទោស លោកឃើញផ្ទាល់ភ្នែកទេ?

**ឆ៖** បាទ, គឺឃើញផ្ទាល់ភ្នែក គឺឃើញដួស-- គេលាយពីកន្លែងសេដ្ឋកិច្ចគេយក គេរែកមកៗលាយជា ដូចជាបបរយើងអ៊ីចឹង វាបាយអ៊ីចឹង ស្រុបដូចជាបបរអ៊ីចឹងមក យកមកដួសឲ្យអ្នកទោសមួយបោយម្នាក់ៗ អ៊ីចឹងទៅ ។

**ស៖** បបរ ឬក៏បាយ?

**ឆ៖** កាលពីខ្ញុំនៅយាម គឺបបរខាប់ៗ ។ តែក្រោយមកគឺ ខ្ញុំអត់បានដឹងទេ ប្រហែលជាបាយរាវបាយខ្លះក៏មិនដឹង ។

**ស៖** គេចែកឲ្យអ្នកទោសម្នាក់ប៉ុន្មាន?

**ឆ៖** គឺម្នាក់មួយបោយ ។

**ស៖** កា១-- កាម៉ែលទាហានហ្នឹង?

[១៤:៣៤:00]

**ឆ៖** កាលនោះ មានបោយ អាបោយមានដៃកាន់អ៊ីចេះ បោយហ្នឹងប្រហែលខ្ទង់គីឡូអង្ករមើលទៅ បោយ ។

**ស៖** មួយបោយដាក់បាន...?

**ឆ៖** មួយបោយហ្នឹងដាក់បានមួយចានយើង បើយើងអ្នកហូបតិចគឺហូបឆ្អែត តែភាគច្រើនគឺតែទឹកមិនសូវមានកាកប៉ុន្មាន ។ តែក្រោយមក គឺខាប់ដែរ អាចឆ្អែត ។

**ស៖** មួយថ្ងៃគេឲ្យប៉ុន្មានពេល? ស្មើណាខ្លះ?

**ឆ៖** មួយថ្ងៃគេឲ្យពីរពេល ។ ពេលព្រឹកអ៊ីចឹងទៅ ម៉ោងដប់កន្លះ ពេលល្ងាចទៅ ម៉ោងប្រាំ ។

**ស៖** តើប៉ុន្មានថ្ងៃ គេឲ្យអ្នកទោសហ្នឹងបានងូតទឹកធ្វើអនាម័យម្តងៗ នៅកន្លែងឃុំហ្នឹង?

**ឆ៖** ជំនាន់នោះ គឺខ្ញុំអត់ដែលបានឃើញឲ្យងូតទឹកផង ។ តែបើបន្ទប់ធំ គឺអាចមានងូត បន្ទប់តូចអត់ អត់ដែលបានឲ្យទឹកងូតផង ។

**ស៖** នៅបន្ទប់ឃុំធំហ្នឹង គេឲ្យងូតទឹករបៀបម៉េច?

**ឆ៖** បន្ទប់ធំហ្នឹង គេបាញ់ទឹកទុយោឱ្យងូតទាំងអស់គ្នាហ្នឹងមួយម្ដងហ្នឹង បួនដប់ថ្ងៃ ឬកន្លះខែ គេឱ្យងូតម្ដងទៅ បាញ់ទុយោដាក់ទៅ លាងឥដ្ឋលាងគេផង ។

**ស៖** តើអ្នកទោសត្រូវបានផ្លាស់សម្លៀកបំពាក់ឱ្យទេ? ឬក៏ឱ្យស្លៀកសម្លៀកបំពាក់ដែលទទឹកហ្នឹង បាញ់ទឹកឱ្យងូតហ្នឹង?

**ឆ៖** បាទ, អត់ៗមានផ្លាស់ទេ ខ្លះជើងជាប់ខ្នោះ អត់បានផ្លាស់ផង ។

**ស៖** នៅពេលដែលអ្នកទោសត្រូវការបន្ទោបង់តូចធំអី តើធ្វើយ៉ាងម៉េចដែរ?

**ឆ៖** ចំពោះអ្នកទោសដែលត្រូវបត់ជើងបន្ទោបង់ គឺមានឡាំងកែសគ្រាប់មួយ គឺដាក់នៅបន្ទប់ធំ ដាក់កែសគ្រាប់ពីរបី អីចឹងទៅ អាបន្ទប់តូច ដាក់មួយបន្ទប់ជិតៗគ្នា ដាក់ក្រៅបន្ទប់អីចឹង ត្រូវការបត់ជើងអី ហៅ-- អ្នកទោសហៅឱ្យអ្នកយាមហ្នឹងហុចឱ្យទៅ ។

**ស៖** តើអ្នកណាដែលអ្នកយកសំណល់ហ្នឹង យកទៅបោះចោល?

**ឆ៖** ចំពោះជាលាមក ជាអីហ្នឹង គឺចាក់សោអ្នកទោសម្នាក់ឱ្យយួរយកទៅចាក់នៅបង្គន់ ។

[១៤:៣៨:១០]

**ស៖** លោកបានឃើញច្បាស់ទេ ថាមានចាក់សោឱ្យអ្នកទោសម្នាក់ ជាអ្នកយួរអាសំណល់ហ្នឹង យកទៅបោះចោល? លោកឃើញផ្ទាល់ភ្នែកដែរ?

**ឆ៖** បាទ, គឺផ្ទាល់ភ្នែក ។

**ស៖** នៅក្នុងបន្ទប់ឃុំរួមហ្នឹង អគារលេខប៉ុន្មាន? ជាន់ទីប៉ុន្មាន?

**ឆ៖** បាទ, អគារនៅ-- អគារខាងជើងជាន់ទីពីរ ។

**ស៖** ពេលនោះ អ្នកណាអ្នកបញ្ជា លោកស្គាល់ទេអ្នកបញ្ជាឱ្យអ្នកទោសដោះៗខ្នោះហើយ យួរសំណល់ហ្នឹងចេញទៅក្រៅ ចាក់ចោល?

**ឆ៖** ចំពោះយកលាមក យកអីចាក់ចោល គឺចំវេនក្រុមណា គឺក្រុមហ្នឹងអាចទទួលខុសត្រូវអាចនាំអ្នកទោសយកទៅចាក់ចោលបាន ។ ឱ្យតែលាមកនោះពេញ ។

**ស៖** អ្នកទោសឈឺ មានរបួស មានគេព្យាបាលទេ? ហើយគេព្យាបាលដូចម្ដេចដែរ?

**ឆ៖** បាទ, ចំពោះអ្នកទោសឈឺ គឺមានពេទ្យគេដើរមើលជាប្រចាំ ។

**ស៖** ក្នុងរយៈពេលដែលលោកយាមនៅខាងក្នុងហ្នឹង លោកធ្វើការជាអ្នកយាមខាងក្នុងហ្នឹងអស់រយៈពេលប៉ុន្មាន?

**ឆ៖** បាទ, ខ្ញុំឃាមតាំងពីខ្ញុំរើពី *ប៉េហ្សុី* ទៅ ទៅនៅរហូតដល់ពាក់កណ្តាលឆ្នាំ៧៨ រហូតដល់ខ្ញុំចេញពីអង្គភាពហ្នឹង ។ ខ្ញុំឃាមរហូត ទាល់តែខ្ញុំចេញទៅរៀនវាយអង្គុលីលេខ ចម្លងឯកសារ បានខ្ញុំឈប់ប្រហែលពាក់កណ្តាលឆ្នាំ៧៨ ។

**ឆ៖** ពេលលោករៀនអង្គុលីលេខ លោកទៅបម្រើការងារខាងរដ្ឋបាលស-២១ ឬក៏បម្រើខាងផ្នែកណា?

**ឆ៖** បាទ គឺខ្ញុំបម្រើនៅអង្គភាពសួរចម្លើយតែម្តង ។

**ស៖** អ្នកណាជាអ្នកបង្រៀនលោកឲ្យសួរចម្លើយអ្នកទោស?

**ឆ៖** បាទ, គឺខ្ញុំ-- អ្នកបង្រៀនគឺឈ្មោះ កាក់ ជាអ្នកបង្រៀនឲ្យខ្ញុំសួរចម្លើយ ឲ្យខ្ញុំនាំអ្នកទោសយកមកឲ្យអង្គុយ ឲ្យគាត់សួរ ឲ្យខ្ញុំមើល ។

**ប្រធានអង្គជំនុំ៖**

ហើយឥឡូវនេះ ដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងបី ហើយចូលវិញ ដើម្បីបន្តស្តាប់សក្ខីកម្មសាក្សីរូបនេះតទៅទៀត ។

មន្ត្រីតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សីនេះ ហើយឲ្យនាំគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងបីជាកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៤២នាទី ដល់ម៉ោង ១៥:០៣នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះតទៅទៀត ។ ជាបន្តសូមប្រគល់ភារៈនេះទៅលោក ចៅក្រម យ៉ា សុខន ដើម្បីបន្តសំណួរសួរដល់សាក្សីរូបនេះ ។ សូមអញ្ជើញលោកចៅក្រម ។

**សួរដោយចៅក្រម យ៉ា សុខន៖**

សូមអរគុណលោកប្រធាន ។

**សៈ** តើការបង្រៀនសួរចម្លើយអ្នកទោសគេបង្រៀននៅកន្លែងណា? ហើយពេលទៅរៀនម្តងៗប៉ុន្មាននាក់?

**ឆៈ** ចំពោះការទៅរៀនសួរចម្លើយគឺរៀននៅកន្លែងអ្នកសួរតែម្តងគឺ សួរតែម្នាក់ រៀនតែម្នាក់ឯង រៀនអង្គុយមើលគេសួរតែម្តង ។

**សៈ** មានដែលទៅរៀនសួរចម្លើយពីជនជាប់ចោទដែរទេ?

**ឆៈ** ចំពោះការទៅរៀនគឺអត់ដែលបានទៅរៀនជាមួយគាត់ផ្ទាល់ទេ គឺរៀនជាមួយឈ្មោះ កាក់ ដែលជាប្រធានក្រុមរបស់ខ្ញុំនោះ ។

**សៈ** ចុះលោកមានដឹងថា អ្នកណាចាត់ចែងឲ្យលោកមកខាងសួរចម្លើយវិញ? ហើយអ្នកណាជាអ្នកឲ្យកាក់ មកបង្រៀនលោក?

**ឆៈ** ការចាត់ចែងឲ្យខ្ញុំមករៀនសួរចម្លើយគឺខ្ញុំអត់បានដឹងទេស្រាប់តែគេឲ្យខ្ញុំមកនៅជាមួយឈ្មោះ កាក់ ហ្នឹងមក ឈ្មោះកាក់ ហ្នឹងប្រើឲ្យខ្ញុំទៅយកអ្នកទោសតែម្តងមក ។

**សៈ** នៅពេលដែលលោករៀនសួរចម្លើយពី កាក់ៗ មានដែលបង្រៀនឲ្យលោកសួរពាក្យថា *សេអ៊ីអា* (CIA), *កាហ្សេបេ* (KGB), ខ្មាំងយួន ។ មានន័យថាដូចម្តេចដែរពាក្យបីហ្នឹង?

**ឆៈ** បាទ, ការសួរចម្លើយគឺមានពាក្យថា *សេអ៊ីអា*, *កាហ្សេបេ* បក្សពលករវៀតណាមគឺមានកាលសួរចម្លើយគឺ រៀន ។

**សៈ** ចុះគេបង្រៀនលោកថាម៉េច *សេអ៊ីអា* ស្អីទៅ *សេអ៊ីអា* ហ្នឹង?

**ឆៈ** អង្កាលគេបង្រៀនជា *សេអ៊ីអា* ហ្នឹងគឺជាភ្នាក់ងារសម្ងាត់របស់អាមេរិក នេះកាលគេបង្រៀនជំនាន់នោះ ។

**សៈ** ចុះ *កាហ្សេបេ?*

**ឆៈ** *កាហ្សេបេ* ជាភ្នាក់ងាររបស់សហភាពសូវៀត ។

**សៈ** បក្សពលករយួនហ្នឹងជាភ្នាក់ងារអី?

**ឆៈ** បក្សពលករយួនគឺជាភ្នាក់ងាររបស់យួនហ្នឹងតែម្តង របស់វៀតណាម ។

**សៈ** លោកដឹងទេ ថាអ្នកណាជាអ្នកកំណត់អ្នកទោសថាជាខ្មាំង?

**ឆៈ** រឿងកំណត់អ្នកទោសថាជាខ្មាំង ខ្ញុំអត់បានដឹងដែរតែចំពោះគេបង្រៀនគេថាចាប់មកកន្លែងហ្នឹងជាខ្មាំង ជា *សេអ៊ីអា* ឬជាបក្សពលករ ឬជា *កាហ្សេបេ* គេណែនាំមកតែប៉ុណ្ណឹង ។

**សៈ** នៅពេល កាក់ បង្រៀនលោកពីការសួរចម្លើយហ្នឹង គេមានជាមេរៀន ឬបង្កើតជាសៀវ-ភៅ បញ្ជីសំណួរអីឲ្យលោកគ្រាន់មើលជាគំរូទេ?

**ឆៈ** បាទ, ការរៀនសួរចម្លើយនេះគឺគ្មានសៀវភៅ គ្មានស្អីជាគំរូទេ គឺរៀនឲ្យអង្គុយមើលគាត់សួរតែម្តង ។

**សៈ** សំណួរទីមួយដែលគេបង្រៀនលោក គេឲ្យសួរអំពីអ្វីទៅអ្នកទោសហ្នឹង? ហើយបន្តមកទៀតគេសួរពីអ្វីទៀត?

**ឆៈ** បាទ, សំណួរទីមួយ គឺគេឲ្យសួរពីប្រវត្តិរបស់អ្នកទោស បន្ទាប់មកគឺសួរពីមូលហេតុដែលអ្នកទោស មូលហេតុដែលបក្សគេចាប់មកគឺមូលហេតុអី?

**សៈ** មានស្អីបន្តទៀតត្រូវសួរ?

**ឆៈ** បាទ, បន្ទាប់ពីសួរមូលហេតុដែលអង្គការចាប់មកគឺអត់មានអីសួរទេ គឺបើអ្នកទោសនោះឆ្លើយថាក្បត់ ឬថាអត់គឺមានតែសង្កត់អ្នកទោសថា អ្នកឯងបើមិនក្បត់ម៉េចក៏អង្គការចាប់មក? គឺមានតែប៉ុណ្ណឹង ។

**សៈ** មានតម្រូវឲ្យឆ្លើយដាក់ទៅអ្នកណាដែលពាក់ព័ន្ធជាមួយឬអត់?

**ឆៈ** ចំពោះរឿងបង្គាប់អ្នកទោសឲ្យសួរ តម្រូវឲ្យឆ្លើយដាក់អ្នកនេះ អ្នកនោះគឺគ្មាន គឺឲ្យសួរទៅតាមចម្លើយ ឲ្យអ្នកទោសឆ្លើយដោយចិត្តរបស់គេ ។

[១៥:០៩:៤២]

**សៈ** គោលបំណងនៃការសួរចម្លើយពីអ្នកទោស តើយើងមានដឹងថាចង់បានអ្វីពីអ្នកទោស?

**ឆៈ** ការសួរចម្លើយអ្នកទោសគឺមានការចង់បានតែចម្លើយពីអ្នកទោសដែលក្បត់ ចង់បានពីចម្លើយនិងខ្សែបណ្តាញរបស់អ្នកក្បត់ ។

**សៈ** លោកដឹងទេ តើអ្នកណាជាប្រធានអង្គភាពសួរចម្លើយ? ហើយអង្គភាពសួរចម្លើយនោះមានប៉ុន្មានក្រុម?

**ឆៈ** បាទ, អារឿងប្រធានសួរចម្លើយគឺខ្ញុំអត់បានច្បាស់ដែរ តែដឹងថា ឈ្មោះ ហ៊ី ឈ្មោះប៉ុន អីនេះ ឈ្មោះ ចាន់ ជាកម្មាភិបាលធំៗសួរចម្លើយ មានប៉ុន្មានក្រុមៗគឺខ្ញុំអត់បានដឹងថាក្រុមប៉ុន្មាន ដឹងថាក្រុមសួរចម្លើយហ្នឹង ក្រុមណាគឺស្គាល់ខ្ញុំស្គាល់តែក្រុមខ្ញុំដែលធ្លាប់រស់នៅជាមួយគ្នាប៉ុណ្ណឹង ។

**សៈ** លោកនៅក្នុងក្រុមណា? ក្នុងអង្គភាពសួរចម្លើយ? ប្រធានក្រុមលោកឈ្មោះអី?

**ឆ៖** បាទ, ក្រុមប្រធានសួរចម្លើយ ប្រធានក្រុមរបស់ខ្ញុំគឺមាន មុនដំបូងបំផុត គឺខ្ញុំនៅជាមួយឈ្មោះ នន ចេញពីរៀនសួរចម្លើយជាមួយឈ្មោះ កាក់ ទៅ ខ្ញុំនៅជាមួយឈ្មោះ នន ។ បន្ទាប់ពីឈ្មោះ នន មក ខ្ញុំនៅជាមួយឈ្មោះ ហេង ។ បន្ទាប់ពីនៅជាមួយឈ្មោះ ហេង មកគឺនៅជាមួយឈ្មោះ ណាន ។ នៅជាមួយឈ្មោះ ណាន រហូតដល់ពេលរត់ចេញពីភ្នំពេញ ។

**ស៖** តើមានការបែងចែកអ្នកសួរចម្លើយទៅតាមប្រភេទអ្នកទោសទេ? ដូចជាអ្នកទោសមានឋានៈសំខាន់ អ្នកទោសបរទេស ឬជាស្ត្រី?

**ឆ៖** បាទ, ចំពោះរឿងអ្នកទោសគឺមានផ្នែកគេសំខាន់ៗ គេមានអ្នកធំៗដូចជាឈ្មោះ ហ៊ី ឈ្មោះ ប៉ុន ឈ្មោះចាន់ កម្មាភិបាលធំៗហ្នឹងគេសួរអ្នកទោសសំខាន់ៗអ្នកធំៗ ដូចជាថ្នាក់រដ្ឋមន្ត្រី ថ្នាក់ប្រធានក្រសួង ប្រធានអង្គភាពធំៗ ឬជាជនបរទេស ឬជានារីកម្មាភិបាលអីធំៗគឺគេអ្នកធំៗគេសួរផ្សេង ។ ចំពោះក្រុមខ្ញុំគឺ សួរចម្លើយតែអ្នករាយរង ឬចម្លើយដែលមិនបានការ គឺខ្ញុំរៀនសួរ ។

**ស៖** តើនៅក្នុងអង្គភាពសួរចម្លើយនេះគេមានចែកជាក្រុមត្រជាក់ ក្រុមក្តៅ ក្រុមអង្កៀមទេ? ហើយក្រុមណាខ្លះស្ថិតនៅក្នុងក្រុមត្រជាក់ ក្រុមក្តៅ ក្រុមអង្កៀម?

**ឆ៖** ចំពោះរឿងក្រុមត្រជាក់ ក្រុមក្តៅ ក្រុមអង្កៀម គឺខ្ញុំអត់បានដឹងទេ កាលណោះគឺខ្ញុំទើបចូលថ្មីរៀនសួរចម្លើយ អ៊ីចឹងគឺមិនអាចដឹងការរាក់ជ្រៅរបស់ក្រុមផ្សេងៗគឺខ្ញុំអត់បានដឹងផង ។

**ស៖** តើមានការបែងចែកក្រុមត្រជាក់ ក្រុមក្តៅ ក្រុមអង្កៀមហ្នឹងទេនៅអង្គភាពសួរចម្លើយ?

[១៥:១៤:១៣]

**ឆ៖** នេះដូចខ្ញុំឆ្លើយអំមិញ គឺខ្ញុំអត់បានដឹង អត់ដឹងថា ក្រុមអង្កៀម ក្រុមត្រជាក់ ក្រុមក្តៅគឺខ្ញុំអត់ បានដឹង ។

**ស៖** ប្រធានក្រុមរបស់លោក ឈ្មោះ ណាន ដឹងថា ប្រធានក្រុមគាត់នៅក្នុងក្រុមណាទេ?

**ឆ៖** ចំពោះ ដឹងក្រុមណាៗ ដឹងតែក្រុមសួរចម្លើយតែប៉ុណ្ណឹង ។

**ស៖** អ្នកទោសត្រូវយកទៅសួរចម្លើយនៅកន្លែងណា? ហើយចំពោះអ្នកទោសបរទេសគេយកទៅសួរចម្លើយណាដែរ?

**ឆ៖** ចំពោះអ្នកទោសដែលត្រូវសួរចម្លើយ គឺយកទៅសួរនៅពីមុខវ៉ា-- នៅពីមុខមន្ទីរ នៅពីខាងមុខតាមបន្ទប់របស់អ្នកសួរម្នាក់ៗ ។ ហើយអ្នកសួរចម្លើយតាមបន្ទប់ហ្នឹងហើយ សួរនៅខាងពីមុខ តាមផ្ទះតាមបន្ទប់របស់អ្នកសួរម្នាក់ៗ ។

**ស៖** នៅពីមុខស-២១ ហ្នឹង?

**ឆ៖** បាទ, នៅពីមុខស-២១ ហ្នឹង តែម្តង គឺខាងក្រៅរបងលួស ខាងក្នុងរបងស័ង្កសី ។

**ស៖** លោកដែលឃើញជនជាប់ចោទសួរចម្លើយអ្នកណាម្នាក់ទេ?

**ឆ៖** បាទ, ចំពោះជនជាប់ចោទ គឺខ្ញុំមិនដែលឃើញសួរចម្លើយអ្នកណាម្នាក់ទេ ។

**ស៖** ពេលលោកសួរចម្លើយអ្នកទោសដែលជនជាប់ចោទចូលទៅជួយសួរជាមួយទេ?

**ឆ៖** បាទ, ចំពោះជនជាប់ចោទ គឺមិនដែលបានចូលទៅសួរជាមួយខ្ញុំទេ គឺខ្ញុំបានជួបគាត់តែម្តង ពេលហូបបាយ ឬរៀនសាលានយោបាយតែប៉ុណ្ណោះ ។

**ស៖** អ្នកណាជាអ្នកសម្រេចឲ្យលោកសួរអ្នកទោសមួយណាៗ? ហើយការបញ្ជាហ្នឹងដោយសរសេរជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

**ឆ៖** បាទ, ចំពោះបញ្ជាឲ្យខ្ញុំយកអ្នកទោសមកសួរ គឺខ្ញុំទទួលជាលាយលក្ខណ៍អក្សរពីប្រធានពួកប្រធានក្រុមរបស់ខ្ញុំហ្នឹងគឺឈ្មោះ កាក់ និងឈ្មោះ ហេង ឈ្មោះ នន ហ្នឹងជាប្រធានក្រុមរបស់ខ្ញុំដែលគាត់ឲ្យជាក្រដាសជាលាយលក្ខណ៍អក្សរមកឲ្យឈ្មោះខ្ញុំទៅយកអ្នកទោសមកសួរ ។

**ស៖** អ្នកណាអ្នកសរសេរជាលាយអក្សរលើក្រដាសនោះ លោកដឹងទេ?

**ឆ៖** ចំពោះអក្សរ-- លាយលក្ខណ៍ជាអក្សរលើក្រដាសនោះគឺខ្ញុំអត់បានដឹងដែរ តែមេពួករបស់ខ្ញុំគាត់ហុចមកឲ្យ គាត់យកមកឲ្យខ្ញុំយកឈ្មោះណា គឺខ្ញុំទៅយកឈ្មោះហ្នឹងមក គឺអត់បានដឹងថាឈ្មោះណាបញ្ជាឲ្យយក សរសេរ ឬឲ្យខ្ញុំយក គឺខ្ញុំអត់បានដឹង ។

**ស៖** នៅក្នុងចំណារលិខិតលើក្រដាសលាយលក្ខណ៍អក្សរហ្នឹង លោកឃើញមានហត្ថលេខានៅលើនោះទេ?

**ឆ៖** បាទ, មានៗហត្ថលេខារបស់ប្រធានពួករបស់ខ្ញុំ ។

**ស៖** ប្រធានពួករបស់លោកមានសិទ្ធិចុះហត្ថលេខានៅលើក្រដាសហ្នឹងដែរ?

**ឆ៖** បាទ, គេ-- ខ្ញុំមិនដឹងដែរ ព្រោះគេហុចក្រដាសឲ្យមកខ្ញុំទៅយក គឺខ្ញុំទៅយក ។

**ស៖** ប៉ុន្តែហត្ថលេខា ឈ្មោះនោះ ឈ្មោះអ្នកណាគេ? ដែលគេចារឲ្យថា ឲ្យទៅយកអ្នកនេះ អ្នកនោះមកសួរចម្លើយមក?

**ឆ៖** គឺអត់មានចារជាលេខាអីផង ជាហត្ថលេខាអីផង ប្រធានពួកខ្ញុំឲ្យទៅយកតែម្តង ទៅយកឈ្មោះនេះមក គាត់ថាអ្នែងទៅយកឈ្មោះនេះនៅបន្ទប់នេះ លេខប៉ុណ្ណោះ ដាក់-- ។ ហ្នឹងឲ្យខ្ញុំទៅយកមក

ខ្ញុំយកទៅសួរបណ្ដោយ តែបើគាត់ទទួលបញ្ជាពីណាមក គឺខ្ញុំអត់បានដឹង ។

**ស៖** លោកបានលិខិតលាយលក្ខណ៍អក្សរនេះហើយ លោកយកលិខិតហ្នឹងទៅឲ្យអ្នកណាទៀត?

**ឆ៖** បាទ, ខ្ញុំបានឈ្មោះអ្នកទោសមកហើយ គឺខ្ញុំយកទៅឲ្យអ្នកយាមនៅខាងក្រៅ ហុចលេខ ហុចលេខបន្ទប់ ហុចឈ្មោះទៅ ឲ្យយាមតាមបន្ទប់មក គេបញ្ចេញឈ្មោះយកមកឲ្យខ្ញុំសួរ ។

**ស៖** លិខិតនោះ បើមិនទាន់ឆ្លងកន្លែងចុះបញ្ជីផង ម៉េចក៏ដឹង យើងដឹងថាអ្នកហ្នឹងនៅបន្ទប់ណា? ជាន់ណា? នៅអគារណាកើត?

**ឆ៖** ចំពោះអារឿងដឹង គឺខ្ញុំអត់បានដឹងថាអ្នកទោសនៅបន្ទប់ណាៗ តែគេឲ្យឈ្មោះមកគឺមានលេខ មានឈ្មោះ មានបន្ទប់ ។ ហ្នឹងគេឲ្យឈ្មោះមកអ៊ីចឹង ។

**ស៖** តើមានដែលយកលិខិតហ្នឹង យកទៅឲ្យខាង សួស ធី ដែលជាអ្នកកាន់បញ្ជីអ្នកទោសហ្នឹងទេ? ហើយបាន សួស ធី ហ្នឹង គេចារតម្រូវថា អ្នកទោសនេះឃុំនៅបន្ទប់នេះ អគារនេះ ជាន់នេះ មានដែលធ្វើអ៊ីចឹងទេ?

**ឆ៖** បាទ ន៎ែ! រឿង-- ខ្ញុំអត់បានដឹងអត់បានយល់ដែរ ព្រោះគេឲ្យមកគឺគេឲ្យឈ្មោះអ្នកទោសគឺមានលេខ មានបន្ទប់អី មានឈ្មោះ មាន(ឮមិនច្បាស់)-- មានអគារមក ។

**ស៖** នៅពេលលោកបានលិខិតនេះ លោកយកទៅឲ្យអ្នកណា? ហើយដើម្បីបានអ្នកទោសមកហ្នឹង តើគេធ្វើដូចម្ដេចខ្លះ?

[១៥:២៣:១២]

**ឆ៖** បាទ,គឺខ្ញុំទៅដល់ ទៅដល់មានបញ្ជីគេដាក់សៀវភៅមួយនៅលើ នៅលើរនងៗអគារហ្នឹងដាក់សៀវភៅមួយលើតុហ្នឹង ហើយទៅដល់ស៊ីញេចុះឈ្មោះអ្នកទោសទៅ លេខបន្ទប់ទៅ ដាក់ឈ្មោះ ហើយចុះហត្ថលេខាចំពោះអ្នកយក ។ គឺចុះហត្ថលេខាខ្លួនឯងផ្ទាល់ គឺខ្លួនខ្ញុំផ្ទាល់ ។ បានអ្នកយាមគេបញ្ចេញអ្នកទោសយកមកឲ្យ ។

**ស៖** នៅពេលដែលអ្នកយាមបញ្ចេញអ្នកទោសមក តើអ្នកទោសស្ថិតក្នុងស្ថានភាពដូចម្ដេច? មានដាក់ខ្នោះ មានចងមុខឬទេ?

**ឆ៖** គឺគេបញ្ចេញមក គេដាក់ខ្នោះដៃ ហើយចងមុខ យកមកប្រគល់ឲ្យយើងខ្ញុំផ្ទាល់ ។

**ស៖** ការបណ្ដើរអ្នកមកសួរចម្លើយ តើអ្នកយាមអ្នកបណ្ដើរមក ឬលោកផ្ទាល់ជាអ្នកបណ្ដើរ? ហើយបណ្ដើរយកទៅសួរនៅកន្លែងណា?

**ឆ៖** បាទ, គឺខ្ញុំបណ្តើរផ្ទាល់ចេញពីកន្លែងអគារមក មកដាក់បន្ទប់របស់ខ្ញុំគឺកន្លែងខ្ញុំសួរចម្លើយផ្ទាល់តែម្តង ។

**ស៖** ប្រហែលចម្ងាយណាពីកន្លែងឃុំហើយមកកន្លែងចម្លើយអ្នកទោសហ្នឹង?

**ឆ៖** បាទ, ចេញពីរបងលួសប្រហែលជាម្ភៃ ឬសាមសិបម៉ែត្រមកក្នុង គឺមកក្រៅចេញមកក្រៅរបងមក ប្រហែលសាមសិបម៉ែត្រមកដល់កន្លែងសួរចម្លើយ ។

**ស៖** ពេលលោកយកអ្នកទោសសួរចម្លើយ តើលោកចាត់ចែងអ្នកទោសរបៀបម៉េច?

**ឆ៖** ពេលមកដល់កន្លែងសួរចម្លើយ គឺខ្ញុំដាក់កងជើង ហើយដោះខ្នោះដៃ ស្រាយមុខ បានសួរ ។

**ស៖** នៅពេលសួរចម្លើយអ្នកទោសហ្នឹង មានប៉ុន្មាននាក់ដែរ?

**ឆ៖** ការសួរចម្លើយអ្នកទោសនោះ គឺមានតែអ្នកទោសម្នាក់ដែលដូចជាខ្ញុំរៀបសួរអ៊ីចឹងយកទៅសួរមួយបន្ទប់តែឯងអ៊ីចឹងទៅដល់សួរពីប្រវត្តិចប់ បាន តាហ៊ិ គាត់ដើរមកសួរដេញដោលពីប្រវត្តិហ្នឹងបន្ត ហើយឲ្យអ្នកទោសឆ្លើយ ។

**ស៖** ការកត់ត្រាយកចម្លើយអ្នកទោសតាមវិធីណាខ្លះទៅ?

**ឆ៖** បាទ, យកចម្លើយពីអ្នកទោសគឺតាមការសរសេរនឹងដៃ ឬក៏វាយអង្គុលីលេខ ឬក៏ថតចម្លងជាម៉ាញ៉េ ។

**ស៖** ពេលលោកសួរចម្លើយអ្នកទោសចប់ ត្រូវរាយការណ៍ទៅឲ្យអ្នកណា?

**ឆ៖** បាទ, គឺខ្ញុំសួរចម្លើយចប់ គឺប្រគល់ឯកសារតាមរយៈមេពួកឲ្យទៅប្រធានខ្ញុំគឺឈ្មោះ កាក់ ឈ្មោះ នន ឈ្មោះ ហេង ហ៊្នឹង ឈ្មោះ ណាន ។

**ស៖** លោកមានដែលរាយការណ៍ពីការសួរបញ្ចប់ចម្លើយអ្នកទោសហ្នឹង ជូនទៅឲ្យជនជាប់ចោទផ្ទាល់ដែរទេ?

**ឆ៖** បាទ, គឺខ្ញុំមិនដែលបានបញ្ជូនទៅឲ្យផ្ទាល់ខ្លួនឯងទេ គឺតាមខ្សែរយៈរហូត ។

**ស៖** តើអ្នកណាជាអ្នកសម្រេចបញ្ចប់ការសួរចម្លើយ?

**ឆ៖** ការសម្រេចបញ្ចប់គឺ សម្រេចលើអ្នកទោសសារភាពថាចប់ហើយ គឺចប់ សម្រេចលើអ្នកទោស ។

**ស៖** ចុះបើសិនជាអ្នកដែលយើងត្រូវទៅរាយការណ៍នោះ ហើយថាមិនទាន់ចប់។ តើមានលិខិតអីត្រលប់មកវិញថា ឲ្យត្រូវសួរបន្តទៀតនោះ?

**ឆ៖** មិនដែលមានឯកសារណាថាឲ្យសួរបន្តផង តែបើមានឆ្ងល់អី ដូចជាដែលជនជាប់ចោទដែលឈ្មោះ ឌុច ហ្នឹងគាត់មានទូរស័ព្ទតេ ទូរស័ព្ទខ្សែរវែនោះ គាត់តេមកថាឈ្មោះនេះអ៊ីចេះ ឈ្មោះអ៊ីចុះឆ្លើយមិនត្រឹមត្រូវអី គាត់មានតេមកសួរដែរ ។

**ស៖** អ៊ីចឹងបានសេចក្តីថានៅពេលដែលយើងរាយការណ៍ពីចម្លើយអ្នកទោសទៅលើ ហើយមានការមិនច្បាស់ត្រង់ណា មានជនជាប់ចោទធ្លាប់ទូរស័ព្ទមកប្រាប់លោកដែរ? ឲ្យសួរកន្លែងនេះបន្ថែម? កន្លែងនោះបន្ថែមទៀត? មានទេ?

**ឆ៖** បាទ, មាន ធ្លាប់មាន គាត់ធ្លាប់តេមកប្រាប់ថា ឈ្មោះនេះអត់ត្រឹមត្រូវ ឬឈ្មោះនេះខុសឈ្មោះនោះអី ។ គាត់តេមកប្រាប់ដែរ ។

**ស៖** គាត់ទូរស័ព្ទមកលោកផ្ទាល់តែម្តង?

**ឆ៖** បាទ, គាត់តេមកផ្ទាល់ ។

**ស៖** លោកស្គាល់សំឡេងគាត់ដែរ?

**ឆ៖** បាទ, គឺស្គាល់ច្បាស់ណាស់ គាត់ សំឡេងគាត់ ។

[១៥:៣០:០៤]

**ស៖** អ្នកទោសដែលសួរចម្លើយហើយ តើគេឲ្យនៅស-២១ហ្នឹងទៀត ឬក៏គេបញ្ជូនទៅកន្លែងណា?

**ឆ៖** ចំពោះអ្នកទោសដែលសួរចម្លើយហើយ គឺបញ្ហាហ្នឹងគឺខ្ញុំអត់បានដឹងទេ ព្រោះការងារសួរចម្លើយដឹងតែសួរចម្លើយ យាមដឹងតែយាមតែប៉ុណ្ណោះ គ្មានឲ្យអ្នកណាដឹងភារកិច្ចនេះៗ គឺអត់បានដឹងដឹងតែសួរ ។

**ស៖** លោកដែលធ្លាប់សួរចម្លើយជាអ្នកទោសស្ត្រីទេ?

**ឆ៖** បាទ, អត់ ។

**ស៖** លោកដឹងទេ គ្រប់អ្នកទោសទាំងអស់គេត្រូវតែសួរចម្លើយទាំងអស់គ្នា ឬមួយក៏មានអ្នកខ្លះមិនត្រូវសួរសោះ?

**ឆ៖** បាទចំពោះអ្នកទោស កាលពីខ្ញុំនៅយាមការពារនៅឡើយ មានអ្នកទោសខ្លះគេទុកចោលយកមកដាក់ចោលមិនដែលសួរ មិនដែលនាំមិនដែលស្អីផង ស្រាប់តែគេយកចេញវិញបាត់ទៅក៏មាន ។ នេះកាលខ្ញុំនៅយាមបានដឹង បើថាខ្ញុំសួរចម្លើយហើយ គឺអត់បានដឹងទេ ។

**ស៖** អ្នកទោសឈ្លើយសឹកវៀតណាម អ្នកណាជាអ្នកសួរ?

**ឆ៖** ចំពោះឈ្លើយសឹកបរទេស គឺខ្ញុំអត់បានដឹងទេ តែដឹងថា អង្គរក្សរបស់ តាចាន់ ឬអង្គរក្សរបស់ តាប៉ុន គេមកយកទៅឲ្យ បែបប្រហែលឈ្មោះ ចាន់ និងឈ្មោះ ប៉ុន ជាអ្នកសួរ ប្រហែលជាមានអ្នកបកប្រែផ្សេងទៀត ។

**ស៖** ចុះអ្នកទោសបស្ចិមប្រទេស ពួកអឺរ៉ុប?

**ឆ៖** បាទ, រឿងបរទេសដទៃទៀតគឺខ្ញុំអត់បានដឹងថា នេះទេ ឃើញតែអង្គរក្សរបស់ តាចាន់ និងតាប៉ុន ហ្នឹងយកដែរ នាំយកទៅដែរ តែអ្នកណាសួរគឺខ្ញុំអត់បានដឹងដែរ ។

**ស៖** តើអ្នកទោសម្នាក់ប្រើពេលក្នុងការសួរចម្លើយអស់រយៈពេលប៉ុន្មានថ្ងៃទើបចប់?

**ឆ៖** ការសួរចម្លើយគឺមិនបានទៀងទាត់ទេ គឺចួនកាលសួរចម្លើយម្នាក់ហ្នឹងមួយខែក៏មាន ចួនកាលមួយអាទិត្យក៏មាន ចួនកាលបួនដប់ថ្ងៃក៏មានដែរ នេះវាមិនអាចកំណត់បានទេ តាមការសួរគឺអ្នកទោសអាចឆ្លើយលឿន ឬក៏អាចមិនចេះអក្សរ ឬក៏មិនចេះឆ្លើយ ហើយក៏អត់ព្រមឆ្លើយ ក៏អាហ្នឹងទៅតាមដំណើរហ្នឹង ។

[១៥:៣៣:៣១]

**ស៖** លោកនៅចាំបានទេ ថាលោកបានធ្លាប់សួរចម្លើយអ្នកទោសប្រហែលប៉ុន្មាននាក់ដែររហូតដល់បែកភ្នំពេញ?

**ឆ៖** ចំពោះខ្ញុំដែលសួរចម្លើយដោយផ្ទាល់ខ្លួនឯង គឺបានប្រហែលជាបីឬបួននាក់ប៉ុណ្ណោះ ព្រោះខ្ញុំទើបតែរៀន បើខ្ញុំនៅជាមួយឈ្មោះ កាក់ គឺរៀនជាមួយឈ្មោះ កាក់ យកឲ្យឈ្មោះសួរ គឺបានប្រហែលជាបួនដប់ម្ភៃនាក់ដែរ តែមិនបានសួរទេ គ្រាន់តែអង្គុយជាមួយនឹងគេ ។

**ស៖** លោកមានចាំឈ្មោះ តើអ្នកណាខ្លះដែលលោកបានសួរចម្លើយ?

**ឆ៖** បាទ,ជំនាន់នោះគឺ អស់រយៈយូរហើយគឺខ្ញុំអត់បានចាំឈ្មោះអីម្នាក់ទេ ភ្លេចអស់ហើយ ។

**ស៖** លោកមានការអនុញ្ញាតឲ្យសួរចម្លើយអ្នកទោស មានន័យថា អ្នកសួរចម្លើយអាចធ្វើអំពើហិង្សាអ្នកទោសបានទេ? ឬក៏ពេលធ្វើអំពើហិង្សាអ្នកទោសត្រូវសុំអនុញ្ញាតសិន?

**ឆ៖** ចំពោះអំពើហិង្សាចំពោះអ្នកទោស គឺអ្នកសួរចម្លើយរាយរងដូចខ្ញុំ គឺមិនអាចប្រើហិង្សាខ្លាំងបានទេ គឺអាចត្រឹមបានជេរស្តី ឬក៏កំហែញបាន តែគ្រង់វាយតប់ ឬក៏ធ្វើទារុណកម្មផ្សេងៗគឺមិនអាចធ្វើបាន ។

**ស៖** តើនេះគឺអ្នកណាជាអ្នកណែនាំ?

**ឆ៖** បាទ, នេះគឺជាមេក្រុម មេពួករបស់ខ្ញុំហ្នឹង គឺឈ្មោះ នន, ឈ្មោះ កាក់, ឈ្មោះ ហេង ឈ្មោះ ណាន ។

**ស៖** ក្នុងករណីអ្នកទោសឆ្លើយមិនអស់ មិនគ្រប់ជ្រុងជ្រោយ មិនតាមសំណួរដែលចង់បាន ឬ មិនឆ្លើយ អ្នកសួរចម្លើយត្រូវប្រើអំពើហិង្សា? អ្នកណាអ្នកបញ្ជា?

**ឆ៖** ពួកអ្នកទោសដែលមិនព្រមឆ្លើយ ត្រូវប្រើអំពើហិង្សា គឺវាច្រើនតែ តាហ៊ី មកផ្ទាល់ មក គាត់មកប្រើ ដូចខ្ញុំអ្នកសួរអ៊ីចឹង គាត់ប្រើឲ្យខ្ញុំទៅកាច់រំពាត់ មែកត្របែកមែកអីមកវាយវាត់ ។

**ស៖** អ៊ីចឹង ហ៊ី ឲ្យលោកកាច់មែកត្របែកយកទៅឲ្យគាត់ ធ្វើអំពើហិង្សាលើអ្នកទោសមែន?

**ឆ៖** បាទ, គឺឈ្មោះ ហ៊ី គាត់ប្រើអំពើហិង្សា គាត់ប្រើខ្ញុំឲ្យកាច់មែកត្របែកមែន ។

**ស៖** ឌុច មានដែលណែនាំឲ្យលោកប្រើអំពើហិង្សាលើអ្នកទោសទេ?

[១៥:៣៧:៤៦]

**ឆ៖** ចំពោះឈ្មោះ ឌុច គឺមិនបានដែលមកណែនាំ ឬក៏មកបញ្ជាឲ្យខ្ញុំប្រើអំពើហិង្សាចំពោះអ្នកទោសគឺអត់ទេ គឺមានតែគាត់បង្រៀននយោបាយនៅសាលាមួយអាទិត្យម្តងអី គឺគាត់ណែនាំនៅក្នុង សាលា ប៉ុន្តែមកសួរ មកកន្លែងផ្ទាល់គឺអត់ មិនដែលមកទេ ។

**ស៖** ឌុច គាត់ណែនាំនៅសាលាហ្នឹង តើណែនាំប្រើអំពើហិង្សារបៀបម៉េចខ្លះទៅ?

**ឆ៖** រឿងណែនាំប្រើអំពើហិង្សា គឺមិនបានណែនាំឲ្យប្រើអំពើហិង្សាអ្វីទេ គឺណែនាំពីផ្នែកនយោបាយឲ្យខំសួរចម្លើយហ្នឹងឲ្យឆាប់ចេញ ហើយធ្វើម៉េចធ្វើនយោបាយឲ្យអ្នកទោសហ្នឹង ឆ្លើយឲ្យស្រួល កុំឲ្យកៀបសង្កត់ កុំឲ្យបង្ខំអ្នកទោសឲ្យសួរដឹកមុខអ្នកទោស ឲ្យសួរដាក់អ្នកនេះ ឆ្លើយដាក់អ្នកនោះ គឺគាត់បង្រៀនពីនយោបាយ កុំឲ្យយើងដឹកមុខខ្លាំង អាហ្នឹងគាត់បង្រៀនអ៊ីចឹង ។ តែចំពោះថា បង្រៀនពីរឿងថាឲ្យខ្ញុំធ្វើអំពើហិង្សាវ៉ៃឆក់អាម៉េច គឺអត់បានដែលបង្រៀនទេ ច្រើនតែ-- បើមកវ៉ៃ គឺច្រើនតែ តាហ៊ី គាត់មកសួរជាមួយខ្ញុំហ្នឹង គាត់ធ្វើទារុណកម្មផ្ទាល់ ។

**ស៖** ការប្រើហិង្សាបែបណាខ្លះលើអ្នកទោសនៅស-២១ នេះដែលលោកបានឃើញ?

**ឆ៖** កាលដែលខ្ញុំនៅរៀនសួរចម្លើយជាមួយឈ្មោះ កាក់ គាត់ធ្វើអំពើហិង្សា មានតែគាត់វ៉ៃនឹង មែកត្របែក ឬក៏វ៉ៃ មានអាប្រដាប់គេឆក់តូច គេវ៉ៃកៀបស្លឹកត្រចៀក ។ វ៉ៃទៅ អានេះឆក់ធ្វើខ្មើចៗ ស្លឹកត្រចៀក ។ អាហ្នឹងឃើញ ខ្ញុំឃើញតែប៉ុណ្ណឹង ។

**ស៖** មានដែលគេច្រកស្បោងកៅស៊ូក្បាលអ្នកទោស បន្តក់ទឹកក្នុងច្រមុះ ឬដកក្រចក មានដែលឃើញគេធ្វើអំពើហិង្សាបែបនេះទេ?

**ឆ៖** ចំពោះអំពើហិង្សាច្រកស្បោង ដកក្រចក ឬបន្តក់ទឹកអី គឺខ្ញុំផ្ទាល់អត់ដែលបានឃើញទេ ក្រែងលោតែក្រុមគេផ្សេង គឺខ្ញុំមិនបានដឹង ។ ប៉ុន្តែ ចំពោះដែលខ្ញុំផ្ទាល់ហើយនៅរៀនសួរហ្នឹង គឺអត់បានឃើញ ។

**ស៖** លោកមានដែលឃើញ ឧបករណ៍ធ្វើអំពើហិង្សាហ្នឹង ចងព្យួរអ្នកទោសជ្រមុជទឹកចូលទឹកពាង មានដែលឃើញទេ?

**ឆ៖** ចំពោះអំពើហិង្សាដែលធ្វើចងជើងព្យួរជ្រមុជទឹកអាង ទឹកអុង គឺខ្ញុំមិនបានដែលឃើញទេលោក អត់ដែលឃើញ ។

[១៥:៤១:៣៣]

**ស៖** លោកមានដែលឃើញគេធ្វើអំពើហិង្សាលើអ្នកទោសជាស្ត្រីទេ?

**ឆ៖** ចំពោះស្ត្រី គឺគេយកទៅសួរកន្លែងផ្សេង គឺខ្ញុំអត់ដែលបានឃើញទេ ។

**ស៖** លោកមានដែលឃើញកុមារមកជាមួយម្តាយ ដែលគេចាប់ម្តាយមក ហើយកុមារមកតាម ហើយគេយកទៅកន្លែងណាដែរ លោកបាន?

**ឆ៖** ចំពោះកុមារគឺខ្ញុំមិនដែលបានដឹងថាគេយកមក មិនដែលឃើញមានកុមារផងនៅក្នុងហ្នឹង។

**ស៖** ចំពោះជនបរទេស បស្ចិមប្រទេសលោកដែលឃើញគេធ្វើអំពើហិង្សាលើគាត់ទេ?

**ឆ៖** ចំពោះអំពើហិង្សាជនបរទេស គឺខ្ញុំមិនដែលបានឃើញគេធ្វើអំពើហិង្សាយ៉ាងម៉េចទេ ព្រោះមិនដែលឃើញគេសួរផង ។

**ស៖** ចុះចំពោះឈ្លើយសឹកវៀតណាម មានដែលឃើញគេធ្វើអំពើហិង្សាទេ?

**ឆ៖** ចំពោះឈ្លើយសឹកវៀតណាម ក៏ខ្ញុំមិនដែលឃើញដែរ ។

**ស៖** លោកដឹងទេ គេប្រើហិង្សាលើអ្នកទោសហ្នឹង ពេលសួរចម្លើយហ្នឹងគេចង់បានអីពីអ្នកទោស?

**ឆ៖** ការសួរចម្លើយគឺ គេចង់បានចម្លើយពីអ្នកទោស គឺចង់បានពីខ្សែរយៈ ខ្សែបណ្តាញរបស់អ្នកទោស ។

**ស៖** លោកមានដែលឃើញគេធ្វើអំពើហិង្សាលើបុគ្គលិកស-២១ ជាអ្នកទោស?

**ឆ៖** ចំពោះអ្នកទោសអ្នកបុគ្គលិកស-២១ គឺមិនដែលបានឃើញទេ គ្រាន់តែ មុខក៏គេមិនឲ្យឃើញផង គេឲ្យទទូរភ្នួយឃ្នុំៗបាត់ ជិតឈឹង មិនបាច់ចាំឃើញធ្វើទារុណកម្មទេ ។

**សៈ** លោកស្គាល់ទេ អ្នកណាបណ្ដើរអ្នកទោសបុគ្គលិកស-២១ ដែលគ្របភ្នួយនោះ?

**ឆ៖** ចំពោះបុគ្គលិកស-២១ ដែលទទូរភ្នួយឃ្នុំៗហ្នឹងគឺច្រើនតែអង្គរក្សរបស់ តាចាន់ និង តាប៉ុន និង តាហ៊ិ ហ្នឹងតែម្ដង ។

[១៥:៤៥:00]

**សៈ** លោកមានដឹងថាគេបណ្ដើរអ្នកទោសបុគ្គលិកស-២១ គ្របភ្នួយហ្នឹងលោកបញ្ជាក់អម្បាញ់មិញ សុទ្ធតែជាអង្គរក្ស តាចាន់, តាហ៊ិ យកទៅសួរចម្លើយនៅកន្លែងណា?

**ឆ៖** គឺយកទៅសួរចម្លើយនៅខាងមុខហ្នឹងដែរ តែពីខាងត្បូងខ្ញុំ ។ នៅខាងត្បូងខ្ញុំរំលងម៉ា--មានថ្នល់មួយ ថ្នល់ហ្នឹងពីខាងលិច អុះ!ពីខាងត្បូងខ្ញុំហ្នឹងមានថ្នល់មួយបណ្ដោយទៅកើតអ៊ីចេះទៅ គាត់តាមជួរ ថ្នល់ហ្នឹង ហើយខ្ញុំនៅជួរថ្នល់ខាងលិច ។

**សៈ** លោកធ្លាប់ឃើញគេបូមឈាមយកពីអ្នកទោសទេ ?

**ឆ៖** ចំពោះការបូមឈាមពីអ្នកទោសគឺខ្ញុំមិនដែលបានឃើញទេ ។

**សៈ** លោកធ្លាប់ មិត្រភក្ដិលោកនិយាយប្រាប់លោកទេរឿងហ្នឹង?

**ឆ៖** ចំពោះមិត្រភក្ដិក៏មិនដែលឮនិយាយដែរ ។

**សៈ** លោកធ្លាប់គេយកអ្នកទោសទៅវះកាត់ដើម្បីរៀនវិជ្ជាពេទ្យទេ?

**ឆ៖** ចំពោះការវះកាត់រៀនវិជ្ជាពេទ្យអ្នកទោសគឺ ខ្ញុំមិនដែលបានឃើញទេ គឺអត់ ។

**សៈ** លោកធ្លាប់ដែលឃើញគេដោះលែងអ្នកទោសទេ បន្ទាប់ពីសួរចម្លើយហើយ?

**ឆ៖** បាទ, ចំពោះរឿងដោះលែងអ្នកទោសគឺខ្ញុំមិនដែលបានដឹង មិនដែលបានឃើញទេ ។

**សៈ** បើលោកមិនដែលឃើញការដោះលែងអ្នកទោសទេ តើជោគវាសនារបស់អ្នកទោសទាំងអស់ហ្នឹងយ៉ាងដូចម្ដេចទៅថ្ងៃក្រោយ?

**ឆ៖** ចំពោះអ្នកដែល-- ជោគវាសនារបស់អ្នកទោសគឺខ្ញុំមិនបានដឹងទេ ព្រោះកាលដែរសួរចម្លើយចប់ ឬក៏គេបញ្ចេញទៅវិញគឺគេដាក់ឡានឃ្នុបជិតៗ អាឡានឃ្នុបហ្នឹងគេដឹកចេញទៅ ហើយគេដឹកចូលមកដាក់ឡានឃ្នុបជិតៗឈឹងអ៊ីចឹងដែរ តែមិនដឹងគេបញ្ជូនទៅខាងណាទេ ព្រោះកាលខ្ញុំដឹងខ្ញុំឃើញតែប៉ុណ្ណឹង ។

**ស៖** លោកមានដឹងថា គេយកអ្នកទោសទៅសម្លាប់នៅស-២១ ទេ ?

**ឆ៖** ចំពោះការសម្លាប់អ្នកទោសនៅស-២១ ខ្ញុំមិនដឹងដែរបានឃើញ មិនដែលបានដឹង ។

**ស៖** ចុះលោកស្គាល់ជើងឯកទេ?

**ឆ៖** ជើងឯក ខ្ញុំធ្លាប់ស្គាល់កាលពីខ្ញុំនៅហាត់បច្ចេកទេស ខ្ញុំក៏ជឹកប្រឡាយនៅហ្នឹង តែជើងឯកសម័យឥឡូវមានសារមន្ទីរដាក់អដ្ឋិធាតុរបស់ជនរងគ្រោះគឺ ខ្ញុំបានទៅឃើញនៅសម័យគេនាំទៅមើលហ្នឹងទស្សនកិច្ចនៅកាលពីរឆ្នាំមុនហ្នឹង ខ្ញុំទើបឃើញឆ្នាំហ្នឹង។ ពីដើមខ្ញុំមិនដែលឃើញទេ ។

**ស៖** នៅក្នុងអំឡុងពេលលោកធ្វើការនៅទីនោះ លោកអត់ដែលឮសោះថាមិត្រភក្តិនិយាយថា អ្នកទោសដែលដឹកចេញ យកទៅសម្លាប់នៅជើងឯក? លោកដែរដឹងទេនៅពេលនោះ?

**ឆ៖** កាលណោះខ្ញុំអត់មានបានដឹងទេ ។ មិនដឹងគេយកទៅណាផង ។

[១៥:៥0:00]

**ស៖** តាមដែលលោករៀបរាប់មក គឺថាលោកលោកនៅមន្ទីរស-២១ ហ្នឹងរយៈពេលយូរដែរ ។ តើនៅពេទ្យហ្នឹងមានប៉ុន្មានដែរ ពេទ្យស-២១?

**ឆ៖** ចំពោះពេទ្យនៅស-២១ មានប្រហែលជាបួនទៅប្រាំនាក់ប៉ុណ្ណឹង ដើរមើលជំងឺអ្នកទោស ។

**ស៖** លោកចាំឈ្មោះទេ ចុងក្រោយបង្អស់អ្នកណា? ឈ្មោះអ្នកណាខ្លះនៅជាពេទ្យស-២១?

**ឆ៖** បាទ, រឿងពេទ្យខ្ញុំមិនសូវបានស្គាល់ទេ ខ្ញុំស្គាល់តែពេទ្យសឿង មួយ ពេទ្យសឿង ហ្នឹងដែលរត់ចេញពីភ្នំពេញបានទៅនៅជាមួយគ្នា ។ សឿង ហ្នឹងបានទៅនៅរហូតដល់ផ្ទះខ្ញុំ ខ្ញុំនៅចាំឈ្មោះគាត់មួយ ឈ្មោះ សឿង ។

**ស៖** ពេទ្យស-២១ មានស្រីទេ?

**ឆ៖** បាទ, ចំពោះពេទ្យអត់មានស្រីផង ឃើញដើរមើលអ្នកទោស ជំងឺអ្នកទោសឃើញតែប្រុស។

**ស៖** មានពេទ្យកុមារប្រុសៗទេ?

**ឆ៖** បាទ ពេទ្យកុមារដូចអត់ឃើញមានផង ឃើញតែអាណិកជន ។

**ស៖** លោកចាំទេ ឈ្មោះអីខ្លះ លោកអាចរៀបរាប់បានទេ?

**ឆ៖** ដូចខ្ញុំថាអ៊ីចឹង ថាអត់បានចាំឈ្មោះទេ ចាំតែឈ្មោះ សឿង មួយ ហើយនិងឈ្មោះអីមួយទៀត ឈ្មោះ យ៉ាន មួយទៀត យ៉ាន ពេទ្យ ។ ខ្ញុំចាំបានពីរហ្នឹង ឈ្មោះពេទ្យអីៗទៀតខ្ញុំ-- វាអត់បានចាំឈ្មោះ ។ សូវស្គាល់ផង ស្គាល់តែមុខ ។ អង្គភាពខុសគ្នាមិនសូវបានស្គាល់គ្នាច្បាស់ទេ ។

**ស៖** ស្គាល់ពេទ្យ សេក ដន ទេ?

**ឆ៖** បាទ, សេក ដន ហ្នឹង គឺបាទ,ស្គាល់ ។

**ស៖** សេក ដន ធ្វើអីកាលនោះ នៅស-២១?

**ឆ៖** កាលនោះ សេក ដន ហ្នឹងប្រហែលជាពេទ្យមែន ព្រោះខ្ញុំចំណាំតែមុខ ឃើញឈ្មោះ ដនៗ ហ្នឹង ។ វាភ្លេចបាត់ទៅ មិនដឹងជាកាលនោះដឹងគាត់ធ្វើអីទេ ។ ពេទ្យនុំងមិនដឹង ខ្ញុំមិនសូវបានចាប់អារម្មណ៍ ឬនឹកឃើញអី ។

**ស៖** តើមានមុខមនុស្សហ្នឹងនៅស-២១ ទេ កាលនោះ? (លោកប្រធាន ខ្ញុំអស់សំណួរសួរ) ។

**ឆ៖** បាទ, ជំនាន់ ឈ្មោះ សេក ដន ហ្នឹងគឺស្គាល់ច្បាស់ កាលនៅហាត់បច្ចេកទេសជាមួយគ្នា គឺនៅក្រុមជាមួយគ្នា នៅពួកជាមួយគ្នា ខ្ញុំស្គាល់ច្បាស់ ។ បានចេញមកនៅមន្ទីរស-២១ គឺមិនដឹងជាភារកិច្ចគាត់ធ្វើអី ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីថៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

លោក អញ្ជើញលោក ហ្សង់ម៉ាក ។

[១៥:៥៤:១៤]

**សួរដោយថៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី សូមលោកប្រាប់យើងថា តើនៅក្នុងបន្ទប់ដែលលោកសួរចម្លើយនោះ តើមានការណែនាំដែលគេបិទនៅលើជញ្ជាំងនោះដែរឬទេ?

**ឆ៖** ចំពោះការណែនាំបិទលើជញ្ជាំងយ៉ាងណានោះ ខ្ញុំអត់បានឃើញជញ្ជាំងបិទថាម៉េចផង គឺខ្ញុំសូមអត់ឆ្លើយ ។

**ថៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រហែលជាលោកប្រធានអាចនឹងសួរសំណួរនេះឲ្យបានច្បាស់ អាចងាយយល់ ហើយខ្ញុំអាចនឹងបង្ហាញនៅលើឯកសារលេខ ERN ជាភាសាខ្មែរ 00181448 ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីផ្នែកខាងសោតទស្សន៍បង្ហាញឯកសារដែលលោកថៅក្រម ហ្សង់ម៉ាក អានអម្បាញ់មិញនេះលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

លោក សេក ដន *(ស៊ិក)* [ឡាច មាន] លោកពិនិត្យមើលនៅសំណេរនេះ ដែលនៅក្នុងឯកសារគឺបានបង្ហាញថា សំណេរនេះ គេបានសរសេរនៅតាមជញ្ជាំងនៅលើក្តារខៀន នៅកន្លែងដែលសួរចម្លើយ តើលោកដែលបានឃើញនៅសំណេរនេះទេ ក្នុងនាមលោកដែរជាអ្នកសួរចម្លើយថ្មី ដែលទើបតែបានរៀន ហើយទៅធ្វើការសួរចម្លើយជាមួយអ្នកមុនៗ ហើយនៅក្នុងអំឡុងពេលដែលលោកសួរចម្លើយចុងក្រោយនោះ?

ម្តងទៀត លោកដែលឃើញទេ នៅកន្លែងដែលលោកសួរចម្លើយ តើមានក្តារខៀនដែលគេសរសេរដូច្នេះដែរឬទេ? ខ្ញុំអានមួយចំនួនគឺ "វិន័យសន្តិបាលៈ ១) សួរអីឆ្លើយនឹង មិនបង្វែរសំណួររបស់អញ ។ ២) មិនឲ្យដោះស្រាយយកលេសនេះលេសនោះតាមគំនិតឯងដាក់ ឬប្រកែក កុហកមិនបានដាច់ខាត..." គឺមានតាមរបៀបហ្នឹងរហូតដល់ប្រាំបួនចំណុច ។ តើលោកដែលបានឃើញសំណេររបៀបនេះនៅក្នុងទីកន្លែងដែលលោកទៅសួរចម្លើយនោះដែរឬទេ?

**លោក ឡាច មាន៖**

បាទ, ចំពោះសំណេរអស់នេះ គឺកាលនោះគឺកាលខ្ញុំនៅសួរចម្លើយ គឺគ្មានក្តារខៀន គ្មានសំណេរសរសេរជាវិន័យរបៀបនេះទេ គឺអត់ ។

[១៥:៥៨:២២]

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍ដកឯកសារនេះចេញពីអេក្រង់ទូរទស្សន៍ ហើយបង្វែររូបភាពទៅជារូបភាពប្រក្រតីឡើងវិញ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ប្រសិនបើលោកមិនបានឃើញការណែនាំសរសេរនៅលើក្តារខៀននោះទេ តើការណែនាំហ្នឹងប្រាប់មកលោកដោយផ្ទាល់មាត់នៅក្នុងការរៀនសូត្រ ដែលថា លោកត្រូវតែអនុវត្តទៅតាមការណែនាំដែលលោកឮនៅក្នុងការរៀនសូត្រនោះឬ?

**ឆ៖** ចំពោះសំណួរនេះ ការដែលគេណែនាំមកគឺ គេណែនាំតែពេលយើងសួរចម្លើយ គឺរៀនពីគេផ្ទាល់តែម្តង គឺអត់បានសរសេរជាសំណេរ ចារជាសំណេរដាក់លើក្តារខៀន គឺអត់មាន គឺមានតែផ្ទាល់មាត់ ។ រៀន និយាយរួមគឺរៀនផ្ទាល់ មើលគេ គេសួររបៀបម៉េច ហើយគេសង្កត់របៀបម៉េចឲ្យអ្នកទោសឆ្លើយ ។

**ស៖** អ៊ីចឹង ទាក់ទងទៅនឹងទិចនិច ឬក៏វិធីសួរ យើងនិយាយអំពីគ្រឿងប្រដាប់មួយដែលថាដាក់នៅត្រចៀក ចាប់នឹងត្រចៀក ថាតើឧបករណ៍ហ្នឹងគេធ្វើរបៀបម៉េច ដែលថាឆក់ហ្នឹង?

**ឆ៖** ការទិចនិចឆក់ហ្នឹង គឺអាហ្នឹងកាលនោះ ឮគេហៅថាអាដាក់គីងគួករវៃៗ អាហ្នឹងរបៀបដូចឌីណាម៉ូកង់ រវៃចេញភ្លើងទៅ គឺអាចឆក់ ។

**ស៖** តើលោកមានដឹងទេថា នៅក្នុងចំណោមបុគ្គលិកស-២១ ទាំងអស់ហ្នឹង មានបុគ្គលិកណាម្នាក់ឈ្មោះ គក ស្រស់ ដែរឬទេ?

**ឆ៖** បាទ, ចំពោះ គក ស្រស់ នេះគឺខ្ញុំអត់បានស្គាល់ផង ដូចជាមិនដែលឮឈ្មោះផង ។

**ស៖** ដូច្នេះ លោកមិនដែលបានជួបគាត់ទេឬ មិនដែលបានជួបនៅតាខ្មៅ ឬក៏នៅប៉ៃហ្ស៊ី ឬក៏នៅស-២១ នោះ?

**ឆ៖** បាទ, អត់ៗដែលជួបផង អត់ដែលស្គាល់ផង ។

[១៦:០១:៤៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំអត់មានសំណួរបន្ថែមទៀតសម្រាប់សាក្សីនេះទេ។ ក៏ប៉ុន្តែ ខ្ញុំចង់ដឹងថា តើជនជាប់ចោទគាត់មានជំហរដូចម្តេចដែរ? ហើយថាតើគាត់ស្គាល់ ឬនៅចាំសាក្សីនេះដែរឬទេ ដែលថាគាត់ សាក្សីនេះធ្លាប់ជាបុគ្គលិកធ្វើការនៅស-២១នោះ?

**ជនជាប់ចោទ៖**

លោកចៅក្រមជាទីគោរព! ចំពោះសាក្សីរូបនេះ ខ្ញុំនៅមានការស្ទាក់ស្ទើរច្រើនណាស់ ។ ទីមួយបើនិយាយអំពីហេតុផលដែលល្មមឲ្យខ្ញុំទទួលបានថាគាត់ជាបុគ្គលិករបស់មន្ទីរស-២១ មានច្រើន ។

សូមបញ្ជាក់ជូនអង្គសវនាការថា ខ្ញុំពិតជាមានមនោសញ្ចេតនានឹងស្រុកកំពង់ត្រឡាចលើ ព្រោះវាមូលដ្ឋានបង្អែកបដិវត្តន៍ចាស់ ។ ប្រពន្ធក៏ខ្ញុំយកនៅកំពង់ត្រឡាចលើ យុទ្ធជនក៏ខ្ញុំចង់បានពីខាងនុ៎ង ។ ដូច្នេះ សាក្សីរូបនេះពិតជានៅក្នុងជម្រើសដែលខ្ញុំចង់បានធ្វើជាបុគ្គលិកមែនហើយ ។ ក្នុងសក្ខីកម្មទាំងអស់របស់គាត់នៅមន្ទីរស-២១ មជ្ឈមណ្ឌលភ្នំពេញ គួរស្តាប់បាន គួរទទួលយកបាន បើយើងយកត្រឹមតែហេតុផលថាគាត់អត់ដាក់បន្ទុកដល់ខ្ញុំ វាគួរថានឹងរីករាយទទួល ។ ក៏ប៉ុន្តែ ខ្ញុំមានជំហរមួយ មិនចង់ឲ្យអ្នកណាដែលមិនមែនជាបុគ្គលិកស-២១ មកជំពាក់វាក់វិននឹងស-២១ទេ ព្រោះស-២១ វាជាយន្តការឧក្រិដ្ឋរបស់ ប៉ុល ពត មិនចង់ឲ្យប្រវត្តិរូបគេមកប្រឡាក់ប្រឡូសទេ ។

ទីពីរ មិនចង់ឲ្យអ្នកណាដែរមិនជាប់ជំពាក់ក្រោមបញ្ជាខ្ញុំផ្ទាល់មកនៅក្រោមបញ្ជាខ្ញុំ ។ នេះខ្ញុំមានគោលជំហរហ្នឹង ។ ដោយសារមានគោលជំហរហ្នឹងហើយបានជាខ្ញុំសូមលើកជាការសង្ស័យ ជាការចាប់អារម្មណ៍ ។ ខ្ញុំអត់មានដែលបានចង់បានទ័ពស្រុករបស់គេមកធ្វើបុគ្គលិកខ្ញុំ ។ ខ្ញុំចង់បានតែក្មេងជំទង់ដែលមិនទាន់ចូលក្នុងអង្គភាពណាច្បាស់លាស់ គឺនៅក្នុងអង្គភាពកុមារ ឬក៏អង្គភាពក្មេងជំទង់មកធ្វើជាបុគ្គលិករបស់ខ្ញុំ ។

ដូច្នេះ រូបបុគ្គលលោក ឡាច មាន ធ្វើឲ្យខ្ញុំរារែកមែនទែន ។ តើគាត់ជាមនុស្សយ៉ាងម៉េច? មកជាបុគ្គលិកស-២១ ឬយ៉ាងម៉េច? ខ្ញុំអត់ទាន់ប៉ានឆ្លើយទេ ។ នេះជាបញ្ហាមួយ ។

បញ្ហាទីពីរ គាត់និយាយពីសភាពការណ៍ គាត់យាមអ្នកទោសនៅតាខ្មៅ ។ សភាពការណ៍ប្រើប្រាស់អ្នកទោសនៅតាខ្មៅ គាត់និយាយហ្នឹងមិនត្រឹមត្រូវតាមសភាពការណ៍ដែលមាននៅតាខ្មៅពេលនោះទេ ។

[១៦:០៤:៥៤]

ទីបី ហេតុផលមួយទៀត នៅប៉ូលិសភ្នំពេញដែលភាសាអ្នកភ្នំពេញគេហៅ *"ប៉េហ្សេ"* នោះ ពួកខ្មែរក្រហមហៅ*"ប៉េអេស"* ។ មានតែខ្ញុំទេដែលប្រើពាក្យផ្លូវការណ៍ជូនសហចៅក្រមស៊ើបអង្កេត ហើយនិងជូនអង្គសវនាការនេះ ជាពាក្យផ្លូវការជំនាន់ សីហនុ គេហៅថា "អគ្គនាយកដ្ឋាននគបាលជាតិ" ហើយគិតយកពាក្យនោះមកប្រើដែរ ពាក្យនេះជ្រៅ ។ ដូច្នេះ ធ្វើឲ្យខ្ញុំកាន់តែចាប់អារម្មណ៍ដល់គាត់ថែមទៀត ។ ដោយឡែកនៅចុងបញ្ចប់នេះ គាត់មាននិយាយថា ខ្ញុំបានទូរស័ព្ទទៅណែនាំគាត់ វាជារឿងមួយប្លែក ។ នៅពេលដែលគាត់សួរចម្លើយជាមួយហ្នឹង ប្រហែលជាដប់ឆ្នាំមុន គាត់ថាគាត់សួរចម្លើយបានម្នាក់ឈ្មោះ ប៉ែន សាម៉ន ។ ខ្ញុំខំស្រាវជ្រាវដែរ នៅក្នុងបញ្ជីស-២១ អត់ឃើញទេឈ្មោះ ប៉ែន សាម៉ន ឃើញឈ្មោះឯណាឯណីនេះទៅវិញ ។

ដូច្នេះ ហេតុផលទាំងប៉ុន្មាននេះ ធ្វើឲ្យខ្ញុំរារែក ។ ខ្ញុំជម្រាបថា ធ្វើឲ្យខ្ញុំរារែកមិនទាន់ច្បាស់ទេ ចាំមើលខ្ញុំទៅពីនេះវិញ ទៅមើលបញ្ជីនៅផ្ទះ តើមានឈ្មោះគាត់នៅក្នុងនុ៎ងទេ? បញ្ជីអ្នកសួរចម្លើយប៉ុន្មាននាក់នោះ ដែលមានជាប់ជំពាក់ជាមួយជនរងគ្រោះដែលត្រូវឆ្លើយនេះ ហើយនេះទេ ឲ្យគាត់រកនឹក-- សុំជួយស្រាវជ្រាវមើល៍ តើគាត់សួរចម្លើយអ្នកណាខ្លះ មានស៊ីញ៉េគាត់នៅចុងសំណួរនោះទេ? នេះជាឯកសារដែលខ្ញុំគិតថា គួរតែលើកឡើងដើម្បីជួយបន្ថែមឲ្យបានយល់ ។ នេះខ្ញុំសូមបញ្ជាក់ជូនអំពីការយល់ឃើញរបស់ខ្ញុំប៉ុណ្ណេះ។ សូមគោរព ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ឡាច មាន ចម្លើយរបស់លោកដែលបានឆ្លើយចំពោះសំណួររបស់លោកចៅក្រម យ៉ា សុខន កន្លងមកនេះ អំពីផ្ទះបាយរួមសម្រាប់កម្មាភិបាលបុគ្គលិកស-២១ តើមានតែមួយកន្លែង ឬក៏មានច្រើនកន្លែង?

**ឆ៖** ចំពោះផ្ទះបាយសារមន្ទីរស-២១ គឺមានតែពីរកន្លែងទេ មានតែកន្លែងខាងកងការពារ និងកន្លែងកងសួរចម្លើយ មានពីរកន្លែងចំពោះបុគ្គលិក ។ តែចំពោះសេដ្ឋកិច្ច អ្នកទោស មានកន្លែងផ្សេងទៀត ។

**ស៖** ផ្ទះបាយសម្រាប់កងការពារហ្នឹងគឺនៅកន្លែងណា? នៅផ្លូវណា? ដែលលោកអាចនិយាយរៀបរាប់បង្ហាញអំពីទីតាំងនៃផ្ទះបាយសម្រាប់កងការពារឲ្យច្បាស់លាស់ដែរឬទេ? ហើយផ្ទះបាយសម្រាប់អ្នកសួរចម្លើយហ្នឹងនៅកន្លែងណាដែរ?

[១៦:០៨:០៨]

**ឆ៖** ផ្ទះបាយចំពោះកងការពារពីដើមគឺ នៅពីក្រោយរបងសារមន្ទីរ។ ឯផ្ទះបាយចំពោះកងសួរចម្លើយគឺនៅពីខាងស្តាំដៃរបស់សារមន្ទីរនៅតាមថ្នល់ ។ តាមថ្នល់កាលនុំងមានថ្នល់កៅស៊ូមួយចេញទៅផ្លូវធំ ហ្នឹងផ្ទះបាយរបស់កងសួរចម្លើយ ឯផ្ទះបាយរបស់កងការពារគឺនៅពីក្រោយ គឺនៅពីខាងលិចរបស់មន្ទីរហ្នឹង ។

**ស៖** ដាច់ដោយឡែកពីគ្នា? ហើយចម្ងាយប្រហែលប៉ុន្មានពីគ្នាទៅផ្ទះបាយសម្រាប់ក្រុមអ្នកសួរចម្លើយ ហើយនិងផ្ទះបាយសម្រាប់អ្នក សម្រាប់កងការពារ ឃ្លាតគ្នាប្រហែលប៉ុន្មានម៉ែត្រពីគ្នា?

**ឆ៖** កាលពីខ្ញុំនៅកងការពារ គឺផ្ទះបាយនៅឆ្ងាយពីគ្នាប្រហែលជា ប្រហែលជាប់ពីររយម៉ែត្រពីគ្នាឆ្ងាយ តែក្រោយមកគឺខ្ញុំប្រហែលជិតចុង៧៨ ហើយបានរើកងការពារមកនៅ មួយនៅពីខាងលិចថ្នល់អាមួយនៅពីខាងជើង មួយនៅពីខាងត្បូងថ្នល់ ។ ហ្នឹងកងការពារនៅពីខាងជើង កងសួរចម្លើយនៅខាងត្បូង ។

**ស៖** ប្រៀបធៀបនឹងកន្លែងសារមន្ទីរគុកទួលស្លែងបច្ចុប្បន្ន តើផ្ទះបាយសម្រាប់កម្មាភិបាលបុគ្គ-លិកនៅមន្ទីរស-២១ នេះនៅខាងណា?

**ឆ៖** នៅពីខាងត្បូងរបស់សារមន្ទីរចំជ្រុង ជ្រុងរបងលួសសារមន្ទីរនោះ ។ ជ្រុងខាងត្បូងឆៀងខាងកើត ។

**ស៖** លោកស្គាល់កន្លែងដែលមានការទទួលបុគ្គលអ្នកទោសចាប់បញ្ជូនមកពីកន្លែងផ្សេងៗទេ? មានដែលថា មានចំណុចកងការពារគេប្រគល់ទទួលអ្នកទោសដែរឬទេ?

**ឆ៖** ចំពោះទទួលអ្នកទោសគឺ ឃើញភាគច្រើនដឹកឡានមកដាក់ពីមុខរបង ពីមុខកន្លែងក្រៅទ្វារចូលហ្នឹងតែម្តង ។ ឃើញភាគច្រើនដឹកយកមកដាក់កន្លែងហ្នឹង ឡានតូចក៏មាន ឡានធំក៏មាន មកដាក់ មកដាក់ពីមុនទ្វារមាត់បង្អួច មាត់របងហ្នឹងបណ្តោយ ។

**ស៖** ចំណុចមួយទៀត លោកនិយាយពាក់ព័ន្ធដល់កន្លែងសួរចម្លើយនៅខាងក្រៅរបងដែលមានព័ទ្ធទៅដោយលួសបន្លា តែនៅខាងក្នុងរបងដែលមានរបាំងដោយស័ង្កសី ។ សំណួរសួរថា តើរបងដែលរបាំងស័ង្កសីនោះនៅផ្នែកខាងកើតនៃមន្ទីរស-២១ ហ្នឹង គេបាំងផ្លូវនៅត្រង់ចំណុចណា?

**ឆ៖** ចំពោះស័ង្កសីដែលបាំងផ្លូវ ឲ្យតែមានផ្លូវ គឺបាំងស័ង្កសីគ្រប់កន្លែងជុំវិញ ចម្ងាយប្រហែលជាមួយរយម៉ែត្រពីរបងលួសបន្លា ។

**ស៖** ខាងកើតហ្នឹងគេបាំងទៅដល់ផ្លូវដែលរ៉ូបជាមួយនឹងលូទឹកស្អុយដែរឬទេ? ឬក៏បាំងហួសផ្លូវរ៉ូបនឹងលូទឹកស្អុយ? លោកស្គាល់លូទឹកស្អុយទេ?

**ឆ៖** បាទ, ចំពោះពីខាងកើតគឺ អាផ្លូវកៅស៊ូមួយ គឺអត់បានបាំងទេ ផ្លូវហ្នឹងគឺចំហ អាផ្លូវលំតូចៗគឺបាំងៗអត់-- គឺបាំងអែបនឹងលូទឹកស្អុយហ្នឹងគឺខាងលិចលូទឹកស្អុយនឹងបណ្តោយ ។ បាំងអែបលូហ្នឹង ទុកប៉ុនថ្នល់សម្រាប់ដើរ ។

**ស៖** អ៊ីចឹងការបាំងហ្នឹងមិនឲ្យជិតទេ គ្រាន់តែទុកច្រកសម្រាប់ដើរប៉ុណ្ណោះ ។

**ឆ៖** ច្រកនុ៎ងធំដែរ ប៉ុនថ្នល់ ដើរអមលូទឹកស្អុយហ្នឹង ។

**ស៖** ចុះខាងត្បូង ទៅខាងត្បូងគេបាំងស័ង្កសីដល់ត្រឹមណាដែរ?

**ឆ៖** បាទ, ចំពោះទៅត្បូងគឺ ស័ង្កសីដល់តាមថ្នល់ ។

**ស៖** ត្រង់ចំណុចណាមួយដែលគេបាំងស័ង្កសីផ្នែកខាងត្បូង ផ្លូវទៅត្បូងវិញ អាផ្លូវទៅខាងត្បូងគេបាំងនៅចំណុចណា?

**ឆ៖** ឯចំពោះផ្លូវទៅខាងត្បូងគឺបាំងទៅដល់ទួលទំពូង ដល់ថ្នល់ទួលទំពូងបណ្តោយ ថ្នល់កៅស៊ូទួលទំពូងហ្នឹង ។

**ស៖** ចុះផ្នែកខាងជើង ខាងជើងទៅផ្លូវទៅខាងជើងនៃមន្ទីរស-២១ ហ្នឹងគេបាំងរបងស័ង្កសីហ្នឹងដល់ផ្លូវទីប៉ុន្មាន ដល់ចំណុចណាដែរ?

**ឆ៖** បាទ, ចំពោះទៅខាងជើងមិនដឹងដល់ចំណុចណាទេ តែខ្ញុំអត់ស្គាល់ជំនាន់នោះ គឺមិនបានស្គាល់ថាកន្លែងហ្នឹងជាកន្លែងអី តែចំណាយប្រហែលជាមួយរយម៉ែត្រពីរបងលួស ។

**ស៖** ចាប់ពីពេលដែលលោកត្រូវបានចាត់តាំងឲ្យមកធ្វើការនៅតាខ្មៅ នៅ*ប៉េហ្ស៊ី* ហើយក្រោយមកនៅមន្ទីរសន្តិសុខស-២១ តើលោកដែលបានការអនុញ្ញាតឲ្យលោកចាកចេញពីមន្ទីរទាំងអស់នេះទៅធ្វើដំណើរទៅឆ្ងាយ ចាកចេញពីទីនេះទៅទីកន្លែងផ្សេងទៀតឆ្ងាយពីនេះដែរឬទេ ដូចជាទៅផ្ទះដើម្បីសួរសុខទុក្ខឪពុកម្តាយជាដើម?

[១៦:១៥:២៣]

**ឆ៖** ចំពោះចេញពីទីកន្លែងអង្គភាពស-២១ គឺមិនដែលបានទៅណាទេ គឺប្រៀបធៀបនឹងអ្នកទោសដែរ អ្នកដែលនៅក្នុងនុំងប៉ុន្មានគឺមិនដែលបានចេញទៅក្រៅទេ ព្រោះការងារជាការងារសម្ងាត់ម្ល៉ោះហើយគេអប់រំថា យើងមិនត្រូវចេញទៅក្រៅ ចេញទៅក្រៅបែកការងារសម្ងាត់របស់គេ ។ នេះជាមិនដែលចេញទៅណាឆ្ងាយពីក្រៅរបង និយាយរួមក្រៅស័ង្កសីនេះ គឺអត់ដែលបានដើរទេ ។ មិនស្គាល់ថាត្រង់នេះត្រង់នោះ ។ ក្រុងភ្នំពេញហ្នឹងយ៉ាងម៉េចមិនបានស្គាល់ផង ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោក ឡាច មាន ឥឡូវនេះដោយសារលោកទើបតែបានសួរសាកសួរដោយអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ នៅភាគីផ្សេងទៀតមិនទាន់បានសាកសួរដល់លោកនៅឡើយ ។ អ៊ីចឹងគឺអង្គជម្រះត្រូវការអញ្ជើញលោកមកនៅថ្ងៃស្អែកមួយព្រឹកទៀតដើម្បីផ្តល់សក្ខីកម្ម ហើយទោះបីយ៉ាងណាអង្គជំនុំជម្រះអរគុណដល់លោកដែលជាសាក្សី ដែលបានអញ្ជើញមកផ្តល់សក្ខីកម្មតាមការកោះអញ្ជើញរបស់អង្គជំនុំជម្រះ ។

ហើយមន្ត្រីតុលាការសម្របសម្រួលនាំសាក្សីទៅពាក់ព័ន្ធជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញដើម្បីជូនគាត់ទៅរកកន្លែងសម្រាក និងឲ្យខាងផ្នែកអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនគាត់ត្រឡប់មកវិញនៅថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួនព្រឹក ។

ហើយអនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំង ហើយឲ្យនាំគាត់មកកាន់សវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក ។

ផ្អាកសវនាការត្រឹមថ្ងៃនេះ សម្រាប់ថ្ងៃនេះត្រឹមនេះ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:១៧ នាទី]*